ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- យកចិត្តទុកដាក់លើអំពើប្រល័យពូជសាសន៍
- ចងចាំអំពីគោលនយោបាយយេនឌ័រហួសហេតុរបស់ អៀង ធីរិទ្ធ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៨៨ ខែសីហា ឆ្នាំ២០១៥

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៨៨ ខែសីហា ឆ្នាំ២០១៥

## មាតិកា

◆ យកចិត្តទុកដាក់លើអំពើប្រល័យពូជសាសន៍ ..........១
◆ បងប្អូនប្រវត្តិសាស្ត្រ ៖ ស្នាមរបួសពីអតីតកាល ..........២
◆ ចងចាំអំពីគោលនយោបាយយេនឌ័រហួសហេតុរបស់ ..........៥

**ផ្នែកឯកសារ**

◆ ចម្លើយសារភាពរបស់ នូ អ៊ានឡេង ហៅ គល់ ..........៧
◆ យុវជន យុវនារីបដិវត្តន៍ ត្រូវពង្រឹងពង្រីកគោលជំហ ..........១២
◆ សាទូលេខទាក់ទងបញ្ហាព្រំដែនវៀតណាម និង ..........១៩

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ហេតុអ្វីបានចូលរួមធ្វើបដិវត្តន៍? ..........២១
◆ នីសារ និងអ្នកបើកឡានឲ្យ សោ ភឹម ..........២៤
◆ រត់ចេញពីគុកដើម្បីរស់ ..........២៨
◆ ការបាត់បង់ បន្សល់ទុកត្រឹមតែអនុស្សាវរីយ៍ ..........៣០
◆ ចាប់ពីរបបខ្មែរក្រហមដល់ឧប្បត្តិហេតុ ហាំបាលី ..........៣២

**ផ្នែកច្បាប់**

◆ ការស្លាប់របស់ជនជាប់ចោទ អៀង ធីរិទ្ធ ..........៤៩

**វេទិកាពិភាក្សាសាធារណៈ**

◆ ការជំរុញទឹកចិត្តពីអ្នកទោសខ្មែរក្រហម ..........៥៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ រសាត់តាមខ្យល់ ..........៥៦



ជនរងគ្រោះនៅសន្តិសុខស-២១ ត្រូវបានឆ្មាំនាំទៅថតរូប មុននឹងទៅឃុំឃាំង និងសួចម្លើយ

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** សូ ហ្វារីណា, ស៊ាន ចិន្តា, អេង កុកថាយ, ជិន ដួងចន្ទ្រាកែវលក្ខ្មីនារីរតន៍, សុភ័ក្ត្រ ភាណា, ប៉ុក ប៉ុនសូម៉ាជ **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** ទាវ សារៈមុនិន្ទ និង ឆេង វើង **អ្នកបកប្រែ ៖** សុភ័ក្ត្រ ភាណា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ ៖** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ ៖** ឆេង វើង និង សន ល័ក្ខ Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org, www.truthcambodia.com

# យកចិត្តទុកដាក់លើអំពើប្រល័យពូជសាសន៍



អដ្ឋិធាតុជនរងគ្រោះដែលតម្កល់ទុកនៅវត្តឫស្សីសាញ់ ឃុំឫស្សីសាញ់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង

អំពើប្រល័យពូជសាសន៍ គឺជាបាតុភូតដ៏គួរឲ្យភ្ញាក់ផ្អើលមួយ ដែលបានកើតមានឡើងនាប៉ុន្មានទសវត្សរ៍កន្លងទៅនេះ ហើយយើងក៏បានឮច្រើនអំពីបញ្ហានេះផងដែរ បើទោះជាយើងបានបន្សាំខ្លួនជាមួយនឹងវាហើយក៏ដោយ ។ ចាប់តាំងពីការស្លាប់នៃជនជាតិអាមេនាន ដែលជំរុញឲ្យមាននូវការសម្លាប់រង្គាលលើជនជាតិជ្វីហ្វ រហូតដល់ទីលានពិឃាតរបស់ប្រទេសកម្ពុជា និងបន្ទាប់មកគឺការកាប់សម្លាប់ដ៏ព្រៃផ្សៃនៅតំបន់ ដារហ្វួរី លើភូមិជាច្រើន យើងក៏បានរកឃើញនូវអំពើប្រល័យពូជសាសន៍ ។ យើងបានឮអំពីវាតាមរយៈទូរទស្សន៍ ។ យើងបានអានអំពីវានៅលើសារព័ត៌មាន និងសៀវភៅ ។ តើមានអ្វីកើតឡើង? ភ្លាមៗនោះយើងក៏បញ្ឈប់ និងបង្វែរខ្សែចក្ខុរបស់យើង ចេញពីរបស់អស់ទាំងនោះ ។ បន្ទាប់មកយើងបន្តទៅមុខទៀត ។ សកម្មភាពនេះហើយដែលបណ្តាលឲ្យអំពើប្រល័យពូជសាសន៍នៅតែរាតត្បាតឥតឈប់ឈរ ម្តងហើយម្តងទៀត ។ ដើម្បីប្រឆាំងនឹងអំពើនេះ យើងត្រូវតែរៀបចំឥរិយាបថរបស់យើងចំពោះវា ។ វានឹងមិនអាចលាក់កំបាំងបានយ៉ាងងាយទេ ។ ជាការពិតណាស់ យើងត្រូវតែយកចិត្តទុកដាក់អំពីអំពើប្រល័យពូជសាសន៍ ។ យើងត្រូវតែមើលឲ្យបានស៊ីជម្រៅអំពីភាពល្អក់កកររបស់វា និងយល់ដឹងអំពីការកកើតឡើងបន្តិចម្តងៗរបស់វា ដែលអាចបញ្ជ្រៀតខ្លួនចូលទៅក្នុងលក្ខខណ្ឌរបស់មនុស្ស ។ ប្រសិនបើមើលលើវាដោយមិនព្រិចភ្នែកយ៉ាងដូច្នេះ យើងអាចដឹងថាវាជាអ្វី តើវាឃោរឃៅខ្លាំងកម្រិតណាបើផ្អែកលើលក្ខខណ្ឌរបស់មនុស្ស ហើយថាតើ អមជាមួយនឹងការយល់ដឹងនេះ យើងអាចសិក្សាអំពីរបៀបបញ្ឈៀស វាឲ្យចេញឆ្ងាយនិងមិនអាចកកើតឡើងម្តងទៀត ។ សុន្ទរកថានេះនឹងពិចារណាលើការវិវត្តនៃគោលគំនិតទូទៅនៃអំពើប្រល័យពូជសាសន៍ ។ វានឹងធ្វើការតាមដាននូវប្រវត្តិនៃគំនិតនេះ ហើយបន្ទាប់មកផ្តល់ជាមតិលើវិធីអប់រំសាធារណជនអំពីអ្វីដែលអំពើប្រល័យអាចនឹងផ្លាស់ប្តូរ ។ យើងត្រូវតែយកចិត្តទុកដាក់អំពីប្រវត្តិនៃអំពើប្រល័យពូជសាសន៍ ដែលអាចឲ្យយើងលុបបំបាត់នូវការបំផ្លិចបំផ្លាញនៃអំពើប្រល័យពូជសាសន៍ ។ **ឆាំង យុ**

# បងប្អូនប្រវត្តិសាស្ត្រ ៖ ស្លាកស្នាមរបួសពីអតីតកាល នៅក្នុងប្រទេសភូមា និងកម្ពុជា

ប្រទេសភូមានៅតែបន្តប្រឈមនឹងជម្លោះ ហើយដែលត្រូវបានពិពណ៌នាថា គឺជាប្រទេសមួយដែលមានសង្គ្រាមស៊ីវិលអស់រយៈពេលដ៏យូរអង្វែងនៅក្នុងប្រវត្តិសាស្ត្រសម័យទំនើប ។

ខណៈដែលការលើកទឹកចិត្តផ្នែកសេដ្ឋកិច្ច និងនយោបាយពិតជាដើរតួនាទីយ៉ាងសំខាន់នៅក្នុងជម្លោះនោះ វាគ្មានការសង្ស័យដែលថា ទស្សនៈនៃភាពខុសគ្នាជំរុញនូវកត្តាទាំងពីរខាងលើ ។ ទស្សនៈនៃភាពខុសគ្នា អាចកើតឡើងក្នុងទម្រង់ផ្សេងៗ ។ ជម្លោះដីព្រៃឈើ និងហេតុការណ៍ដ៏ឃោរឃៅទ្រង់ទ្រាយធំដទៃទៀត ដែលកើតឡើងចំពោះមនុស្សជាតិ គឺសុទ្ធសឹងតែបង្កឡើងដោយទស្សនៈនៃភាពខុសគ្នារវាងជាតិ ជាតិពន្ធុ និង សាសនា ។

ក៏ប៉ុន្តែ តើមនុស្សទាំងអស់ពិតជាខុសគ្នាមែនឬ? មនុស្សក្នុងសកលលោកអាចនឹងកត់ចំណាំនូវភាពខុសគ្នាបានយ៉ាងងាយស្រួល ។ នៅពេលដែលយើងសម្លឹងមើលទៅកាន់មនុស្សម្នាក់ទៀតនៅតាមផ្ទះ ភូមិ ខេត្ត ឬ ប្រទេសជិតខាង ទោះបីជាមានចំណុចខុសគ្នាជាច្រើនដែលយើងអាចកត់សម្គាល់បានយ៉ាងណាក្តី ក៏ចំណុចរួមគ្នាដែលមនុស្សទូទៅមាននៅតែស្មើ ឬច្រើនជាងចំណុចខុសគ្នាដដែល ។ វាជាមេរៀន មួយដែលប្រទេសក្រោយជម្លោះរៀនសូត្រពីបទពិសោធន៍ដ៏ជូរចត់ ។ ប្រទេសកម្ពុជាមានរឿងរ៉ាវជាច្រើនដើម្បីប្រាប់ទៅរដ្ឋាភិបាល និងប្រជាជនភូមា ។

ចាប់តាំងពីឆ្នាំ១៩៧០ រហូតដល់ការចុះចូលនៃតំបន់រឹងមាំចុងក្រោយរបស់ខ្មែរក្រហម នាឆ្នាំ១៩៩៨ ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលហែកហួរ និងខ្ទេចខ្ទាំដោយសារសង្គ្រាមខ្លាំង



រូបខាងឆ្វេង ជិត មិនឡាន (អតីតអ្នកទោសនយោបាយភូមា) និងលោក ឆាំង យុ ជនរងគ្រោះក្នុងរបបខ្មែរក្រហម នៅប្រទេសភូមា

បំផុតក្នុងពិភពលោក ។ ប្រទេសកម្ពុជាបានទទួលរងនូវភាពចលាចលក្នុងសង្គម និងសង្គ្រាមចាប់តាំងពីទសវត្សទី៦០ (ឬមុននេះ) ។ នៅពេលដែលខ្មែរក្រហមក្តោបក្តាប់ប្រទេសនៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានបំផ្លាញនូវជាតិ ជាតិពន្ធុ និងសាសនា ដែលខុសពីការឃោសនារបស់ខ្លួនក្នុងការកែទម្រង់ប្រទេស ។ ប្រជាជនរាប់លាននាក់ត្រូវទទួលរងទុក្ខ និងការសម្លាប់ ។ អ្នករស់រានមានជីវិតក្នុងពេលបច្ចុប្បន្ន ក៏ដូចជាកូនចៅរបស់ជនរងគ្រោះ និងអ្នកដែលបានស្លាប់ទៅ បានបន្តចងកំហឹងចំពោះអ្វីដែលបានកើតឡើង ។ ក៏ប៉ុន្តែដោយសារតែពេលវេលា និងកិច្ចខិតខំប្រឹងប្រែង កម្ពុជាបានបង្កើតឡើងនូវការវិវត្តដ៏គួរឲ្យកត់សម្គាល់ ឆ្ពោះទៅរកការផ្សះផ្សាជាតិ ការបងចាំ និងយុត្តិធម៌ ។ ការវិវត្តនេះគឺមិនងាយស្រួលនោះទេ កុំថាឡើយមិនឲ្យមានកំហុសឆ្គង ។ ហេតុនេះហើយបានជាប្រទេសភូមាគួរតែងាកមកមើលកម្ពុជា មិនត្រឹមតែលើដំណោះស្រាយបញ្ហាដែលកំពុងកើតឡើងតែប៉ុណ្ណោះនេះទេ ប៉ុន្តែក៏ទៅលើមេរៀនដែលកម្ពុជាបាន រៀនសូត្ររួចមកហើយដែរ ។

ខ្ញុំមានភាពជិតស្និទ្ធជាមួយប្រទេសភូមា ទាំងផ្នែកជាតិពន្ធុ និងប្រវត្តិសាស្ត្រ ។ ក្នុងនាមជាខ្មែរមួយរូប ខ្ញុំមានខ្សែស្រឡាយជាប់ទៅនឹងក្រុមជនជាតិខ្មែរមននៅក្នុងប្រវត្តិសាស្ត្ររបស់យើង ។ ខ្ញុំធំដឹងក្តីឡើងជាមួយនឹងអត្តសញ្ញាណនៃជនជាតិនេះ ហើយក៏ត្រូវបានរំពុកដោយគ្រួសាររបស់ខ្ញុំ និងប្រវត្តិសាស្ត្រកម្ពុជាដែរ ។ ខ្ញុំមានអារម្មណ៍ចូលចិត្តប្រទេសនេះជាខ្លាំងនៅពេលដែលខ្ញុំបានទៅធ្វើទស្សនកិច្ចនៅទីនោះអស់ជាច្រើនដង វាហាក់ដូចជាខ្ញុំបានផ្សារភ្ជាប់ជាថ្មីជាមួយនឹងប្រវត្តិសាស្ត្រនៃកំណើតរបស់ខ្ញុំ ។ ខ្ញុំអាចស្រមៃឃើញថា ខ្ញុំមិនមានភាពប្លែកពីជនជាតិខ្មែរដទៃទៀតដែលបានទៅធ្វើទស្សនកិច្ចប្រទេសភូមា នោះទេ ហើយពេលនោះខ្ញុំក៏សួរខ្លួនឯងថា «តើខ្ញុំមានរូបរាងដូចជនជាតិមននៅក្នុងប្រទេសភូមាឬទេ?» ខ្ញុំពិតជាដូចមែន ។

ជនជាតិកម្ពុជា និងជនជាតិភូមាភាគច្រើន នឹងមានភាពភ្ញាក់ផ្អើលចំពោះអ្វីដែលខ្លួនមានបទពិសោធន៍ រួមគ្នា ក៏ដូចជា វប្បធម៌ដែរ ។ ប្រទេសទាំងពីរមានជនភៀសខ្លួនទៅកាន់ប្រទេសថៃដូចគ្នា ។ នៅក្នុងប្រទេសថៃនេះហើយដែលខ្ញុំបានជួបជាមួយនឹងមិត្តភក្តិជនជាតិភូមាជាលើកដំបូងរបស់ខ្ញុំដែលមានឈ្មោះថា មួងដុង ។ យើងទាំងពីរមានរឿងរ៉ាវជាច្រើនដូចគ្នា ដែលអាចឲ្យយើងក្លាយទៅជាបងប្អូន ។ ដូចគ្នាទៅនឹងបងប្អូនប្រវត្តិសាស្ត្រដែរ ប្រទេសកម្ពុជា និងប្រទេសភូមាឆ្លងកាត់នូវសង្គ្រាមដ៏ខ្លោចផ្សា អំពើហិង្សា និងការគាបសង្កត់ដូចគ្នា ។

ក្នុងអំឡុងរបបខ្មែរក្រហម ខ្ញុំត្រូវបានខ្មែរក្រហមឃុំឃាំងនៅក្នុងគុកនៅពេលដែលខ្ញុំមានអាយុទើបតែ១៥ឆ្នាំ ។ បទពិសោធន៍ដ៏ឈឺចាប់បំផុតរបស់ខ្ញុំ គឺការចងចាំនូវការវាយដំដ៏ឃោរឃៅដោយឈ្លបខ្មែរក្រហមក្នុងអំឡុងពេលនោះ ។ ខ្ញុំជឿថា ម្តាយរបស់ខ្ញុំស្ថិតនៅក្នុងហ្វូងនៃ «តុលាការប្រជាជនរបស់ខ្មែរក្រហម» នេះ ហើយខ្ញុំក៏ជឿថា គាត់កំពុងមើលមកខ្ញុំនៅអំឡុងពេលដ៏ខ្លោចផ្សានោះ ។ វាពិតជាឈឺចាប់ណាស់សម្រាប់ខ្ញុំ នៅពេលដែលខ្ញុំគិតដូច្នេះ ស្របពេលដែលខ្ញុំកំពុងទទួលរងទារុណកម្មពីសំណាក់ឈ្លបខ្មែរក្រហម ម្តាយរបស់ខ្ញុំជ្រើសរើសមិនចេញមកការពារខ្ញុំ ឬយ៉ាងហោចណាស់សុំអង្វរឲ្យកងឈ្លបទាំងនោះលើកលែងទោសដល់ខ្ញុំ ។ «បទឧក្រិដ្ឋ» ដែលខ្ញុំបានប្រព្រឹត្ត ប្រហែលជាអាចនឹងមិនធ្ងន់ធ្ងរ ក៏ប៉ុន្តែនៅពេលនោះ បទឧក្រិដ្ឋទាំងនេះត្រូវបានខ្មែរក្រហមចាត់ទុកថាធ្ងន់ធ្ងរ ដែលគួរតែទទួលទោសដល់ស្លាប់ ។ ខ្ញុំត្រូវបានខ្មែរក្រហមចាប់ខ្លួននៅពេលដែលខ្ញុំកំពុងបេះផ្សិត និងរើសគួរស្រូវទៅចិញ្ចឹមបងស្រីរបស់ខ្ញុំម្នាក់ ។ បងស្រីខ្ញុំកំពុងតែពពោះនៅពេលនោះ ដោយពុំមានចំណីអាហារគ្រប់គ្រាន់ គាត់ទទួលរងនូវការអត់ឃ្លានយ៉ាងខ្លាំង ។ ដោយពុំមានការអនុញ្ញាតពីសំណាក់មេកង ខ្ញុំបានព្យាយាមរកផ្សិតខ្លះៗពីវាលស្រែទុកសម្រាប់គាត់ ។ ខណៈពេលដែលខ្ញុំកំពុងខឹងនឹងឈ្លបខ្មែរក្រហមដែលវាយដំខ្ញុំ ខ្ញុំក៏មានការខឹងសម្បារចំពោះម្តាយខ្ញុំដែរ ។ ៣៥ឆ្នាំក្រោយមក ម្តាយខ្ញុំប្រាប់ខ្ញុំថា គាត់មិនបានស្ថិតនៅក្នុងហ្វូងមនុស្សដែលឈរមើលខ្ញុំទាំងនោះទេ ។ គាត់ប្រាប់ថា គាត់ដឹងថាខ្ញុំត្រូវបានឈ្លបខ្មែរក្រហមវាយដំ និងចាប់យកទៅដាក់គុកក្បែរនោះ ប៉ុន្តែគាត់បានទៅកាន់ទីកន្លែងធ្វើទារុណកម្មខ្ញុំនោះ ក្រោយហេតុការណ៍ដែលបានកើតឡើងរួចទៅហើយ ។

បទពិសោធន៍នេះបានកើតឡើងអស់ប្រមាណជាង ៣៥ឆ្នាំកន្លងមកហើយ ប៉ុន្តែវានៅតែបន្តបន្សល់នូវភាពល្អក់កករដល់ទំនាក់ទំនងក្នុងគ្រួសាររបស់យើង ដោយបង្កឲ្យមាននូវអារម្មណ៍ព្រះពោរ និងភាពតានតឹង ។ ទោះបីជាប្រជាជនកម្ពុជាភាគច្រើនបានរស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ក៏ពិតមែន តែបទ

ពិសោធន៍នេះនៅតែបន្តផលប៉ះពាល់ទៅលើគ្រួសារ សហគមន៍ និង ប្រទេសជាតិទាំងមូលក្នុងទម្រង់មួយដែលមិនអាចពិពណ៌នាបាន និងដោយប្រយោល ។ ជួនកាល របួសដែលជាសះនៅខាងក្នុង អាចនឹងឈឺចាប់ជាងរបួសផ្នែកខាងក្រៅ ។ រយៈពេល៣៥ឆ្នាំនេះ អាចធ្វើឲ្យសះស្បើយលើរបួសស្នាមផ្លូវកាយរបស់ប្រជាជនកម្ពុជា ប៉ុន្តែរបួសស្នាមផ្នែកខាងក្នុង និងអរូបីយ គឺជារបួសដែលបង្កើតនូវផលប៉ះពាល់ដ៏ធំធេងដល់ការតស៊ូឆ្ពោះទៅមុខរបស់សង្គមកម្ពុជា ។

ខ្ញុំបានជួបជាមួយនឹងមនុស្សដ៏ល្អជាច្រើននៅក្នុងប្រទេសភូមា ដូចជា ជិត មិនឡាយ កាលពីប៉ុន្មានឆ្នាំមុន ហើយខ្ញុំក៏បានប្រទះឃើញនូវរបួសស្នាមអស់ទាំងនេះដែរ ។ ដោយត្រូវបានឃុំឃាំងដោយសារ «បទឧក្រិដ្ឋ» នយោបាយ មនុស្សជាច្រើននៅក្នុងប្រទេសភូមាចំណាយពេលដ៏ប្រសើរបំផុតនៃជីវិតរបស់ខ្លួននៅក្នុងគុក ។ មនុស្សមួយចំនួនក៏បានទទួលរងនូវទារុណកម្ម និងស្នាមរបួសផ្លូវកាយដែលបញ្ជាក់ពីការឈឺចាប់ដ៏ធ្ងន់ធ្ងររបស់គេ ។ ទោះបីជាយ៉ាងណាក្តី ស្នាមរបួសខាងក្នុងជាកត្តាបង្កនូវការឈឺចាប់ខ្លាំងក្លាចំពោះបុគ្គល និងសង្គម ។ អតីតអ្នកទោសជាច្រើនព្យាយាមយ៉ាងមោះមុតក្នុងការផ្សារភ្ជាប់ខ្លួនជាថ្មីជាមួយនឹងគ្រួសារ ។ ជីវិតត្រូវស្ថិតនៅខ្ទាត់ខ្ទាយ ហើយសម្ព័ន្ធភាពគ្រួសារតែងតែត្រូវបានបំផ្លាញ ។

ដូចគ្នានេះដែរ ទំនាស់ជាតិពន្ធុ និងសាសនានៅតែបន្តនៅក្នុងប្រទេសភូមា ។ ប្រជាជនជាច្រើនក្នុងប្រទេសភូមានៅតែបន្តទទួលរងនូវការរើសអើង ការគាបសង្កត់ និងការគំរាមកំហែងដោយហិង្សា ចំពោះការតស៊ូដែលឈរលើមូលដ្ឋានរបស់ជាតិ ជាតិពន្ធុ និងសាសនា ដាច់ដោយឡែកពីគ្នា ។ ដូចគ្នានឹងប្រទេសកម្ពុជាក្នុងអំឡុងរបបខ្មែរក្រហមដែរ ទស្សនៈនៃភាពខុសគ្នានៅតែបន្តគ្របលើចំណុចរួមរបស់មនុស្សជាតិ ។ វាពុំមានការលើកលែងទេ ។

ទស្សនៈនៃភាពខុសគ្នាមិនចាំបាច់ឈានដល់ដំណាក់កាលបែងចែករវាង «ពួកយើង និង ពួកគេ» នោះទេ ។ ផ្ទុយទៅវិញ វាគួរតែមានការយល់ឃើញរួម និងការពេញចិត្តចំពោះភាពខុសប្លែកគ្នា ដែលជាធាតុផ្សំដ៏សំខាន់មួយនៃប្រជាធិបតេយ្យដ៏ជោគជ័យ ។ វាគឺជាកម្លាំងជំរុញនៃអារ្យធម៌ទំនើបមួយ ។ ប្រទេសភូមាអាចក្លាយជាប្រទេសជាតិមួយដ៏ពេញលេញ ដរាបណាប្រទេសនេះទទួលស្គាល់នូវតម្លៃ និងអនាគតរបស់ប្រទេសខ្លួនផ្សារភ្ជាប់ ដោយផ្ទាល់ទៅនឹងកម្រិតដែលប្រទេសអាចគ្រប់គ្រងនូវការចូលរួម ទាំងស្រុងនៃប្រជាជនទាំងមូល ។ ប្រទេសដែលប្រានចោល (ឬជាន់ឈ្លី) ជនជាតិភាគតិចរបស់ខ្លួន គឺកំពុងជួញដូរសក្តានុពលរបស់ប្រទេសខ្លួនជាមួយតែនឹងសុវត្ថិភាព សម្រាប់ប្រជាជនភាគច្រើន ឬ អ្នកធំ ដែលមានអំណាច និងទ្រព្យសម្បត្តិ ។ អ្វីដែលកាន់តែលំបាកជាងនេះទៅទៀត គឺគេកំពុងតែធ្វើការភ្នាល់គ្នានូវជោគវាសនាប្រទេសរបស់ខ្លួន ។

ខណៈដែលប្រទេសកម្ពុជា បានកសាងនូវការវិវត្តដ៏គួរឲ្យកត់សម្គាល់លើការអភិវឌ្ឍក្រោយជម្លោះរបស់ខ្លួន ប្រទេសនេះក៏បានប្រព្រឹត្តនូវកំហុសឆ្គងជាច្រើនដែលប្រទេសដទៃទៀតគួរតែធ្វើការស្វែងយល់ ។ កម្ពុជាបានចំណាយពេលជាង៣៥ឆ្នាំ ចាប់តាំងពីការដួលរលំនៃរបបខ្មែរក្រហមដើម្បីគ្រប់គ្រងលើភាពភ័យខ្លាចនៃប្រវត្តិសាស្ត្ររបស់ខ្លួន ។ ទោះបីជាជញ្ជាំងគុកដែលបានកសាងដោយខ្មែរក្រហម ត្រូវបានផ្តួលរំលំដោយពេលវេលា និងការអភិវឌ្ឍក្តី ជួនកាលជញ្ជាំងដែលធំធេងជាងនេះ មិនប្រាកដថា ជាជញ្ជាំងដែលមានរូបរាងនោះទេ ។ វាសំដៅលើជញ្ជាំងដែលស្ថិតនៅនៅក្នុងចិត្តរបស់យើង ដែលលេចឡើងតាមរយៈការគាបសង្កត់ ការរើសអើង ការភ័យខ្លាច អំពើហិង្សា និងអំពើឃោរឃៅដែលមានជាច្រើនឆ្នាំ ហើយទាមទារឲ្យមានការយកចិត្តទុកដាក់ខ្ពស់បំផុតរបស់យើង ។ នៅពេលដែលប្រទេសមួយរង់ចាំដើម្បីប្រឆាំងនឹងជញ្ជាំងនេះកាន់តែយូរ ប្រទេសនោះនឹងតម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែងកាន់តែខ្លាំងដើម្បីជម្នះវា ។ កម្ពុជាគឺជាមេរៀនមួយក្នុងប្រវត្តិសាស្ត្រ តែវាមិនមែនស្ថិតនៅតែឯកឯងទេ ។ មជ្ឈិមបូព៌ា អាហ្វ្រិក និងសូម្បីតែសហរដ្ឋអាមេរិក គឺសុទ្ធសឹងជាឧទាហរណ៍ពីការតស៊ូប្រឹងប្រែង ដែលកើតមាននៅពេលដែលប្រទេសនានាទទួលបរាជ័យក្នុងការជម្នះនូវបញ្ហា ឬទស្សនៈនៃភាពខុសគ្នារបស់ខ្លួន ។

ប្រទេសភូមាកំពុងស្ថិតក្នុងកាលៈទេសៈអំណោយផលមួយក្នុងការឆ្ពោះទៅមុខ និងធ្វើការសិក្សាពីបទពិសោធន៍របស់កម្ពុជា ។ ក្នុងនាមជាបងប្អូនប្រវត្តិសាស្ត្រ ប្រទេសភូមា និងកម្ពុជាមានអ្វីៗជាច្រើន ដែលត្រូវសិក្សាពីគ្នាទៅវិញទៅមក ហើយប្រទេសភូមានឹងមិនចាំបាច់ឆ្លងកាត់នូវការតស៊ូដ៏យូរអង្វែង ដែលបងប្អូនកម្ពុជារបស់ខ្លួនបានជួបប្រទះនោះទេ ។ **ឆាំង យុ**

# ចងចាំអំពីគោលនយោបាយយេនឌ័រហួសហេតុរបស់ អៀង ធីរិទ្ធ

អៀង ធីរិទ្ធ គឺជារដ្ឋមន្ត្រីសង្គមកិច្ចក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងជាជនជាប់ចោទក្នុងសំណុំរឿង០០២ ដែលត្រូវបានដោះលែងឲ្យនៅក្រៅឃុំដោយសារតែជំងឺវង្វេងវង្វាន់ស្មារតីរបស់គាត់ បានស្លាប់កាលពីថ្ងៃសៅរ៍ ទី២២ ខែសីហា ។ គាត់បានស្លាប់ដោយពុំបានប្រឈមមុខនឹងយុត្តិធម៌ ក៏ប៉ុន្តែយើងមិនគួរឲ្យរឿងរ៉ាវនេះកន្លងទៅយ៉ាងដូច្នេះដែរ ។ យើងគួរតែចងចាំនូវគោលនយោបាយ ដែលបង្កវិនាសកម្មរបស់គាត់ ជាពិសេសគឺគោលនយោបាយយេនឌ័រ ក្នុងអំឡុងពេលគាត់កាន់តំណែងជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ។

អៀង ធីរិទ្ធ បានទៅសិក្សានៅប្រទេសបារាំង ហើយបានត្រឡប់មកកាន់ប្រទេសកម្ពុជាវិញនៅក្នុងឆ្នាំ១៩៥៧ ជាមួយនឹងប្តីរបស់គាត់ ព្រមទាំងមេដឹកនាំកុម្មុយនីស្តដទៃទៀត ។ គាត់គឺជាសាស្ត្រាចារ្យមួយរូបនៅមុនពេលដែលគាត់កាន់ដំណែងជារដ្ឋមន្ត្រីសង្គមកិច្ច ។ ប្តីរបស់គាត់ គឺ អៀង សារី ដែលជាជនជាប់ចោទក្នុងសំណុំរឿងជាមួយគ្នានេះ គឺជារដ្ឋមន្ត្រីការបរទេស ។ អៀង សារី បានស្លាប់នៅក្នុងឆ្នាំ២០១៣ ។ អៀង ធីរិទ្ធ គឺជាស្ត្រីមួយរូបក្នុងចំណោមស្ត្រីដែលកាន់ដំណែងកំពូលមួយចំនួនទៀតដែលមានឥទ្ធិពលក្នុងអំឡុងរបបកុម្មុយនីស្ត ។ ស្ត្រីដទៃទៀតដែលស្ថិតក្នុងជួរដឹកនាំជាន់ខ្ពស់ រួមមាន ខៀវ ប៉ុណ្ណារី ជាបងស្រីរបស់គាត់ និងជាប្រពន្ធរបស់ ប៉ុល ពត ដែលជាអ្នកបង្កើតសមាគមស្ត្រី និង យ៉ុន យ៉ាត ជាប្រពន្ធរបស់ សុន សេន ។

បន្ទាស់ប្តូរគ្រួសារ គឺជាគោលនយោបាយមួយក្នុងចំណោម



អៀង ធីរិទ្ធ អតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ជួបជាមួយគណៈប្រតិភូបរទេស នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

គោលនយោបាយដ៏ហួសហេតុរបស់គាត់ ដោយគាត់បានអះអាងថា គោលនយោបាយនេះនឹងរំដោះស្ត្រីចេញពីការគាបសង្កត់ ។ គោលនយោបាយយេនឌ័រនេះបានធ្វើការសង្កត់ធ្ងន់ទៅលើសមភាពនិងភាពជាម្ចាស់ការសម្រាប់ភេទទាំងពីរ ។ អៀង ធីរិទ្ធ បាននិយាយក្តែងៗថា ស្ត្រីស្ថិតក្នុងរបបរបស់គាត់ គឺគ្រាន់តែធ្វើការងារហើយត្រឡប់មកផ្ទះ និងបរិភោគអាហារប៉ុណ្ណោះ ។ ស្ត្រីទាំងនោះមិនចាំបាច់ចម្អិនម្ហូបអាហារ ឬធ្វើការងារផ្ទះអ្វីឡើយ ។ ដូចដែលបានដកស្រង់ចេញពីសៀវភៅរបស់ អេលីហ្សាប៊ែត បេកក័រ ដែលមានចំណងជើងថា «នៅពេលដែលសង្គ្រាមផុតរលត់ទៅៈ ប្រទេសកម្ពុជា និងបដិវត្តន៍របស់ខ្មែរក្រហម» ៈ «ដំបូងឡើយ ស្ត្រីត្រូវធ្វើការត្រឡប់មកផ្ទះ និងរកត្រី អង្ករ សម្រាប់ចម្អិន និងមើលថែទាំកូនចៅ» ។ វាពិតជាអាក្រក់ខ្លាំងណាស់ ។ នៅក្នុងការរស់នៅជាសមូហភាព ស្ត្រីគ្រាន់តែធ្វើការហើយត្រឡប់មកផ្ទះ និងបរិភោគអាហារប៉ុណ្ណោះ» ។ ហេតុនេះ ស្ត្រីទាំងនោះមិនចាំបាច់ជំពាក់ជំពិនជាមួយកូនចៅ និងគ្រួសារខ្លួនទេ ។ ជាលទ្ធផល ស្ត្រីនៅលីវត្រូវបានបំបែកចេញពីឪពុកម្តាយរបស់ខ្លួន ។ ស្ត្រីដែលរៀបការរួចត្រូវបានបំបែកចេញពីប្តី និងកូនរបស់ខ្លួន ។ ការឈប់សម្រាកលំហែមាតុភាពមានការដាក់កំហិតជាខ្លាំង ។ ការឈប់សម្រាកនេះខុសប្លែកគ្នាពីតំបន់មួយទៅតំបន់មួយទៀត ។ រយៈពេលវែងបំផុតសម្រាប់ការឈប់សម្រាកលំហែមាតុភាព គឺប្រហែលមួយខែ ហើយរយៈពេលខ្លីបំផុតមានត្រឹមតែមួយឬពីរសប្តាហ៍ប៉ុណ្ណោះ ។ អ្វីដែលយ៉ាប់យឺនជាងនេះ គឺស្ត្រីដែលមានផ្ទៃពោះទទួលបានការថែទាំផ្នែកវេជ្ជសាស្ត្រ និងអាហារូបត្ថម្ភតិចតួចបំផុត ហើយស្ត្រីទាំងនោះនៅតែត្រូវធ្វើការងារក្នុងកម្រិតជាក់លាក់មួយ ក្នុងអំឡុងពេលពពោះ ឬក្រោយពេលសម្រាលកូនរួច ។

សមភាព បើតាមនិយមន័យរបស់គាត់ គឺសំដៅទៅលើកម្លាំងកាយ និងស្មារតីបដិវត្តន៍ មិនមែនសំដៅទៅលើតម្លៃនៃភាពជាស្ត្រីទេ ។ ស្ត្រីត្រូវបានបង្ខំឲ្យបំពេញការងារដូចគ្នានឹងបុរស ។ ការខិតខំបំពេញការងារ និងការពលីមិនបានផ្តល់ឲ្យនូវប្រយោជន៍ ឬឋានៈដល់ស្ត្រីនៅកម្រិតថ្នាក់ទាប និងមធ្យមទេ ។ នេះមិនមានន័យថា ស្ត្រីមិនអាចក្លាយជាឃាតករ ឬជនដៃដល់ក្នុងជំនាន់នោះទេ ។ មានឃាតករ និងជនដៃដល់ជាច្រើនជាស្ត្រី ដែលត្រូវបានបំពាក់បំប៉នដោយគោលនយោបាយយេនឌ័រ និងគោលនយោបាយខ្មែរក្រហមដទៃទៀត ។ ទោះបីជាយ៉ាងណាក្តី ស្ត្រីភាគច្រើនបានទទួលរងនូវកង្វះ ជីវជាតិ កង្វះការថែទាំសុខភាព និងត្រូវធ្វើការជាទម្ងន់ ។ ស្ត្រីជាច្រើនត្រូវបានសម្លាប់ ។ សុខភាពរបស់ស្ត្រីស្ថិតនៅជាបញ្ហាប្រឈមដ៏ចម្បងមួយបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមក្នុងឆ្នាំ១៩៧៩ ។


អៀង ធីរិទ្ធ នៅក្នុងបន្ទប់សវនាការនៃសាលាក្តីខ្មែរក្រហម

បើទោះជាមានភាពវិនាសកម្មទាំងអស់ទាំងនេះមែន អៀង ធីរិទ្ធ បានប្រានចោលនូវការទទួលខុសត្រូវរបស់ខ្លួន ៈ «ខ្ញុំមិនដឹងថា ហេតុអ្វីបានជាមនុស្សល្អម្នាក់ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ហើយខ្ញុំបានទទួលរងនូវទុក្ខលំបាកជាច្រើន ។ ខ្ញុំមិនអាចអត់ធ្មត់បានទេ ព្រោះខ្ញុំត្រូវបានចោទប្រកាន់ដោយមិនសមស្រប» ។ ជនរងគ្រោះជាច្រើន ដែលភាគច្រើនជាស្ត្រីត្រូវបានបាត់បង់ជីវិតដោយពុំទាន់បានទទួលនូវយុត្តិធម៌ ។ ជនរងគ្រោះដែលនៅសេសសល់ នឹងនៅតែបន្តចងចាំនូវគោលនយោបាយរបស់ អៀង ធីរិទ្ធ ដែលបានបំបែកបំបាក់គ្រួសារ និងបានចូលរួមចំណែកបង្កឲ្យមានការបាត់បង់នូវជីវិតមនុស្សអស់ ជាង២លាននាក់ ។ **ស្វ ហ្វារីណា**

# ចម្លើយសារភាពរបស់ នូ អ៊ានឡេង ហៅ គល់ លេខាឃុំគោលាប់ ស្រុកក្រចេះ តំបន់៥០៥

***ដកស្រង់ចេញពីឯកសារចម្លើយសារភាព D២១២៧២***

នូ អ៊ានឡេង ហៅ គល់ ភេទប្រុស អាយុ៣៩ឆ្នាំ កើតនៅភូមិដីដុះ ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ តំបន់៥០៥ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គល់ មានតួនាទីជាលេខាឃុំគោលាប់ ស្រុកក្រចេះ ។ ប្រពន្ធឈ្មោះ ឈឹម ប៊ុនធី អតីតគ្រូបង្រៀននៅសាលាបឋមសិក្សាកញ្ជរ ស្រុកឆ្លូង ។ គល់ ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៨ និងបញ្ជូនខ្លួនមកឃុំឃាំងនៅមន្ទីរស-២១ ដើម្បីសួរចម្លើយ ។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបចម្លើយសារភាពរបស់គល់៖

ឆ្នាំ១៩៥៤ ក្រោយពីប្រឡងមធ្យមសិក្សាធ្លាក់ គល់ បានធ្វើការទាក់ទងឈ្មោះ ស្រៀង ឈាង ដែលជាសិស្សរៀននៅថ្នាក់ទី៥ នៃវិទ្យាល័យសីហនុ ។ ស្រៀង ឈាង មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសាស្ត្រាចារ្យម្នាក់នៅវិទ្យាល័យនេះឈ្មោះ ទីវ អុល ហៅ សោម (អង្គការចាប់ខ្លួនហើយ) ។ ជាបន្តបន្ទាប់ ឈាង បានអប់រំគល់ ឲ្យស្អប់របបកុម្មុយនីស្ត ហើយចូលចិត្តលោករបបសេរី ។ មួយរយៈក្រោយមក ឈាង ក៏បានបញ្ចូល គល់ ជាភ្នាក់ងារសេ.អ៊ី.អា ដែលមាន ទីវ អុល ជាអ្នកទទួលស្គាល់ ព្រមទាំងមានគោរពទង់ជាតិរបស់អាមេរិកផងនៅពេលនោះ ។ បន្ទាប់ពីបានក្លាយខ្លួនជាភ្នាក់ងារសេ.អ៊ី.អា រួចមក គល់ ត្រូវបាន ឈាង ណែនាំឲ្យស្គាល់ខ្សែ



រូបថតជនរងគ្រោះ ខ្នោះ និងឧបករណ៍ធ្វើទារុណ នៅមន្ទីរសន្តិសុខស-២១ ឬសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង

សេ.អ៊ី.អា មួយចំនួនមានឈ្មោះ តាំង ហុងលីម, ប៊ុល ផន, ភិន សារិន, តាំង គីមឡេង, បៃ កុសល, រូ គុនលីម, ម៉ក់ យាត, ជ័រ ឈឿង ផាយ ស្រួលទាក់ទងគ្នាធ្វើសកម្មភាពទៅថ្ងៃក្រោយ ។

ក្នុងអំឡុងពីឆ្នាំ១៩៥៥-១៩៥៩ គល់ បានប្រឡងជាប់មធ្យមសិក្សានៅក្រចេះ ប៉ុន្តែដោយគ្មានលុយកាក់គ្រប់គ្រាន់ ដើម្បីបន្តរៀនសូត្រនៅទីនេះបាន គល់ បានសម្រេចចិត្តទៅរៀននៅសាលារាជការឯក្រុងកំពង់ឆ្នាំងវិញ ហើយរក្សាការទាក់ទងជាមួយខ្សែរយៈ សេ.អ៊ី.អា ចាស់ដែល ។ បន្ទាប់មក ឈឿង បានខ្ទេសនាមឲ្យ គល់ ស្គាល់មនុស្សពីរនាក់ទៀតមានឈ្មោះ ប្រាក់ ផួនសេង និង សោម សាអ៊ុក ។ តាមរយៈអ្នកទាំងពីរបានណែនាំ គល់ ឲ្យទាក់ទងភ្ជាប់ខ្សែជាមួយឈ្មោះ ប្រាក់ ឈុំ គ្រូបង្ហាត់កីឡានៅកំពង់ឆ្នាំង, លី ហាំងជៀវ គ្រូបង្រៀន, អ៊ុក គ្រី សិស្សថ្នាក់ទី៦, តុប ទូច សិស្សថ្នាក់ទី៦, ប៉ែន ហុក ស្រេង សិស្សថ្នាក់ទី៦ មិនតែប៉ុណ្ណោះគល់ និង ឈឿង បានសហការគ្នា កសាងកម្លាំង សេ.អ៊ី.អា បានមួយចំនួនទៀតមានឈ្មោះ សោម ភណ្ឌុល, ប៉ែន ធួក, កែម សាផុន, ពិជ ស៊ីផួង, សាម៉េត, គីម ហ៊ាន, វ៉ា ក្រឹង ។

នៅចុងឆ្នាំ១៩៥៩ គល់ បានមករៀនច្បាប់គ្រូនៅសាលាអង្គអេងជាប់សាលាគរុកោសល្យខាងក្រោយស៊ីសុវត្ថិភ្នំពេញ ហើយបានជួប ឈាង និង ទីវ អុល ដែលជាសាស្ត្រាចារ្យត្រូវមកបង្រៀនច្បាប់គ្រូនៅសាលាគរុកោសល្យនេះដែរ ។ ពេលនោះ ទីវ អុល បានណែនាំឲ្យទាក់ទងខ្សែផ្សេងទៀត មានឈ្មោះ គិត សៅ សាស្ត្រាចារ្យវិទ្យាល័យក្រចេះ បច្ចុប្បន្នប្រធានក្រសួងសិក្សាអប់រំរបស់ (តំបន់៥០៥), អេង ប៊ុនហ៊ាង គ្រូបង្រៀនបច្ចុប្បន្នប្រធានក្រសួងដឹកជញ្ជូនតំបន់៥០៥ (អង្គការចាប់ខ្លួនហើយ), ពិជ ប៊ុនធិន គរុគ្រូនៅសាលាគរុកោសល្យ, គ្រួច ធួ គរុគ្រូនៅសាលាគរុកោសល្យ ភ្នំពេញ ។

ឆ្នាំ១៩៦០ គល់ កសាងកម្លាំងបានបីនាក់មានឈ្មោះ ឡេង ញ៉ិ (កម្មករកាប់ឈើនៅសំបុក និងជាគណៈសហករណ៍ភូមិក្បាលជួរ), គន់ (គណៈសហករណ៍ភូមិក្បាលជួរ) និង លីម សមាជិក ភូមិច្រុស ឃុំសំបុក ។ នៅចុងឆ្នាំ១៩៦១ គល់ បានទៅបង្រៀនសិស្សនៅសាលាបឋមសិក្សាក្រុង ក្រចេះ ។ កាលនោះ ឈាង បានណែនាំឲ្យទាក់ទងជាមួយ ចិត្ត គ្រូបង្រៀន (ឆ្នាំ១៩៧៧ ធ្វើជាគណៈចម្ការកៅស៊ូស្នួល), ប៉េង ហៅ កិច គ្រូបង្រៀន (បច្ចុប្បន្នសមាជិកវប្បធម៌តំបន់៥០៥), សាំង ចាន់ ឆោម គ្រូបង្រៀន, សៅ ពេញ គ្រូបង្រៀន (បច្ចុប្បន្នសមាជិកក្រសួងឧស្សាហកម្មតំបន់៥០៥), សុន សមាជិកសេដ្ឋកិច្ចស្រុកក្រចេះ), ព្រុំ ចំរើន (សមាជិកភូមិសំបុក ឃុំសំបុក), ជាង យាង ប្រធានការដ្ឋានស្រុកសំបូរ, គីម សមាជិកឃុំថ្មក្រែ ស្រុកក្រចេះ, ឡេន សមាជិកឃុំថ្មក្រែនៅឆ្នាំ ១៩៧៧, ជួន អនុលេខាឃុំថ្មក្រែ ស្រុកក្រចេះ, និន ខាំភាន គ្រូបង្រៀនជនជាតិលាវ ។

ឆ្នាំ១៩៦៤-១៩៧០ គល់ បានទៅបង្រៀននៅសាលាកញ្ជរ ស្រុកឆ្លូង ។ មួយឆ្នាំក្រោយមក បានផ្លាស់មកបង្រៀនសិស្សនៅអនុវិទ្យាល័យឆ្លូងវិញ ហើយបានភ្ជាប់ខ្សែជាមួយ ម៉េង លីម, ឈី ម៉េងហួយ, កោះ យាន, ឃួន វ៉ាន, សរិត សេងគ្រី, និង នូ សុខគាល់ ។ ខែតុលា ឆ្នាំ១៩៧០ គល់ បានមករៀនបច្ចេកទេសយោធានៅសំបុក ។ រៀនបាន១៥ថ្ងៃ ក៏បានទៅធ្វើខាងក្រុមសំណង់នៅ បុសប្រហោងវិញ និងមានតួនាទីជាប្រធានក្រុម ទន្ទឹមនឹងនោះដែរ គុល កសាងកម្លាំង សេ.អ៊ី.អា បានពីរនាក់មានឈ្មោះ សុខ យុទ្ធជនស្លថ្នាំពេទ្យនៅតំបន់៥០៥ និងឈ្មោះ ជា (ស្លាប់) ។

ឆ្នាំ១៩៧១ គល់ បានចូលរួមក្នុងរាត្រីប្រឡងសិល្បៈនៅតំបន់៥០៥ ស្ថិតនៅក្នុងភូមិក្រសាំង ឃុំថ្មី ហើយបានជួបជុំបក្ខពួកមួយចំនួនដែលជាខ្សែរយៈចាស់ និងបានពិភាក្សាអំពីផែនការដែលត្រូវយកមកអនុវត្ត និងវិធីសាស្ត្រផ្សេងៗក្នុងការទាក់ទងខ្សែសផ្ទាក់នៅតាមកន្លែងនីមួយៗ ។ ពីរខែក្រោយមក គល់ ត្រូវបានអង្គការចាត់តាំងឲ្យធ្វើជាកម្មាភិបាលឃោសនាអប់រំនៅឃុំថ្មី ស្រុកក្រចេះ ។ បន្ទាប់មក អ៊ី បានណែនាំឲ្យទាក់ទងឈ្មោះ យ៉ូន សមាជិកសេដ្ឋកិច្ចតំបន់៥០៥, ពិន សេងវ៉ិន ហៅ យឹម លេខាឃុំថ្មី និងសមាជិក សេ.អ៊ី.អា ជាច្រើននាក់ទៀត ។

ខែសីហា ឆ្នាំ១៩៧២ គល់ ត្រូវបានអង្គការចាត់តាំងឲ្យធ្វើជាសមាជិកគណៈកម្មករលើសែង ក្រុងក្រចេះ តំបន់៥០៥ ។ ទីនោះ គល់ បានទាក់ទងភ្ជាប់ខ្សែជាមួយ គិត សៅ ហើយ គិតសៅ បានខ្ទេសនាមឲ្យទាក់ទងខ្សែរយៈផ្សេងទៀតមានឈ្មោះ ឆន ហៅ ព្រៃ សមាជិកភូមិសាមគ្គី ឃុំចង្ក្រង់ ស្រុកក្រចេះ, សែម សាន ហៅ ប៉ោង ប្រធានភូមិសរិត ឃុំគោលាប់ និងធ្វើជាលេខាឃុំ សំបុកនៅខែមករា ឆ្នាំ១៩៧៤ ។

ខែមិថុនា ឆ្នាំ១៩៧៥ យី បានហៅ គល់ និងកម្មាភិបាលក្នុង

ស្រុកក្រចេះចូលរួមប្រជុំ នៅមន្ទីរជ-៤ ស្ថិតនៅក្នុងឃុំជា ដើម្បីដាក់ផែនការសម្រាប់អនុវត្ត ។ សមាជិកដែលបានចូលរួមនៅពេលនោះ មានឈ្មោះ នា លេខាឃុំថ្មគ្រែ, សុន លេខាឃុំរកាកណ្តាល, គិត សៅ លេខាឃុំថ្មអណ្តើក, សាត ប្រធានសេដ្ឋកិច្ចស្រុកក្រចេះ, ញ៉ែម ពុន ប្រធានសុខាភិបាលស្រុកក្រចេះ, ហ៊ឹម ប្រធានយោធាស្រុកក្រចេះ, រស់ អនុលេខាស្រុកក្រចេះ, នារី រឿន លេខាឃុំក្រគរ (ស្លាប់), ដែក លេខា ឃុំជា, ផែន លេខាឃុំសណ្តាយ, វ៉ាង លេខាឃុំកន្ទួត, ផៃ អនុលេខាឃុំថ្មអណ្តើក, ពិន សេងវ៉ន ហៅ ឃឹម លេខាឃុំថ្មី, យាន លេខាឃុំបន្ទុង, សំ លេខាឃុំសំបុក, សាក សមាជិកស្រុកក្រចេះ (ចាប់ខ្លួនហើយ), នារី លាប សមាជិកស្រុកក្រចេះ (ចាប់ខ្លួនហើយ), ផល សមាជិកស្រុកក្រចេះ (ចាប់ខ្លួនហើយ), ម៉ែន សមាជិកស្រុកក្រចេះ ។ ក្រោយពីខទ្វេសនាមឲ្យស្គាល់គ្នាហើយ ឃី បានលើកពីខ្លឹមសារនៃផែនការសម្រាប់អនុវត្តមានបីចំណុចគឺ ទី១ បំផ្លាញនយោបាយរបស់បក្សដោយបំភ្លៃមាគ៌ា បីគោនក្នុងមួយហិកតា និងបង្អត់បាយប្រជាជន, ទី២ កសាងកម្លាំង សេ.អ៊ី.អា ប្រមូលអ្នក១៧ មេសា ដែលមាននិន្នាការជាប់ជាទាហាន ប៉ូលីសរដ្ឋការពីសង្គមចាស់ បញ្ចូលអ្នកទាំងអស់នោះទៅក្នុងឈ្លប-យោធាស្រុក ហើយឲ្យមានតួនាទីដឹកនាំនៅក្នុងក្រុម ចំណែកកម្មាភិបាលបដិវត្តន៍មិនត្រូវបានជ្រើសរើសឲ្យធ្វើជាអ្នកដឹកនាំឡើយ, ទី៣ បំបិទវប្បធម៌នយោបាយបដិវត្តន៍ វិទ្យុ កាសែត ឯកសារ ទស្សនាវដ្តី មិនឲ្យប្រជាជនមហាជនស្តាប់ឬក៏អានឡើយ ជាហេតុធ្វើឲ្យប្រជាជនខ្វះការយល់ដឹងផងដឹតផងុល មិនយល់ពីមាគ៌ានយោបាយរបស់បក្ស និងបំផុសវប្បធម៌របស់ចក្រពត្តិឲ្យជ្រាបចូលជ្រៅពេញក្នុងស្រទាប់ប្រជាជន ។ ក្រោយពីប្រជុំចប់ គល់ បាននាំយកផែនការទាំងនេះ ទៅដាក់ឲ្យបក្ខពួករបស់ខ្លួនអនុវត្តជាបន្តបន្ទាប់ ។ ស្របពេលជាមួយគ្នានេះដែរ គល់ កសាងកម្លាំងបានបីនាក់បន្ថែមទៀតមាន ឈ្មោះ ណៃម ខេង, ចាន់ លី និង ឡាំ ធឿន ។

ឆ្នាំ១៩៧៦ គល់ បានដឹកនាំខ្សែរយៈ សេ.អ៊ី.អា របស់ខ្លួនទាំងអស់ឲ្យធ្វើសកម្មភាពក្នុងការបំភ្លៃមាគ៌ាធ្វើស្រែរបស់បក្ស ។ កន្លែងគ្មានទឹកមិនឲ្យប្រជាជនជីកប្រឡាយ ស្រូវស្រាលយកទៅស្ទូងនៅស្រែក្រោម រីឯស្រូវធ្ងន់ស្ទូងនៅស្រែលើជាដើម ។ ខែធ្វើស្រែដឹកនាំប្រជាជនទៅកាប់ព្រៃធ្វើចម្ការ កម្លាំងត្រូវបានដកចុះដកឡើងទីបំផុតចម្ការក៏ធ្វើមិនបានរួចរាល់ ទំនប់ ប្រឡាយក៏ជីកមិនបានសម្រេចតាមផែនការរបស់បក្ស ដល់ខែធ្វើស្រែគ្មានទឹកស្រោចស្រប់គ្រាប់គ្រាន់ ជាហេតុធ្វើឲ្យទិន្នផលស្រូវបានតិច ជីវភាពរបស់ប្រជាជនជួបការលំបាក ហូបមិនគ្រប់គ្រាន់ មិនសម្បូរសប្បាយ ។ បំផុសចលនាប្រជាជនឲ្យវាយប្រហាររបបសមូហភាពរបស់បក្សការហូបចុកមិនឆ្អែត មិនគ្រាប់គ្រាន់ ហើយធ្វើការងារច្រើនទៀត ។ ក្រៅពីនេះ បក្ខពួករបស់ គល់ បានកៀរគរប្រមូលប្រជាជនដែលមានសមាសភាព ជាទាហាន ជាមន្ត្រីរដ្ឋការពីសង្គមចាស់ ដើម្បីកសាងជាកម្លាំងដើម្បីប្រឆាំងនឹងបដិវត្តន៍ ។

ឆ្នាំ១៩៧៧ ឃី បានដឹកនាំការប្រជុំមួយដែលអ្នកចូលរួមមានឈ្មោះ គល់, អុល, សែម សាន ហៅ ប៉េាង និង នារី រុម ដើម្បីដាក់ផែនការមួយចំនួនឲ្យអនុវត្តដូចជា រៀបចំផ្ទះសម្រាប់ដាក់ទូលេខដាក់សម្ភារប្រើប្រាស់មួយចំនួន និងរៀបចំឃុំគោលាប់ ឲ្យទៅជាមូលដ្ឋានបង្អែករបស់ សេ.អ៊ី.អា សម្រាប់វាយបក្សកុម្មុយនីស្តកម្ពុជានៅថ្ងៃខាងមុខ ។ ទន្ទឹមនឹងការរៀបចំមូលដ្ឋានបង្អែកឲ្យបានរឹងមាំហើយ ត្រូវកសាងកម្លាំងឈ្លបរបស់ឃុំ សម្រាប់ការពារមូលដ្ឋាន ដោយជ្រើសរើសយកអ្នកដែលជាប់និន្នាការនយោបាយពីសង្គមចាស់ ជាទាហាន ជាប៉ូលីស និងជាមន្ត្រីរដ្ឋការជាដើម ។ ត្រូវកសាង ពង្រឹង និងពង្រីកកម្មាភិបាលសម្រាប់ដឹកនាំមូលដ្ឋាន ត្រូវប្រមូលទុកដាក់ស្បៀងដូចជាស្រូវ អង្ករ សម្រាប់ឧបត្ថម្ភដល់កម្លាំងមូលដ្ឋានរបស់ សេ.អ៊ី.អា ឲ្យបានគ្រប់គ្រាន់ ត្រូវអប់រំពង្រឹង និងពង្រីកកម្លាំងនៅក្នុងមូលដ្ឋានឲ្យបានរឹងមាំ ។ ខាងគមនាគមន៍ត្រូវជួសជុលកែលម្អផ្លូវឲ្យបានស្អាត ដើម្បីងាយស្រួលដល់ការបើកបរដឹកសម្ភារចេញចូល ។ ផ្នែកសង្គមកិច្ច និងសុខាភិបាល ត្រូវពង្រីកសម្រាប់បម្រើមូលដ្ឋាន សេ.អ៊ី.អា ។ ចំណែកខាងនយោបាយវិញ ត្រូវធ្វើការឃោសនាអប់រំប្រជាជន មហាជនឲ្យយល់ជ្រួតជ្រាបពីគោលជំហរ និងបំណងរបស់ចលនា សេ.អ៊ី.អា ។ ក្រោយពីបានទទួលផែនការហើយ គល់ បានយកខ្លឹមសារនៃផែនការខាងលើមកណែនាំ ពន្យល់ដល់បក្ខពួករបស់ខ្លួន ដើម្បីអនុវត្តភារកិច្ចកសាងមូលដ្ឋានបង្អែកឲ្យបានរឹងមាំ និងជោគជ័យ ។

ខែមេសា ឆ្នាំ១៩៧៧ គល់ និងបក្សពួកនៅតាមមូលដ្ឋានភូមិឃុំ បានសហការគ្នាកសាងកម្លាំងសម្រាប់រៀបចំអង្គភាពឈ្លប

ការពារមូលដ្ឋានបានចំនួន១៥នាក់ ។ កម្លាំងទាំងអស់នេះ គល់ បានដាក់បញ្ចូលជាមួយឈ្លបដែលមានស្រាប់ខ្លះ ហើយប្រគល់ឲ្យ អុល សមាជិកឃុំជាអ្នកទទួលខុសត្រូវ ។ ក្រៅពីសកម្មភាពប្រមូលកៀរគរកម្លាំង គល់ និងបក្ខពួកបានឃោសនាអប់រំណែនាំប្រជាជនជាហូរហែឲ្យយល់ពីទិសដៅ និងគោលបំណងរបស់ចលនា សេ.អ៊ី.អា ។ ចំណែកស្បៀងអាហារត្រូវដកទុកមួយចំនួនជាចាំបាច់ សម្រាប់ឧបត្ថម្ភសមរភូមិមុខ ត្រៀមទុកសម្រាប់ឧបត្ថម្ភដល់ចលនា សេ.អ៊ី.អា ពេលធ្វើរដ្ឋប្រហារនៅថ្ងៃខាងមុខ ។

ខែធ្នូឆ្នាំ១៩៧៧ គល់ បានទៅជួប ប៉ោង, ស៊ិន, អ៊ាង និង ផន នៅខាងពេទ្យ ហើយបានណែនាំអ្នកទាំងអស់គ្នាឲ្យបន្តធ្វើសកម្មភាពប្រឆាំងបក្សឲ្យបានខ្លាំងក្លាថែមទៀត ដោយប្រើមធ្យោបាយមិនឲ្យយកចិត្តទុកដាក់ព្យាបាលជំងឺជូនប្រជាជនសន្សំថ្នាំពេទ្យល្អៗឲ្យបានច្រើន ទុកសម្រាប់ទំនុបបម្រុងក្រុម សេ.អ៊ី.អា នៅពេលធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ ។ ពេលព្យាបាលជំងឺ ត្រូវធ្វើសកម្មភាពចាក់ថ្នាំសម្លាប់ប្រជាជន ធ្វើយ៉ាងណាឲ្យប្រជាជនលែងមានជំនឿទុកចិត្តមកលើបដិវត្តន៍ ។ ក្រោយពីបានធ្វើសេចក្តីណែនាំរួចមក បក្ខពួករបស់ គល់ បានចាក់ថ្នាំសម្លាប់អ្នកជំងឺស្លាប់អស់បីនាក់ ហើយបានលាក់ថ្នាំពេទ្យល្អៗ បានមួយចំនួនទុកសម្រាប់ឧបត្ថម្ភដល់ចលនា សេ.អ៊ី.អា ពេលចេញធ្វើសកម្មភាព ។

ខែមករា ឆ្នាំ១៩៧៨ ម៉ែន បានបើកការប្រជុំមួយនៅមន្ទីរស្រុកក្រចេះ ។ អ្នកដែលបានចូលរួមប្រជុំនៅពេលនោះមាន យី, ស៊ឹម, សាក់, សំ, យាន, នា, រឿន, ផុន, ធុន, ដៃ, វ៉ាន់, ដែក, ឃឹម, ដែន, សាក, ហ៊ឹម, ប៊ុន និង មីន ។ ក្រោយពីស្តាប់សេចក្តីរាយការណ៍ដ៏មានសារសំខាន់ របស់សមាជិកម្នាក់ៗរួចមក យី បាននិយាយថា "ភារកិច្ចរបស់យើងនៅមានច្រើនទៀតដែលត្រូវធ្វើ គឺផែនការធ្វើរដ្ឋប្រហារនៅក្នុងខែមេសា ឆ្នាំ១៩៧៨នេះ" ។ តាមគម្រោងផែនការ ខាងមូលដ្ឋានដែលនៅជិតផ្លូវជាតិលេខ១៣ ត្រូវប្រញាប់យកស្រូវ អង្ករ ចេញពីសហករណ៍របស់ខ្លួន រកកន្លែងទុកដាក់ឲ្យបានគត់មត់ ដែលជាស្បៀងត្រៀមសម្រាប់ផ្គត់ផ្គង់កម្លាំងពេលធ្វើសកម្មភាព ចំណែកកម្លាំងរួមនៅមូលដ្ឋានត្រូវបន្តពង្រឹង និងពង្រីកថែមទៀត ហើយរៀបចំបំពាក់អាវុធឲ្យបានគ្រប់ដៃ ។ តាមមូលដ្ឋានឃុំនីមួយៗ ត្រូវពង្រីកកម្លាំងរបស់ខ្លួនឲ្យបានមួយអនុសេនាតូច សម្រាប់ធ្វើសកម្មភាពយោធានៅពេលធ្វើរដ្ឋប្រហារ ។ នៅក្នុងសហករណ៍ចាំបាច់ត្រូវកសាងឈ្លបក្នុងមួយសហករណ៍ឲ្យបានមួយក្រុមដើម្បីការពារមូលដ្ឋានសហករណ៍របស់ខ្លួន និងជួយជាកម្លាំងដល់ឈ្លបឃុំនៅពេលឈ្លបឃុំត្រូវការកម្លាំងជំនួយចាំបាច់ ។ កម្លាំងដឹកនាំនៅក្នុងសហករណ៍ស្មើមិត្តទាំងអស់យកចិត្តទុកដាក់អប់រំពង្រឹងឲ្យបានជាប់ជាប្រចាំ ឯបញ្ហាស្បៀងសព្វសារពើ ត្រូវត្រៀមឲ្យបានច្រើនដើម្បីឧបត្ថម្ភដល់កម្លាំងកងទ័ពរបស់យើង ។ ដោយឡែក ចំពោះមូលដ្ឋានឃុំគោលាប់ និងឃុំចង្រ្កង់ ត្រូវសហការគ្នាធ្វើការរួមគ្នាជ្រើសរើសរកទីតាំងមួយកន្លែងដែលមានភូមិសាស្ត្រស្ងប់ស្ងាត់ ដើម្បីសាងសង់ឃ្លាំងមួយសម្រាប់លាក់អាវុធចំនួន ១០ឡាន និងគ្រាប់ចំនួន២៥ឡាន ដែលអាវុធទាំងអស់នេះ បានមកពីខាងតំបន់ខ្លះ និងជំនួយរបស់វៀតណាមខ្លះ ។ ក្រៅពីនេះ យើងមានអំបិលចំនួន៣០តោន អង្ករចំនួន១៨០បាវ ប្រហុកចំនួន៣០តោន និងត្រីប្រឡាក់ប្រហែល៣០តោន ជារបស់ដែលបានឧបត្ថម្ភមកពីតំបន់ ក៏ត្រូវដឹកជញ្ជូនយកមកលាក់ទុកនៅទីនេះដែរ ហើយរបស់ទាំងអស់នេះយើងនឹងបានទទួលនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៨នេះ ដើម្បីត្រៀមទុកសម្រាប់បម្រើដល់ផែនការធ្វើរដ្ឋប្រហារនៅខែមេសា ឆ្នាំ១៩៧៨ ខាងមុខនេះ ។ម្យ៉ាងទៀត មូលដ្ឋានឃុំគោលាប់ ត្រូវទទួលបន្ទុកចិញ្ចឹមយោធាចំនួនជាង២០០នាក់ ដែលកម្លាំងនេះបានមកពីកម្មករខស្សរាហកម្មដឹកជញ្ជូនខាងលីសែងរបស់តំបន់៥០៥ ដើម្បីត្រៀមវាយយកក្រុងក្រចេះ រួមជាមួយយោធាស្រុក យោធាតំបន់ និងយោធាវៀតណាមដើម្បីវាយយកប្រទេសកម្ពុជាតែម្តង ។ ក្រោយពីបានទទួលផែនការពី យី ហើយ គុល និងបក្ខពួក បានសាងសង់ឃ្លាំងមួយសម្រាប់លាក់អាវុធមួយនៅព្រៃចុងអូរជ័រ ហើយបានយកអាវុធគ្រាប់រំសេវ និងស្បៀងដែលបានរៀបចំតាមគម្រោងរួចជាស្រេចហើយនោះ យកមកលាក់ទុកនៅក្នុងឃ្លាំងនេះ ហើយបានចាត់តាំងឈ្មោះ សុក និង ខៀន ឲ្យដាក់វេនគ្នាយាមការពារ ។

នៅដើមខែកម្ភៈ ឆ្នាំ១៩៧៨ យី បានមកឃុំគោលាប់ស្នើសុំផ្ទះ៣ខ្នង សម្រាប់ដាក់ទូរលេខ និងដើម្បីក្តាប់សភាពការណ៍នៅពេលធ្វើរដ្ឋប្រហារ និងបានចាត់តាំង គុល ឲ្យទៅទាក់ទង ហាយ, ហ៊ាង, និង ឃឹម នៅមន្ទីរផ្គត់ផ្គង់របស់តំបន់ និងមន្ទីរខស្សរាហកម្មដឹកជញ្ជូនដើម្បីទទួលយកកម្លាំងកម្មករមកត្រៀមបង្កប់ទុកក្នុងមូលដ្ឋាន ។ នៅថ្ងៃ

បន្ទាប់ គុល និង អុល បានទៅទទួលកម្លាំងពី ហាយ, ហ៊ាង និង ឃឹម នៅភូមិត្រពាំងកណ្តាលចំនួន២៣០នាក់ ឲ្យមកស្នាក់នៅផ្ទះដែលគ្មានប្រជាជនស្នាក់នៅ នៅភូមិព្រៃគគីរ មានឈ្មោះ ពិន, សាវ៉ន និង ឈិន ជាអ្នកទទួលខុសត្រូវនៅទីនោះ និងបានចាត់តាំង ដាន, លឹម និង ណុត ជាអ្នកផ្គត់ផ្គង់ស្បៀងអាហារដល់អ្នកទាំងអស់នោះ ហើយថែមទាំងបានចាត់តាំង ដេត និង ភី ឲ្យមកអប់រំ និងហ៊ឹកហ៊ឺន ផ្នែកបច្ចេកទេសយោធាដល់កម្មករទាំងអស់នោះទៀតផង ។

ចុងខែកម្ភៈ ឆ្នាំ១៩៧៨ ដោយផែនការជ្រើសរើសឈ្លបនៅតាមមូលដ្ឋានមិនបានសម្រេច តាមផែនការ គុល បានកោះហៅបក្ខពួកទាំងអស់ឲ្យមកប្រជុំនៅមន្ទីរឃុំគោលាប់ ដើម្បីស្នើសុំកម្លាំងបន្ថែមមកឲ្យឃុំ ។ ពេលនោះឈ្មោះ ឆាយ បានប្រគល់កម្លាំងដែលខ្លួនអប់រំកសាងបានចំនួនបីនាក់មាន ឈ្មោះ កុល ចេត្តនា, ងិន កេសនា និង ម៉ៅ វើង ។ បន្ទាប់ពីប្រជុំចប់ គុល បានយកកម្លាំងយុវជនទាំងបីទៅបញ្ចូលក្នុងកម្លាំងឈ្លបរបស់ឃុំគោលាប់ ។

ខែមីនា ឆ្នាំ១៩៧៨ គុល បានចុះទៅសហករណ៍ជ្រាំ និងសហករណ៍រវាង ហើយអប់រំកម្លាំងថ្មីបាន៨នាក់ថែមទៀតមានឈ្មោះ វ៉ើន ប្រជាជននៅសហករណ៍ភូមិជ្រាំ ឃុំគោលាប់, ស្រេង ប្រជាជននៅសហករណ៍ភូមិជ្រាំ ឃុំគោលាប់, យុន ប្រជាជននៅសហករណ៍ភូមិជ្រាំ ឃុំគោលាប់, ស៊ាន ប្រជាជននៅសហករណ៍រវាង ឃុំគោលាប់, ផល្លី ប្រជាជននៅសហករណ៍រវាង ឃុំគោលាប់, វ៉ា យុទ្ធជនឈ្លបសហករណ៍រវាង ឃុំគោលាប់, យ៉ន ប្រជាជនចាស់នៅសហករណ៍រវាង ឃុំគោលាប់, និង យ៉ាន់ ឈ្លបសហករណ៍រវាង ឃុំគោលាប់ ។ ក្រោយមក គុល បានទៅជួប សៅ នៅភូមិអូរឫស្សី បន្ទាប់ពីបានទទួលសំបុត្របន្ទាន់មួយច្បាប់ ។ នៅពេលទៅដល់ គុល បានឃើញ ហ៊ាន, សាក់, យ៉េត, សុន, រឿន, និង សុន អង្គុយចាំរួចជាស្រេច ។ ភ្លាមនោះដែរ សៅ បាននិយាយថា “មិត្ត គល់ ឯងមានដឹងរឿងនៅ ដ-៥ ទេ? មានយោធាមកព័ទ្ធមន្ទីរ ដ-៥ ហើយមិនដឹងចាប់អ្នកណាទេ?” នៅពេលសួរ គល់ ក៏មិនដឹងរឿងអ្វីសោះ ក៏បំបែកគ្នាមួយរយៈ ហើយបានណាត់ជួបគ្នាសាជាថ្មីទៀតនៅភូមិត្រពាំងកណ្តាល នាពេលយប់ថ្ងៃទី២៤ ។ ថ្ងៃណាត់ជួបគ្នាបានមកដល់ គល់ និងបក្ខពួកទាំងអស់បានទៅជួបគ្នា ។ ពេលនោះ ម៉ែន បាននិយាយថា “ឥឡូវនេះ សភាពការណ៍មិនសូវល្អទេ ដូច្នេះ យើងត្រូវគេចខ្លួនទៅតាមព្រៃសិន ឯការពិនិត្យអាវុធ និងប្រជុំសាខាក៏ត្រូវផ្អាកសិនដែរ” ចប់ការប្រជុំយើង ក៏បានបំបែកគ្នា ។ ក្រោយពេលចេញពីប្រជុំ ទើបដឹងថា ឃី ត្រូវអង្គការចាប់ខ្លួន ។ ហេតុនេះ គល់ បាននាំឈ្លបជាង១០នាក់រត់ទៅភូមិច្រវ៉ាំ ។ ពេលមកដល់ភូមិច្រវ៉ាំ គល់ បានឲ្យឈ្លបទាំងអស់ស្នាក់នៅក្នុងភូមិនេះ ចំណែកខ្លួនបានរត់បន្តទៅព្រៃគគីរ ចេញពីព្រៃគគីរក៏បានជួប អ៊ាង នៅ ព្រៃកោះដាច់ ។ អ៊ាង បានប្រាប់ថា “បង យាន រកបង គល់ ឯង!” ។ នៅពេលដឹងថា យាន រកខ្លួន គល់ ក៏បានទៅជួប យាន នៅភូមិចង្ក្រង់ តែពេលទៅដល់ភូមិចង្ក្រង់មិនបានជួប យាន ទេ គល់ ក៏បានវិលត្រឡប់មកភូមិច្រវ៉ាំវិញ ស្នាក់នៅបានមួយថ្ងៃមួយយប់ ក៏បានវិលទៅឃុំគោលាប់វិញ រហូតដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៨ ត្រូវអង្គការចាប់ខ្លួនតែម្តងទៅ ។

ចម្លើយសារភាពរបស់ នូ អ៊ានឡេង ហៅ គល់ ជាឯកសារសរសេរដោយដៃមានចំនួន៤៩ទំព័រ ក្នុងនោះមានបញ្ជីរាយឈ្មោះមនុស្សដែលជាប់ពាក់ព័ន្ធនៅក្នុងចម្លើយសារភាពចំនួន២៦៩នាក់ បានរួមគ្នាជាមួយ គល់ ធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ ។ ឈ្មោះខ្លះត្រូវបានអង្គការចាប់ខ្លួនហើយ និងឈ្មោះខ្លះទៀតមិនទាន់ចាប់ខ្លួននៅឡើយ ។ ចម្លើយសារភាពនេះ បានធ្វើចប់សព្វគ្រប់នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៨ ដែលនៅចុងបញ្ចប់នៃចម្លើយសារភាពនេះ មានចុះហត្ថលេខា និងស្នាមផ្តិតមេដៃរបស់អ្នកសារភាពឈ្មោះ នូ អ៊ានឡេង ហៅ គល់ និងមានចុះហត្ថលេខារបស់អ្នកសួរចម្លើយឈ្មោះ ជា វុធ ។ **ឆេង ទ៉េង**


## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm . ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# យុវជន យុវនារីបដិវត្តន៍ ត្រូវពង្រឹងពង្រីកគោលជំហរសមូហភាព ឱ្យខ្ពស់ជានិច្ចដើម្បីការពារ និងកសាងប្រទេសបានល្អប្រសើរ និងលឿនលោតផ្លោះ!

*(អត្ថបទស្រង់ចេញពីទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្តន៍លេខពិសេស ចេញផ្សាយខែកញ្ញា ឆ្នាំ១៩៧៧ D២១៤០៣)*

ប្រទេសកម្ពុជា ជាប្រទេសក្រីក្រ មានកសិកម្មអន់ថយ ។ ថែមពីលើនេះទៀត ប្រទេសកម្ពុជាយើងត្រូវសង្គ្រាមឈ្លានពាន វិនាសកម្មរបស់ចក្រពត្តិអាមេរិក និងបរិវារបំផ្លិចបំផ្លាញឲ្យវិនាស ខ្ទេចខ្ទាំអស់រយៈពេលជាង៥ឆ្នាំ យ៉ាងដំណំទៀត ។ ដូច្នេះ ក្រោយចេញផុតពីសង្គ្រាមវិនាសកម្មនេះភ្លាម ប្រជាជនកម្ពុជាយើងមានការលំបាក ខ្វះសព្វ ខ្វះគ្រប់ ហើយត្រូវប្រឈមមុខដោះស្រាយបញ្ហាស្មុគស្មាញមួយរយ មួយពាន់ជំពូក ។ នេះជាសភាពធម្មតានៃប្រទេសដែលទើបចេញផុតពីសង្គ្រាម ។ ប្រទេសណាក៏ដូចជាប្រទេសណាដែរ តាមពិសោធនៅក្នុងសកលលោក ប្រទេសដែលទើបចេញផុតពីសង្គ្រាមនីមួយៗ ត្រូវចំណាយពេលពី ៣ឆ្នាំងយ៉ាងតិច ដើម្បីរៀបចំស្ដារសេដ្ឋកិច្ចជាតិរបស់ខ្លួនឲ្យដំណើរការឡើងវិញបាន និងអាចឧបត្ថម្ភខ្លួនឯងវិញបាន ។

ប៉ុន្តែ ចំពោះប្រទេសកម្ពុជាយើងដែលធ្លាប់មានប្រពៃណីប្រយុទ្ធអង់អាចក្លាហាន ជាមួយធម្មជាតិ ក៏ដូចជាមួយខ្មាំងសត្រូវ



កសិករភ្ជួររាស់ដំណាំបន្ថែម សម្រាប់ឧបត្ថម្ភខ្លួន និងសរមភូមិមុខ

ឈ្លានពានទឹកដី តាំងពីយូរលង់ណាស់មកហើយ វិនាសកម្ម និងការលំបាកវេទនា ខ្វះសព្វ ខ្វះគ្រប់ ដែលបណ្តាលមកពីសង្គ្រាមឈ្លានពានដ៏កំណាចឃោរឃៅរបស់ចក្រពត្តិអាមេរិក និងបរិវាររនេះ ពុំបានធ្វើឲ្យវីរប្រជាជនកម្ពុជាយើងអស់សង្ឃឹម ទាល់ច្រក សុញគំនិត ហើយស្ថិតនៅជាអសកម្ម ចំពោះមុខគ្រោះមហន្តរាយទាំងនេះឡើយ ។ ផ្ទុយទៅវិញ វិនាសកម្ម និងការលំបាកវេទនាសព្វបែបយ៉ាង ការខ្វះសព្វ ខ្វះគ្រប់នេះ បានលត់ដំ និងសាកល្បងនូវគោលជំហរវីរភាព និងគោលជំហរប្រយុទ្ធស្រួចស្រាវដាច់ខាត របស់ប្រជាជនកម្ពុជាយើង ឲ្យរឹតតែរឹងប៉ឹង មាំជំហរថែមទៀត ។ រីឯសង្គ្រាមវិនាសកម្មដ៏កំណាចឃោរឃៅរបស់ចក្រពត្តិអាមេរិក និងបរិវារ បានដុតភ្លើងកំហឹងជាតិ និងភ្លើងកំហឹងវណ្ណៈរបស់ប្រជាជនកម្ពុជាយើងឲ្យឆេះក្តៅងំជាប់ជានិច្ច គ្មានពេលណារលត់ឡើយ ។ ដូច្នេះប្រជាជនកម្ពុជា បានប្រែក្លាយការឈឺចាប់ខ្លោចផ្សា និងគំនុំឈាមស្រស់ទាំងអស់នេះ ឲ្យក្លាយទៅជាកម្លាំងប្រយុទ្ធយ៉ាងមោះមុត ស្រួចស្រាវបំផុត ក្នុងការវាយសម្រុកកសាងប្រទេស និងការពារប្រទេសបច្ចុប្បន្ន និងតទៅអនាគតទៀតជារៀងរហូត ។

គ្រាន់តែចេញផុតពីសង្គ្រាមវិនាសកម្មភ្លាម ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជាយើង ប្រជាជនកម្ពុជាបានរួបរួមសាមគ្គីគ្នា ចិត្តមួយ ថ្លើមមួយ ប្រមូលផ្តុំកម្លាំងកាយ ចិត្ត និងមធ្យោបាយដែលមាននៅសេសសល់ខ្លះៗទាំងប៉ុន្មាន វាយសម្រុកបង្កបង្កើនផល ស្តារសេដ្ឋកិច្ចជាតិ ដើម្បីដោះស្រាយជីវភាពប្រជាជនខ្លួនឯងផង និងមានទុនការពារប្រទេស និងកសាងប្រទេស ដោយគោលជំហរឯករាជ្យម្ចាស់ការផង យ៉ាងសស្រោក់សស្រាំ ទាំងយប់ទាំងថ្ងៃ ។ គ្មានអ្នកណាម្នាក់ ឱបដៃនៅស្ងៀមទំនេរ ឬឱបដៃរង់ចាំជំនួយពីសកលលោកឡើយ ។ ម្នាក់ៗ បានមូរដៃអាវ លាត់ជើងខោ និងវីរក្សិនយ៉ាងណែន ចុះប្រឡូកបង្កបង្កើនផលយ៉ាងខ្លាំងក្លា ទាំងយប់ទាំងថ្ងៃ ទាំងប្រាំង ទាំងវស្សា រហូតដល់មានស្បៀងដោះស្រាយជីវភាពខ្លួនឯងបានដោយជោគជ័យ និងដោយឯករាជ្យ ម្ចាស់ការ ។ រហូតមកដល់បច្ចុប្បន្ននេះ គឺក្នុងរយៈតែពីរឆ្នាំប៉ុណ្ណោះ ប្រជាជនកម្ពុជា ក្រោមការដឹងនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជាយើង បានប្រយុទ្ធកសាងប្រទេសឲ្យមានមុខមាត់ថ្មីសន្ធាង និងរីកចម្រើនលោតផ្លោះលើគ្រប់វិស័យ ។ បច្ចុប្បន្ននេះ នៅជនបទកម្ពុជាយើង ទីណាៗក៏មានប្រព័ន្ធសំណង់ចាត់ចែងទឹកខ្វាត់ខ្វែងស្មុគស្មាញ ដែលអាចម្ចាស់ការកម្រិតខ្ពស់លើកបញ្ហាទឹកបង្កបង្កើនផល ។ ក្នុងរយៈតែជាងពីរឆ្នាំប៉ុណ្ណោះ ប្រជាជនកម្ពុជាយើងបានប្រយុទ្ធលើកទំនប់ តូច មធ្យម ធំ ច្រើន ស្មុគស្មាញ ទប់ព្រែក ស្ទឹង បឹង អូរ តម្កល់ទឹក និងបញ្ចូលទឹកស្រោចស្រពស្រែ បានជាច្រើនម៉ឺនហិកតា ប្រយុទ្ធធ្វើអាងទឹក តូច ធំ មធ្យម នៅគ្រប់ទីកន្លែង ដើម្បីតម្កល់ទឹកទុកស្រោចស្រពស្រែ បានខួបប្រាំងខួបវស្សា ។ កាលក្នុងសម័យមុនរំដោះ បារាយណ៍ទឹកថ្លា នៅក្នុងខេត្តសៀមរាប ជាអាងទឹកធំបំផុតតែមួយគត់នៅក្នុងប្រទេសកម្ពុជាយើង ។ ប៉ុន្តែ បច្ចុប្បន្ននេះ អាងទឹកធំៗ ដែលមានចំណុះរាប់រយលានម៉ែត្រគ្រីគុណ ហើយដែលមានទំហំប៉ុនគ្នានឹងបារាយណ៍ទឹកថ្លា ហើយនិងធំជាងបារាយណ៍ទឹកថ្លាទៅទៀត មាននៅគ្រប់ភូមិភាគ និងតំបន់ ។ រីឯ អាងទឹកមធ្យមចំណុះរាប់សិបលានម៉ែត្រគ្រីគុណ ក៏មានច្រើនស្មុគស្មាញ នៅតាមគ្រប់តំបន់ និងស្រុកដែរ ។ ក្រៅពីនេះ ប្រជាជនកម្ពុជាយើង នៅបានប្រយុទ្ធជីកព្រែកវែងៗ ច្រើនសិបគីឡូ ជីកប្រឡាយ តូច មធ្យម ធំ ខ្វាត់ខ្វែងពាសពេញផ្ទៃជនបទកម្ពុជាយើង ។ ទន្ទឹមនឹងនេះ ប្រជាជនកម្ពុជាយើង ក៏នៅបានប្រយុទ្ធលើកប្រព័ន្ធភ្លឺស្រែថ្មី កាត់ខ្វាត់ខ្វែងជាក្រឡាឈើត្រង់ នៅតាមគ្រប់វាលស្រែដីខ្វាញ់ និងដីមធ្យមពាសពេញអស់ហើយ ។ ប្រព័ន្ធសំណង់ទឹក ដ៏ច្រើនស្មុគស្មាញទាំងនេះ ដែលពុំធ្លាប់មានទេនៅក្នុងប្រវត្តិសាស្ត្រកម្ពុជាជាង២០០០ឆ្នាំមកហើយ បានធ្វើឲ្យកសិករ សហករណ៍យើង អាចម្ចាស់ការលើទឹកបង្កបង្កើនផលបានកម្រិតខ្ពស់ ហើយក៏បានធ្វើឲ្យជនបទកម្ពុជាយើងមានមុខមាត់ថ្មីសន្ធាង និងស្រស់ប្រិមប្រិយខួបប្រាំង ខួបវស្សា ។ ឆ្នាំនេះប្រជាជនយើង បានវាយសម្រុកបង្កបង្កើនផលតជាប់គ្នារដឹកដោយគ្មានគិតគូរពីប្រាំងឬវស្សា ឬដេករង់ចាំទឹកភ្លៀងធ្លាក់ពីលើមេឃឡើយ ។ ការនេះបានធ្វើឲ្យជនបទកម្ពុជាយើង ឥឡូវក្លាយទៅជាសួនស្រូវ និងសួនដំណាំខៀវស្រងាត់ចម្រុះពណ៌លឿងទុំឆ្អិនឆ្អៅ ទាំងប្រាំង ទាំងវស្សាយ៉ាងពិតប្រាកដហើយ ។

ជាលទ្ធផលឆ្នាំនេះ ប្រជាជនកម្ពុជាយើង មានស្បៀងដោះស្រាយ និងកែប្រែជីវភាពប្រជាជនយើង បានគ្រប់គ្រាន់ ធូរធាឡើងជាលំដាប់ ដោយឯករាជ្យ ម្ចាស់ការពេញទី ហើយថែមទាំងមានសល់ស្រូវអង្ករនាំចេញទៅលក់ក្រៅប្រទេសសម្រាប់ជាទុនទិញគ្រឿង

ចក្រ និងរបស់របរចាំបាច់ផ្សេងៗ យកមកកសាងប្រទេស និងការពារប្រទេស បានយ៉ាងស័ក្តិសិទ្ធិទៀតផង ។

ខាងផ្នែកឧស្សាហកម្ម ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជាយើង ក្នុងរយៈតែជាងពីរឆ្នាំប៉ុណ្ណោះ ប្រជាជន កម្មករ សហជីពយើង មិនត្រឹមតែបានប្រយុទ្ធស្តា និងជុសជុលរោងចក្រចាស់ៗ ដែលត្រូវខូចខាតយ៉ាងដំណាំក្នុងពេលសង្គ្រាម ឲ្យដំណើរការឡើងវិញជាប្រក្រតីប៉ុណ្ណោះទេ តែបងប្អូននៅបានប្រយុទ្ធកសាងរោងចក្រថ្មីៗ បានជាបន្តបន្ទាប់ទៀត ។ សព្វថ្ងៃនេះ បងប្អូនបានក្តាប់បច្ចេកទេសវិទ្យាសាស្ត្រយ៉ាងណែនក្នុងដៃ ចេះបញ្ឆារគ្រឿងចក្រសព្វបែបយ៉ាងនៅក្នុងរោងចក្រនានា ព្រមទាំងមានសមត្ថភាព និងទេពកោសល្យច្នៃប្រឌិត ធ្វើគ្រឿងចក្រថ្មីៗ ឬកែកាឡៃ គ្រឿងចក្រចាស់ៗ ដែលធ្លាប់តែរណបបរទេសទាំងស្រុង ទាំងខាងវត្ថុធាតុដើម ទាំងខាងគ្រឿងបន្លាស់ខ្មៅខ្លងផ្សេងៗ ឲ្យមកប្រើប្រាស់វត្ថុធាតុដើម និងរបស់របរដែលមាននៅក្នុងប្រទេសយើងដោយជោគជ័យទៀត ។ បច្ចុប្បន្ននេះ បងប្អូនកំពុងវាយសម្រុកផលិតឧបករណ៍ និងម៉ាស៊ីនកសិកម្ម ផ្សេងៗ រួមជំរុញមហាចលនា វាយសម្រុកបង្កបង្កើនផលដោយឯករាជ្យម្ចាស់ការ និងផលិតរបស់របរចាំបាច់ផ្សេងៗ បម្រើជីវភាពប្រជាជន រួមដោះស្រាយជីវភាពប្រជាជនយើង ខាងសម្ភារបានដោយជោគជ័យជាបន្តបន្ទាប់ ។

ខាងផ្នែកសង្គមកិច្ច និងសុខាភិបាល ក៏មានការរីកចម្រើនយ៉ាងឆាប់រហ័សដែរ ។ រោងចក្រផលិតថ្នាំពេទ្យយើងនៅក្រុងភ្នំពេញ កំពុងវាយសម្រុកផលិតទាំងថ្នាំសម័យ ទាំងថ្នាំជាតិដែលប្រើប្រាស់វត្ថុធាតុដើមនៅក្នុងប្រទេសយើងទាំងអស់ បម្រើសេចក្តីត្រូវការរបស់ប្រជាជនបានដោយជោគជ័យ ។ ក្រៅពីនេះ នៅតាមគ្រប់ភូមិភាគ តំបន់ ស្រុក រហូតដល់គ្រប់សហករណ៍ទៀត សុទ្ធតែមានមន្ទីរពេទ្យសម្រាប់ព្យាបាលអ្នកជំងឺ និងមន្ទីរផ្សំថ្នាំពេទ្យ និងថ្នាំជាតិឧបត្ថម្ភខ្លួនបានជា អតិបរមា និងដោយឯករាជ្យម្ចាស់ការ ។

រីឯខាងផ្នែកវប្បធម៌ សិក្សាបច្ចេកទេស វិទ្យាសាស្ត្រ ក៏មានការរីកចម្រើនលោតផ្លោះដែរ ។ យើងបានវាយកម្ទាត់ការមិនចេះអក្សរ នៅក្នុងប្រជាជនកម្ពុជាយើង អស់ជាមូលដ្ឋានហើយ ។ នេះជាបញ្ហាមួយធ្ងន់ធ្ងរដែលពួកវណ្ណៈកាន់អំណាចពីសង្គមចាស់ក៏ដូចជាប្រទេសនានា ជាច្រើននៅលើសកលលោក ពុំអាចដោះស្រាយបាន និងពុំទាន់ដោះស្រាយបាននៅឡើយទេ ។ ខាងផ្នែកបច្ចេកទេស វិទ្យាសាស្ត្រកម្រិតបឋម ដែលបម្រើចលនាការពារប្រទេស និងកសាងប្រទេសបច្ចុប្បន្ននេះ ក៏កូនចៅ ប្រជាជនកម្មករ កសិករក្រីក្រយើង បានក្តាប់ណែនក្នុងដៃហើយ ។ល ។

ការរីកចម្រើនលោតផ្លោះគ្រប់វិស័យ ទាំងអស់នេះបានធ្វើឲ្យជីវភាពប្រជាជនយើងមានការរីកចម្រើនធូរធាឡើងជាលំដាប់ ទាំងខាងស៊ីចុក ស្លៀកពាក់ ទាំងខាងជម្រកជ្រកនៅ ទាំងខាងថ្នាំសង្កូវ ព្យាបាលរោគ ទាំងខាងស្មារតី ទាំងខាងវប្បធម៌ បច្ចេកទេស វិទ្យាសាស្ត្រ ។ បច្ចុប្បន្ននេះជំងឺតម្កាត់ផ្សេងៗ ដែលធ្លាប់តែញាំញីសុខភាពប្រជាជនយើង ជាង២០០០ឆ្នាំមកហើយនោះ ក៏ត្រូវបានចុះថមថយជាអតិបរមា ស្ទើរតែអស់ជាមូលដ្ឋានហើយ ។ គ្រាន់តែជំងឺគ្រុនចាញ់មួយមុខក៏ឃើញថា វាចុះថមថយអន់ពី៧០ ទៅ៨០ភាគរយហើយ ។ ដូច្នេះ ឆ្នាំនេះប្រជាជនកម្ពុជាយើង មានកម្លាំងពលំខ្លាំងក្លា មាំទាំ អាចវាយសម្រុកបង្កបង្កើនផលបានសស្រោកសស្រាំជាប់ជានិច្ច នៅតាមគ្រប់មុខព្រួញទាំងអស់ ទូទាំងប្រទេស ។ ដូច្នេះឃើញថា ឆ្នាំនេះ ជីវភាពប្រជាជនយើង មានការរីកចម្រើនលោតផ្លោះលើគ្រប់វិស័យដែរ ។

ផ្នែកខាងការពារប្រទេស ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជាយើង ប្រជាជន កម្មករ កសិករ សមូហភាព និងកងទ័ពបដិវត្តន៍កម្ពុជាយើង ប្រយុទ្ធការពារប្រទេសបានល្អប្រសើរ ការពារបានទាំងព្រំដែនគោក ទឹក ការពារបានទាំងដែនសមុទ្រ កោះ ការពារបានទាំងបូរណភាពដែនដី និងអធិបតេយ្យភាពជាតិ ការពារបានទាំងសន្តិសុខផ្ទៃក្នុងជូនប្រជាជនយើង ។

សរុបមក មកទល់នឹងបច្ចុប្បន្ននេះ ប្រជាជន កម្មករ កសិករ សមូហភាព និងកងទ័ពបដិវត្តន៍កម្ពុជាយើង បានប្រយុទ្ធការពារប្រទេស បានល្អប្រសើរលើគ្រប់ផ្នែក ហើយល្អប្រសើរជាងពេលណាៗទាំងអស់ ដែលតាំងពីដើមរៀងមក ពួកវណ្ណៈកាន់អំណាចប្រតិកិរិយាគ្រប់ជំនាន់ពុំអាចការពារបានដូច្នេះឡើយ ។

ទាំងអស់នេះ ជាមហាជ័យជម្នះដ៏ធំធេងអស្ចារ្យរបស់ប្រជាជនកម្ពុជាយើង ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុនីស្តកម្ពុជា បន្ទាប់ពីមហាជ័យជម្នះ ១៧ មេសា ឆ្នាំ១៩៧៥ កន្លងទៅ ។ ប្រជាជនកម្ពុជាទាំងមូល មានការរំភើបរីករាយឥតឧបមា

ចំពោះមហាជ័យជម្នះគ្រប់ផ្នែកទាំងអស់នេះ ។ បងប្អូនយល់ច្បាស់ ហើយជឿជាក់ថា ការរីកចម្រើនលោតផ្លោះលើគ្រប់វិស័យទាំងអស់ នេះ គឺពិតជាបានមកពីរបបសមូហភាពក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជាយើង ។ តាមទំហំនៃវិនាសកម្ម ដែលបណ្តាលមកពីសង្គ្រាមឈ្លានពានរបស់ចក្រពត្តិអាមេរិក និង បរិវារ និងតាមទំហំនៃការខ្វះខាតទុនសព្វសារពើដែលប្រទេសជាតិ និងប្រជាជនយើងត្រូវឆ្លងកាត់ បើប្រសិន ជាគ្មានរបបសមូហភាព និងរឹងប៉ឹង យុត្តិធម៌ត្រឹមត្រូវក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្ត កម្ពុជាមួយ ដ៏ត្រឹមត្រូវ និងភ្លឺស្វាងទេ នោះយើងមិនគ្រាន់តែពុំអាច កសាងប្រទេស និងការពារប្រទេសបានល្អប្រសើរ និងរីកចម្រើន លោតផ្លោះលើគ្រប់វិស័យយ៉ាងនេះប៉ុណ្ណោះទេ តែយើងពុំអាច និងដោះស្រាយជីវភាពប្រជាជនយើង ដោយឯករាជ្យម្ចាស់ការ បានទៀតផង ។ ដូច្នោះហើយ បានជាប្រជាជន កម្មករ-កសិករ សមូហភាពយើង មានការរីករាយ ពេញចិត្ត ពេញថ្លើម និងរបប សមូហភាពបច្ចុប្បន្ននេះណាស់ ហើយមានជំនឿជឿជាក់លើការ ដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងរបស់បក្សកុម្មុយនីស្តកម្ពុជា យើងតែ មួយគត់ ។ បងប្អូនមានការកក់ក្តៅ ហើយមានសង្ឃឹមយ៉ាងមុតមាំលើ អនាគតដ៏ភ្លឺស្វាង ត្រចេះត្រចង់របស់ប្រទេសជាតិខ្លួន ក៏ដូចជារបស់ ខ្លួនបងប្អូនផ្ទាល់ដែរ ។ បច្ចុប្បន្ននេះ បងប្អូនអត់ព្រួយ បារម្ភ ពីជំពាក់ ឆ្នាក់គេ បំណុលវណ្ឌកទៀតហើយ អត់ព្រួយពីរឿងគ្មានការធ្វើ អត់ ព្រួយ បារម្ភពីការអត់ឃ្លានដាច់ពោះស្លាប់ ដូចកាលនៅក្នុងសង្គម ចាស់ទៀតហើយ ។ ប្រជាជនកម្ពុជាយើងទាំងមូល មានតែប្រមូល អស់កម្លាំងកាយ កម្លាំងចិត្ត កម្លាំងបញ្ញា និងសមហភាពដែលខ្លួនមាន ទាំងប៉ុន្មាន វាយសម្រុកបំពេញភារកិច្ចបដិវត្តន៍ តាមមុខព្រួញរៀងៗ ខ្លួន ឲ្យបានខ្លាំងក្លាជាប់ជានិច្ចតែប៉ុណ្ណោះ ដើម្បីរួមវិភាគទានការពារ ប្រទេស ឲ្យបានកាន់តែល្អប្រសើរឡើងទៀត និងរួមវិភាគទានកសាង ប្រទេសឲ្យរីកចម្រើនលឿនលោតផ្លោះលើគ្រប់វិស័យ យ៉ាងឆាប់ រហ័សថែមទៀតប៉ុណ្ណោះ ។ដូច្នេះ ប្រជាជនកម្ពុជាយើងគ្រប់រូបលែង នឹកនា លែងស្រមើស្រមៃទៅរករបបកម្មសិទ្ធិឯកជនដែលជារបប ជិះជាន់ហុតឈាម អន្លៀមឆ្អឹងដ៏អយុត្តិធម៌ និងឃោរឃៅហួសស៊ីស



កសិករក្នុងសហករណ៍ នៅស្រុកកោះធំ ប្រមូលផលពោតដើម្បីឧបត្ថម្ភសមូហភាព និងកងទ័ពបដិវត្តន៍ នៅសមរភូមិមុខ

បំផុតនោះទៀតហើយ ។ ប្រជាជនកម្ពុជាយើង មានតែសេចក្តីប្តេជ្ញាចិត្តការពាររបបសមូហភាពនេះ ឲ្យបានគង់វង្សស្ថិតស្ថេរចេរកាល ហើយប្តេជ្ញាកសាងពង្រឹង និងពង្រីករបបសមូហភាពនេះឲ្យបានកាន់តែរឹងប៉ឹងខ្លាំងក្លាឡើង កាន់តែល្អបរិសុទ្ធផូរផង់ឡើងថែមទៀតតែប៉ុណ្ណោះ ។

ដើម្បីរួមវិភាគទានការពារប្រទេស ការពារបក្សកុម្មុយនីស្តកម្ពុជា ការពារបដិវត្តន៍កម្ពុជា ការពាររបបសមូហភាពដ៏យុត្តិធម៌ល្អបរិសុទ្ធនេះ និងការពារប្រជាជន ឲ្យបានល្អប្រសើរជារៀងរហូតទៅ និងដើម្បីរួមវិភាគទានកសាងប្រទេសឲ្យបានលឿនលោតផ្លោះលើគ្រប់វិស័យ និងចម្រើនថ្កុំថ្កើនរុងរឿងយ៉ាងឆាប់រហ័ស យុវជនយុវនារីបដិវត្តន៍យើង ដែលជាកម្លាំងស្រួចឈានមុខ ក្នុងគ្រប់ភារកិច្ចបដិវត្តន៍បច្ចុប្បន្ននេះ ក៏ដូចជាក្នុងការបន្តវេនធ្វើបដិវត្តន៍ ឲ្យក្រហមឆ្អិនឆ្អៅជារៀងរហូតតទៅអនាគតទៀត ៖ ត្រូវតែខិតខំពង្រឹង ពង្រីក និងបំពាក់បំប៉នឲ្យដល់ខ្លួននូវគោលជំហរសមូហភាព វណ្ណៈអធនរបស់បក្សឲ្យខ្ពស់ជានិច្ច ។ ពង្រឹងពង្រីកគោលជំហរសមូហភាព វណ្ណៈអធនរបស់បក្សនេះគឺ ៖

១) ខិតខំវាយកម្ទេចនូវសតិអារម្មណ៍ កម្មសិទ្ធិសួនតួ កម្មសិទ្ធិបុគ្គល និងសតិអារម្មណ៍កម្មសិទ្ធិឯកជនផ្សេងៗទៀតទាំងអស់ ទាំងខាងកម្មសិទ្ធិខាងសម្ភារតូចធំគ្រប់បែបយ៉ាង ទាំងខាង កម្មសិទ្ធិខាងសតិអារម្មណ៍ដែលពួនសម្ងំកប់ជ្រៅនៅក្នុងពង្វឹងផ្ទៃក្នុងខ្លួនយើងម្នាក់ៗ មានកម្មសិទ្ធិខាងអំណាចអាជ្ញា កម្មសិទ្ធិខាងមុខមាត់ បុណ្យសក្តិ កម្មសិទ្ធិខាងបុគ្គលនិយម នាម៉ឺននិយម ការិយាល័យនិយម យោធានិយម កម្មសិទ្ធិខាងអំណាចអួតអាង កម្មសិទ្ធិខាងដំណែងនាទី ស្នាដៃបុគ្គល កម្មសិទ្ធិខាងសេរីនិយមក្នុងការរស់នៅ ធ្វើការងារដើរហើរ ក៏ដូចសេរីនិយមក្នុងការនិយាយស្តី ទាក់ទងកម្មសិទ្ធិ ខាងប្រណែនឈ្នានីសប្រៀបធៀបកម្មសិទ្ធិខាងចចេសចចូច វាយប្រហារសមមិត្តជុំវិញផងគ្នា ។ល។

សតិអារម្មណ៍កម្មសិទ្ធិឯកជនទាំងអស់នេះ ទោះបីស្តែងចេញជារូបភាពអ្វីក៏ដោយ ទោះបីមាន កម្រិតណាក៏ដោយ សុទ្ធតែនាំឲ្យអន្តរាយដល់អាត្មាខ្លួន ក៏ដូចអន្តរាយដល់ចលនាបដិវត្តន៍ ដល់របបសមូហភាពដ៏យុត្តិធម៌ត្រឹមត្រូវនៃយើង ហើយក៏និងនាំឲ្យអន្តរាយដល់ប្រទេសជាតិ និងប្រជាជនយើងយ៉ាងពិតប្រាកដណាស់ ។ ដូច្នេះ យុវជន-យុវនារីបដិវត្តន៍យើង គ្មានហេតុផលអី និងឱបក្រសោបវា លាក់បំពួនវា ឲ្យរីកដុះដាលនៅក្នុងខ្លួនយើងទៀតនោះឡើយ ។ យើងត្រូវតែដាច់ខាតវាយកម្ទេចវា គាស់រំលើងវាចោលឲ្យបានទាំងស្រុង ។ ដូច្នេះ យុវជនយុវនារីបដិវត្តន៍យើង ត្រូវតែប្តេជ្ញាចិត្តខ្ពស់ ប្រយុទ្ធវាយកម្ទេចវាក្នុងពេលបច្ចុប្បន្នក៏ដូចតទៅអនាគតតរៀងរហូតទៅដែរ ។

២) ត្រូវស្រឡាញ់ពេញចិត្ត ពេញថ្លើម របបសមូហភាពរបស់បក្សយើង ។ ស្រឡាញ់របបសមូហភាពនេះ គឺមិនមែនស្រឡាញ់នៅតែត្រឹមមាត់ថា នៅតែត្រឹមវិញ្ញាណប៉ុណ្ណោះទេ តែស្រឡាញ់របបសមូហភាពឲ្យទៅជាទស្សនៈគោលជំហរ ហើយជ្រួតជ្រាបថា ទាល់តែមានរបបសមូហភាពរឹងប៉ឹងខ្លាំងក្លា និងយុត្តិធម៌ត្រឹមត្រូវក្រោមការដឹកនាំរបស់បក្ស ទើបប្រទេសជាតិយើងអាចស្ថិតស្ថេរ គង់វង្ស និងរឹងប៉ឹងខ្លាំងក្លាជារៀងរហូតទៅបាន ។ ទាល់តែស្ថិតនៅក្រោមរបបសមូហភាពរបស់បក្ស បច្ចុប្បន្ននេះ ទើបប្រទេសជាតិយើងរីកចម្រើនថ្កុំថ្កើងរុងរឿង មានឈ្មោះបោះសំឡេងទាំងនៅក្នុងប្រទេសទាំងនៅលើសកលលោក ។ ដោយសារមានរបបសមូហភាពនេះហើយ ទើបប្រជាជនកម្មករ កសិករក្រីក្រយើង បានឡើងជាម្ចាស់ប្រទេសជាតិ ម្ចាស់ទឹកដីព្រៃព្រឹក្សា ស្រែចម្ការរបស់ខ្លួន ហើយមានសិទ្ធិសេរីភាព និងមានលទ្ធភាពបញ្ចេញអស់នូវសមត្ថភាពដែល


យុទ្ធនារីកងចល័តដឹកជញ្ជូនស្បៀងអាហារ និងគ្រាប់រំសេវយកទៅឧបត្ថម្ភឲ្យកងទ័ពបដិវត្តន៍ នៅខ្សែត្រៀមជួរមុខ

ខ្លួនមាន រួមគ្នាវាយសម្រុកការពារប្រទេសបានល្អប្រសើរ និងកសាងប្រទេសបានលឿនលោតផ្លោះ លើគ្រប់វិស័យបានដូចបច្ចុប្បន្ននេះ ។ ដោយសាររបបសម្ពហភាពនេះហើយ ទើបជីវភាពប្រជាជនក្រីក្រយើង ដែលធ្លាប់តែរស់នៅរងទុក្ខវេទនា ឈឺចាប់ខ្លោចផ្សា និងអត់ឃ្លានជាប្រចាំ ជាង២០០០ឆ្នាំមកហើយនោះ ត្រូវបានកែប្រែ និងលើកតម្កើងឲ្យសម្បូរធូរធាឡើងជាលំដាប់ ហើយឈានទៅសម្បូរសប្បាយនៅពេលខាងមុខទៀត ។ ដូច្នេះ សរុបមក របបសម្ពហភាពមានសារសំខាន់ និងមានអត្ថន័យជាយុទ្ធសាស្ត្រចំពោះវាសនាប្រទេសជាតិ និងប្រជាជនយើង ក៏ដូចចំពោះចលនាបដិវត្តន៍កម្ពុជាយើង និងអនាគតនៃបក្សកុម្មុយនីស្តកម្ពុជាយើងដែរ ។ បើប្រសិនជារបបសម្ពហភាពយើងបច្ចុប្បន្ននេះ ត្រូវរលំរលាយទៅវិញនោះ ប្រទេសជាតិ និងប្រជាជន និងត្រូវធ្លាក់ខ្លួនទៅជាខ្ញុំកញ្ជះគេវិញយ៉ាងទាបថោកបំផុត ខ្ញុំកញ្ជះ ចក្រពត្តិបរទេសផង ខ្ញុំកញ្ជះវណ្ណៈសក្តិភូមិ វណ្ណៈនាយទុន និងវណ្ណៈជិះជាន់ផ្សេងៗទៀតផង ។ ដូច្នេះ ប្រទេសជាតិ និងប្រជាជនកម្ពុជាយើង ព្រមទាំងយុវជន យុវនារីកម្ពុជាយើង និងត្រូវជួបប្រទះនូវគ្រោះមហន្តរាយ និងទុក្ខសោកវេទនាសព្វបែបយ៉ាង ដែលពុំងាយនឹងរើខ្លួនរួចវិញឡើយ ។ ឃើញយ៉ាងនេះ ទើបយុវជនយុវនារីបដិវត្តន៍យើង ចាំបាច់ត្រូវតម្កល់ផលប្រយោជន៍រួមរបស់សម្ពហភាព ពោលគឺរបស់ប្រទេសជាតិ បដិវត្តន៍ និងប្រជាជនយើងឲ្យខ្ពស់ជាងផលប្រយោជន៍បុគ្គលស្ងួនតួយើង ឲ្យខ្ពស់ជាងអាយុជីវិតខ្លួនយើងទៅទៀត ។ ទោះបីពេលខ្លះ របបសម្ពហភាពនេះ ឬផលប្រយោជន៍របស់សម្ពហភាពនេះវាទំនាស់ ឬវាប៉ះពាល់នឹងផលប្រយោជន៍បុគ្គលស្ងួនតួយើងខ្លះៗក៏ដោយ ក៏យើងហ៊ានលះបង់ផលប្រយោជន៍បុគ្គលស្ងួនតួនេះដើម្បីផលប្រយោជន៍សម្ពហភាព និងដើម្បីរបបសម្ពហភាពយើង រីកចម្រើនរឹងប៉ឹងខ្លាំងក្លា ដោយរីករាយសោមនស្សជ្រះថ្លាជានិច្ច ។ ដូច្នេះយើងមិនទោមនស្ស មិនអាក់អន់ស្រពន់ចិត្ត មិនថ្នាំងថ្នាក់នឹងបក្ស និងសម្ពហភាព និងរបបសម្ពហភាពនេះឡើយ ។ តែផ្ទុយទៅវិញ យើងនៅតែរីករាយ ពេញចិត្ត ស្រឡាញ់របបសម្ពហភាព ហើយនៅតែឃើញថា របបសម្ពហភាពនេះ ខ្ពង់ខ្ពស់ ល្អបរិសុទ្ធជាងរបបឯកជនឆ្ងាយណាស់ដូចមេឃ និងដី ។ នេះហើយជាទស្សនៈ គោលជំហរ ស្រឡាញ់ពេញចិត្ត ពេញថ្លើម និងរបបសម្ពហភាពរបស់បក្សយើង ដែលយុវជន យុវនារីបដិវត្តន៍យើងត្រូវតែខិតខំបំពាក់បំប៉នឲ្យខ្លួនរឹងមាំជានិច្ច គ្រប់ពេលវេលា ។

៣) ឃើញសារសំខាន់ និងអត្ថន័យជាយុទ្ធសាស្ត្រ នៃរបបសម្ពហភាពយ៉ាងនេះហើយ យុវជន យុវនារីបដិវត្តន៍យើងចាំបាច់ត្រូវការពាររបបសម្ពហភាពនេះឲ្យបានដាច់ខាត ហើយរួមចំណែកពង្រឹងពង្រីករបបសម្ពហភាពនេះ ឲ្យបានរឹងប៉ឹងខ្លាំងក្លា និងស្ថិតស្ថេរថេរកាលតរៀងរហូតទៅ ។ ម្យ៉ាងដោយលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ជាប់ជានិច្ច ខំតាមដានរាវរក បោសសំអាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងបក្សក្តី ផ្ទៃក្នុងបដិវត្តន៍ក្តី ផ្ទៃក្នុងកងទ័ពក្តី ផ្ទៃក្នុងសហករណ៍ និងប្រជាជនក្តី កុំឲ្យវាបំផ្លិចបំផ្លាញឬបំភ្លៃបំប៉ោងរបបសម្ពហភាពដ៏ត្រឹមត្រូវល្អបរិសុទ្ធនេះ របស់បក្សបានឡើយ ។ ម្យ៉ាងទៀតដោយខិតខំអនុវត្តមាគ៌ា និងលាក់ការណ៍ផ្សេងៗរបស់បក្សឲ្យបានត្រឹមត្រូវជានិច្ច កុំយកផលប្រយោជន៍បុគ្គលស្ងួនតួមកវាំងស្ទះ ឬមកបង្វែរមាគ៌ាបក្ស លាក់ការណ៍ និងគោលការណ៍ផ្សេងៗរបស់បក្សដាច់ខាត ។

ធ្វើយ៉ាងនេះ ទើបហៅថា ការពាររបបសម្ពហភាព ទើបអាចការពាររបបសម្ពហភាពបានល្អ ប្រសើរជារៀងរហូតទៅ ។ បើយុវជន យុវនារីបដិវត្តន៍យើងគ្រប់រូប បំពាក់បំប៉ន និងពង្រឹងពង្រីកនូវគោលជំហរ សម្ពហភាពវណ្ណៈអធនរបស់បក្ស ដូចពោលខាងលើនេះ បានរឹងប៉ឹងល្អយ៉ាងនេះ នោះយើងប្រាកដជានឹងរួមចំណែកវាយសម្រុកការពារ និងកសាងប្រទេសបច្ចុប្បន្ននេះបានខ្លាំងក្លា និងលឿនលោតផ្លោះ យ៉ាងពិតប្រាកដ ។ តទៅអនាគតទៀត យុវជន យុវនារីបដិវត្តន៍យើង ប្រាកដជានឹងបន្តវេនធ្វើបដិវត្តន៍បានល្អប្រសើរ និងក្រហមឆ្អិនឆ្អៅជារៀងរហូត គ្មានខុបសគ្គអ្វីគ្មានខ្មាំងសត្រូវតូច ធំ ឬជិតឆ្ងាយណាអាចមកធ្វើឲ្យល្អក់ពណ៌បដិវត្តន៍កម្ពុជាយើង និងបក្សកុម្មុយនីស្តកម្ពុជាយើងបានជាដាច់ខាត ។

**ទស្សនៈខុសឆ្គងមួយចំនួនកន្លងមក**

បើពិនិត្យជាចលនារួម នៅទូទាំងប្រទេសឃើញថាចលនាសម្ពហភាព និងរបបសម្ពហភាពរបស់បក្សយើងបច្ចុប្បន្ននេះ មានសភាពរឹងប៉ឹង ខ្លាំងក្លា និងលឿនលោតផ្លោះ ទាំងខាងផ្នែកចាត់តាំងទាំងចលនា ទាំងទស្សនៈគោលដៅ ។ ប៉ុន្តែ បើពិនិត្យទៅតាមបុគ្គលខ្លះៗ និងអង្គភាពខ្លះៗវិញ ឃើញនៅមានទស្សនៈខុសឆ្គងមួយចំនួនចំពោះគោលជំហរសម្ពហភាពវណ្ណៈអធនរបស់បក្សនេះ ។ មូលហេតុសំខាន់ គឺមកពីមានកម្មសិទ្ធិស្ងួនតួខាងសម្ភារក្តី ខាងសតិអារម្មណ៍ក្តី

ខាងមនោសញ្ចេតនាក្តី ខាងលោកទស្សនៈក្តី និងខាងទម្លាប់ចាស់ក្តី ។

១) ពេលចលនាសមូហភាព ឬរបបសមូហភាពស្រប និងផលប្រយោជន៍បុគ្គលខ្លួន អាត្មាខ្លួន នោះយើងក៏ស្រែកជយោ របបសមូហភាព ជយោ! បក្សកុម្មុយនីស្តកម្ពុជាដ៏ត្រឹមត្រូវ និងភ្លឺស្វាងមហាអស្ចារ្យ ។ ប៉ុន្តែ ពេលណាដែលចលនាសមូហភាព ឬរបបសមូហភាពទំនាស់ ឬប៉ះនឹងផលប្រយោជន៍ស្ងួនភ្ងា ឬមនោសញ្ចេតនាបុគ្គលខ្លួន នោះមិត្តយើងខ្លះក៏ទោមនស្សថ្នាំងថ្នាក់នឹងសមូហភាព វាយតម្លៃរបបសមូហភាពថាយ៉ាងនេះ យ៉ាងនោះ រហូតដល់ថ្នាំងថ្នាក់នឹងបក្សថែមទៀតផង ។

ឧទាហរណ៍ៈ ពេលបក្ស ដកប្រជាជនពីទីក្រុងនានាទៅរស់នៅបង្កបង្កើនផលនៅជនបទ មិត្តយើងខ្លះដែលមានម៉ែឪបងប្អូន កូនចៅ នៅក្នុងចំណោមប្រជាជនទាំងនេះដែរ ក៏តូចចិត្តទោមនស្ស វាយតម្លៃបដិវត្តន៍សង្គមនិយម ថាយ៉ាងនេះ យ៉ាងនោះ តែមិត្តយើងមិនឃើញសារសំខាន់ជា យុទ្ធសាស្ត្រ ជាអាយុជីវិត ក្នុងកិច្ចការពារប្រទេស ការពារផលបដិវត្តន៍ និងការពារប្រជាជនយើងទូទាំងប្រទេសនោះឡើយ ។

ឧទាហរណ៍ៈ ពេលបក្សប្រកាសចាត់តាំងសហករណ៍កសិករនៅទូទាំងប្រទេស ដើម្បីចាក់គ្រឹះ កសាងរបបសមូហភាពសង្គមនិយមនៅកម្ពុជា ក៏ដូចដើម្បីរំដោះប្រជាជនក្រីក្រយើងលើគ្រប់ផ្នែកឲ្យបានទាំងស្រុងដាច់ខាត មិត្តយើងខ្លះដែលធ្លាប់ចូលចិត្តរស់នៅជាឯកជនក៏ហាក់ដូចជាមានការចង្អៀតចង្អល់ក្នុងចិត្ត និងការចាត់តាំងសហករណ៍កសិករនេះ ។ ខ្លះទៀតរហូតដល់ថ្នាំងថ្នាក់នឹងសហករណ៍នឹងបក្សទៀតផង ។ល ។

២) ពេលស្រួល ពេលទទួលបានជ័យជម្នះជាបន្តបន្ទាប់ យើងជឿជាក់លើរបបសមូហភាពរបស់បក្ស ឃើញថា របបសមូហភាពរបស់បក្សនេះ យុត្តិធម៌ត្រឹមត្រូវ រឹងប៉ឹង ខ្លាំងក្លាណាស់ ។ ប៉ុន្តែ ពេលជួបបរាជ័យបណ្តោះអាសន្នមួយដង មួយកាល ឬជួបការលំបាកស្មុគស្មាញផ្សេងៗ មិត្តយើងបែរជាបាត់ជំនឿលើរបបសមូហភាពលើការដឹកនាំរបស់បក្ស មានការមន្ទិលសង្ស័យ ក្រែងលោរបបសមូហភាព មិនខ្លាំងក្លាដូចរបបឯកជន ។ល ។

៣) ពេលឃើញការខ្វះខាត ឬការប្រហោងខ្លះៗ នៅកន្លែងខ្លះ អង្គភាពខ្លះ ដែលជាបាតុភាព បណ្តោះអាសន្នធម្មតា នៃសម្ភារដែលកំពុងវិវត្តមិត្តយើងខ្លះបែរទៅជាវាយតម្លៃដល់របបសមូហភាពទាំងមូលថាមិនកើត មើលឃើញរបបសមូហភាពអន់ជាងរបបឯកជន ។ល ។

ឧទាហរណ៍ៈ ឃើញគោសហករណ៍ស្គម វិនិច្ឆ័យថា សហករណ៍អន់ជាងឯកជន តែមិនទាន់ឃើញថាអ្នកមើលគោ មិនទាន់មានស្មារតីទទួលខុសត្រូវខ្ពស់ ចំពោះសមូហភាពឡើយ ។

កន្លងមក ដោយមានទស្សនៈខុសឆ្គងយ៉ាងនេះចំពោះរបបសមូហភាព បានជាយុវជន យុវនារីបដិវត្តន៍យើងខ្លះ មិនរីករាយជ្រះថ្លា មិនសកម្មប្រយុទ្ធក្នុងចលនាបដិវត្តន៍ ដែលកំពុងផុសផុល ខ្លាំងក្លាសស្រោកសស្រាំនៅគ្រប់ទិសទីនេះឡើយ ។ ដូច្នេះមិត្តយុវជន-យុវនារីយើងប្រភេទនេះ កសាងខ្លួនយឺត ឬរីកចម្រើនមិនទាន់ចលនា ។ មានយុវជន យុវនារីយើងខ្លះទៀត (ចំនួនតិច) រហូតដល់លាក់ខ្លួន ទៅជាចំណីខ្មាំងបម្រើខ្មាំងបាយកលខ្មាំង រួមសកម្មភាពជាមួយខ្មាំង បំផ្លិចបំផ្លាញ និងក្បត់ប្រទេសជាតិឯង ប្រជាជនឯងយ៉ាងទាបថោកបំផុត ។

ដូច្នេះ យុវជន យុវនារីបដិវត្តន៍យើង ដែលជាអ្នកត្រូវបន្តវេនបដិវត្តន៍តទៅអនាគតទៀត ជាអ្នកទទួលខុសត្រូវ កាន់ក្តាប់ជោគវាសនាប្រទេសជាតិ ប្រជាជន ចលនាបដិវត្តន៍ និងបក្សកុម្មុយនីស្តកម្ពុជា តទៅអនាគតទៀត ចាំបាច់ត្រូវវាយកម្ចាត់ឲ្យស្អាតរលីងគេងនូវទស្សនៈខុសឆ្គងទាំងប៉ុន្មានខាងលើនេះ ហើយខិតខំកសាងបំពាក់បំប៉នឲ្យខ្លួននូវគោលជំហរសមូហភាពវណ្ណៈអធនរបស់បក្ស ឲ្យដល់ខ្លួនជាប់ជានិច្ច ធ្វើឲ្យខ្លួនយើងម្នាក់ៗ ទៅជាកំពែងថែប ការពារប្រទេស ការពារប្រជាជន ការពារបដិវត្តន៍ ការពារបក្ស ការពាររបបសមូហភាព យ៉ាងរឹងប៉ឹងដាច់ខាតជារៀងរហូត ។ ដូច្នេះ ទោះបីស្ថិតក្នុងកាលៈទេសៈលំបាកស្មុគស្មាញយ៉ាងណាក្តី យុវជន យុវនារីបដិវត្តន៍យើង ត្រូវតែឈរ ដាច់ខាតនៅខាងសមូហភាព ជឿជាក់លើរបបសមូហភាពរបស់បក្ស ហើយស្រឡាញ់ពេញចិត្ត និងរបបសមូហភាព និងរីករាយ ថ្លៃថ្លាក្នុងចលនាសមូហភាពជាប់ជានិច្ច ។ ធ្វើយ៉ាងនេះ ទើបយុវជន យុវនារីបដិវត្តន៍យើង រីកចម្រើនឆាប់រហ័ស វិវត្តទាន់ចលនា ហើយដឹកនាំចលនាបដិវត្តន៍យើង បច្ចុប្បន្នក៏ដូចតទៅអនាគតទៀតបានល្អប្រសើរ និងលោតផ្លោះដាច់ខាត ។

**ឆេង ខេង**

# សារទូរលេខទាក់ទងបញ្ហាព្រំដែនរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម

***គោរពជូនសមមបងប៉ុលជាទីស្នេហា និងរលឹក សូមជ្រាប ។***

ខ្ញុំសូមរាយការណ៍ជូនបងពីសភាពការណ៍ នៅតាមព្រំដែន តាមសេចក្ដីរាយការណ៍របស់តំបន់២៣ មានដូចតទៅៈ

**១) នៅស្រុកចន្ទ្រា ៈ**

◆ នៅតាមព្រំប្រទល់ដែនស្រុកចន្ទ្រា មិនទាន់មានបញ្ហាចោទឡើងដោយប្រើអាវុធទេ គ្រាន់តែមានពួកវៀតណាមមួយចំនួនបានអុំទូកចូលមកក្នុងទឹកដីយើង ត្រង់មុំខាងជើងវត្តប្រាសាទ ចម្ងាយ២គីឡូម៉ែត្រពីព្រំដែន ។

◆ ដោយឡែកសភាពការណ៍នៅក្នុងប្រទេសវៀតណាម តាមការស្ដាប់បានផ្ទាល់នឹងសត្យានុម័តិបានឲ្យដឹងថាៈ

ចាប់តាំងពីថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៥ ការប្រយុទ្ធគ្នានៅខាងកើតតាកៅ ចម្ងាយពីព្រំដែនចំនួន១០គីឡូម៉ែត្រ ក្នុងនោះមានកាំភ្លើងតូចធំ រថក្រោះ និងកប៉ាល់ហោះបានបាញ់រះ និងផ្ទោងទម្លាក់គ្រាប់បែកអស់រយៈមួយថ្ងៃមួយយប់ ។

◆ ក្រោយពីនោះមក សកម្មភាពនៅប្រទេសវៀតណាម នៅតែពុះសួរផ្ទុះអាវុធទាំងយប់ទាំងថ្ងៃតែពីសតែពាសទូទាំងប្រទេស ។ សកម្មភាពដែលកើតមានឡើងដូចខាងលើមូលហេតុមកពីមិនឯកភាពគ្នាលើការផារ ចាត់តាំងរដ្ឋអំណាចភូមិឃុំរវាងវៀតណាមខាងជើង និងវៀតណាមខាងត្បូង ។

**២) ស្រុករមាសហែក ៈ**

ចាប់ពីថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១០ឲ្យ៩៧៥ ពួកយួនបានដញ្ជូនកងទ័ពរបស់វា មកនៅតាមខ្សែព្រំដែនជាច្រើន ។ ផ្នែកខាងត្បូង វាចូលមកដល់ភូមិបុល និងភូមិតាខ្វៃ ។ សកម្មភាពនេះ មិនទាន់មានជាសកម្មភាពអ្វីឡើយ ។

**៣) ស្រុកសំរោង ៈ**

កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៥ មានគ្នាវាប្រហែល១០នាក់ បាននាំគ្នាលួចឆ្លងចូលមកក្នុងទឹកដី យើងចម្ងាយ១០០ម៉ែត្រពីព្រំដែន ។ ទន្ទឹមនេះ ពួកវាបានលែងក្របីឲ្យស៊ីស្រូវប្រជាជនយើងនៅភូមិប្រេកក្រពិសខាងត្បូងព្រៃទួលញរហូតដល់ត្រពាំងដើមពោធិ៍អស់ជិតមួយហិកតា ។

◆ ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៧៥ មានកងទ័ពវៀតណាមមួយវរសេនាធំ ដោយមាន ទាំងឡានដឹកកាណុងធុន១០៥មីលីម៉ែត្រ និង១២៥មីលីម៉ែត្រ ចំនួន១៥គ្រឿង និងរថក្រោះ២០ បានធ្វើដំណើរចេញពីទីក្រុងនានា ហើយឈប់សំចតនៅតាមខ្សែព្រំប្រទល់ដែនកម្ពុជាវៀតណាមត្រង់ចំនុច បេនមេតាយ ស្ថិតនៅខាងកើតភូមិក្បាលចាម និងខាងជើងព្រៃចំបក់ ។ នៅពេលដែលមកដល់ភ្លាម ពួកនេះក៏រៀបចំក្បួនយុទ្ធសាស្ត្រជាស្រេច ដោយមានក្រុមផ្នែកដឹកជញ្ជូនគ្រាប់ ចេះតែជញ្ជូនយកមកទុកដាក់នៅកន្លែងរថក្រោះ ។ ចំពោះកាណុងវិញ គឺដាក់មុខតម្រង់ទៅខាងកើតទាំងអស់ ។ លុះដល់ម៉ោង៩ ព្រឹកក្នុងថ្ងៃដដែល ក៏កើតមានការប្រយុទ្ធគ្នានៅត្រង់ផ្លោកអស់ រយៈពេលមួយម៉ោង ដោយមានទាំងកាំភ្លើងធំបាញ់ជួយគាំទ្រអស់រយៈជិត១៥នាទី ។ បន្តិចក្រោយមកក៏មាន យន្តហោះកន្ទុំរុយចំនួន៥ គ្រឿងមកបាញ់រះនៅត្រង់កន្លែងប្រយុទ្ធរហូតដល់ម៉ោងបីរសៀលទើបស្ងប់ ។ ចំពោះប្រជាជនដែលនៅទីក្រុងធំៗ បានដឹកជញ្ជូនអីវ៉ាន់អីវ៉ាន់របស់របរចេញមកនៅផ្សារធ្មង់ និងក្បាល ចាម តាមខ្សែព្រំដែនជា បន្តបន្ទាប់ និងយ៉ាងគគ្រឹកគគ្រេង ។

◆ នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៧៥ដដែល មានពួកយៀកកុងពីរនាក់ ភេទប្រុស មានកាន់អាវុធធុនអាកាពីរដើម រំលោភចូលមកទឹកដី

យើង ត្រង់សារូម ខាងជើងភូមិឈូកសរចម្ងាយ៤០០ម៉ែត្រពីព្រំដែន ។

- នៅព្រឹកថ្ងៃដដែល វេលាម៉ោង១០ព្រឹក មានពួកវាបីនាក់ទៀត ប្រដាប់ដោយអាវុធគ្រប់ដៃ ចូលមកក្នុងទឹកដីយើង នៅភូមិប្រកកំពិស ចម្ងាយពីព្រំដែន២៥០ម៉ែត្រ បណ្តាលឲ្យខូចខាតស្រូវអស់ជាច្រើនកន្លែង ។

**វិធានការការពាររបស់យើង :**

ដូចមានសភាពខាងលើ យើងខ្ញុំគណៈ អ.ច.ត តំបន់២៣ បានមានវិធានការការពារ តាមព្រំប្រទល់ ដែនដូចខាងក្រោមនេះ

១) បានណែនាំទៅរាល់ស្រុកដែលមានសភាពដូចនេះ ឲ្យចាត់តាំងកម្លាំងឈ្លប រួមផ្សំ និងកម្លាំងកងទ័ព ប្រមូលផ្តុំរបស់ស្រុកធ្វើសហការជាមួយគ្នា យាមឃ្លាំមើលការពារខ្មាំង ក៏ដូចជាការពារប្រជាជនវៀតណាម ដែលចេញពីគ្រប់រូបភាព មិនឲ្យធ្វើសកម្មភាពអុកឡុកក្នុងទឹកដីយើងបាន ។

២) លើសកម្មភាពតាមព្រំដែនដែលចេះតែប្រែប្រួលបន្តបន្ទាប់យ៉ាងនេះ គឺបានឲ្យរាល់ស្រុក រាយការណ៍ឡើងមកតំបន់ប្រចាំថ្ងៃ ដើម្បីក្តាប់បាន និងមានវិធានការរាយការណ៍ឡើងទៅខាងលើដែរ ។

- នៅតំបន់២០ មានទិដ្ឋភាពប្លែកដូចជាខ្ញុំរាយការណ៍ជូនបងពីសកម្មភាពនៅតំបន់២៣ ឥឡូវនេះវាឆ្លងមកដល់តំបន់២០ នៅស្រុកមេសាង ព្រៃវែង តាមសេចក្តីរាយការណ៍របស់ស្រុកមេសាង និងព្រៃវែង ថាមានសង្កាត់ព្រៃឃ្នៀសស្រុកមេសាង សង្កាត់ស្វាយអន្ទរស្រុកព្រៃវែង មានត្រីអណ្តែង ត្រីកញ្ចុះ ពស់វែក គ្រប់ធុន សត្វដែលមានពិសងាប់អណ្តែតពាសពេញស្រះ ត្រពាំង បឹង បួរ អូរ ស្ទឹង ។ សត្វទាំងនេះងាប់ យើងយកមកពិនិត្យឃើញមានដំបៅ និងខ្លាចពេញខ្លួនរបស់វា រីឯនៅក្នុងសាច់របស់វាឃើញមានឈាមខ្មៅ មានប្រជាជនរើសត្រីទាំងនោះមកហូប មិនយូរប៉ុន្មានមានជំងឺចុះរាក មានលក្ខណៈអាសន្នរោគ ។ ប្រជាជនខ្លះព្យាបាលទាន់ ខ្លះក៏គ្រោះថ្នាក់ដល់អាយុជីវិត ។

**ខាងយើងខ្ញុំកំពុងមានវិធានការទប់ទល់ដូចតទៅ :**

◆ ជូនដំណឹងដល់គណៈបម្រើប្រជាជនគ្រប់ថ្នាក់ ឲ្យផ្សព្វផ្សាយរឿងនេះដល់ប្រជាជនសហករណ៍ ហាមដាច់ខាតមិនឲ្យរើសត្រី ឬពស់ដែលងាប់ យកទៅហូប ឬធ្វើប្រហុកផ្អក និងបំផុសឲ្យសម្អាតអនាម័យក្នុងភូមិ ហូបរបស់ឆ្អិន ផឹកទឹកឆ្អិន ។ បើមានកន្លែងណាមានជំងឺនេះ ត្រូវឲ្យព័ត៌មានដល់គ្រូពេទ្យជាបន្ទាន់ ។ ចាត់ពេទ្យចល័ត ឲ្យចុះទៅមូលដ្ឋាន ដែលមានកើតជំងឺនេះ ដើម្បីជួយសង្គ្រោះដល់ប្រជាជន ។

◆ ថ្នាំគ្រប់មុខដើម្បីជួយសង្គ្រោះ ឃើញថាខ្សោយមែនទែន បើខាងបងមានលទ្ធភាព សូមផ្តល់ខ្លះនូវថ្នាំ គ្រប់មុខជាពិសេសថ្នាំគ្រុនចាញ់ ។ ចំណែកថ្នាំការពារអាសន្នរោគ ខាងយើងខ្ញុំមានខ្លះហើយ ។ ខ្វះតែថ្នាំព្យាបាលទូទៅ ឧទាហរណ៍ៈ អូរេអូមេស៊ីនទីហ្វ ដែលទប់ទល់នឹងជំងឺគ្រុនក្តៅសន្ធំ និងគ្រុនពោះវៀន ។ និយាយរួមពួក ថ្នាំព្យាបាលទូទៅទាំងភាគ ទាំងតំបន់អស់រលីង ។ ថ្នាំដែលអង្គការផ្តល់មុនៗ ចែកគ្នាបានបន្តិចបន្តួចម្នាក់ប៉ុណ្ណោះ ។

សូមគោរពជូនពរបង មានសុខភាពល្អ និងជ័យជម្នះ

ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៥

ឆុន

ចម្លងជូន

◆ បងខៀវ

◆ បងឌឿន

◆ បងភា

◆ ទុកជាឯកសារមួយច្បាប់

# ហេតុអ្វីបានជាចូលរួមធ្វើបដិវត្តន៍?

ក្រោយរដ្ឋប្រហារទម្លាក់ព្រះនរោត្តម សីហនុ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ពីសំណាក់លោកសេនា ប្រមុខ លន់ នល់ រួចមក ប្រទេសកម្ពុជាដ៏តូចមួយនេះ ដែលធ្លាប់តែរស់នៅក្នុងសុខសន្តិភាព និងសុខដុមរមនា បានធ្លាក់ក្នុងភ្លើងសង្គ្រាមយ៉ាងសន្ធោរសន្ធៅរវាងកងទ័ព លន់ នល់ និងកងទ័ពបដិវត្តន៍ខ្មែរក្រហម ។ ខ្មែរក្រហម គឺជាឈ្មោះដែលសម្តេចព្រះនរោត្តម សីហនុ មានបន្ទូលសំដៅទៅលើក្រុមកុម្មុយនីស្តដែលប្រឆាំងនឹងព្រះអង្គកាលពីទសវត្សរ៍ឆ្នាំ១៩៦០ ។ ទីបំផុត សត្រូវរបស់ព្រះអង្គមួយនេះ បានក្លាយជាដៃគូជាមួយព្រះអង្គក្នុងការប្រយុទ្ធប្រឆាំងជាមួយ លន់ នល់ ដើម្បីដណ្តើមប្រទេសមកគ្រប់គ្រងវិញ ។

នៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ ១៩៧៥ - ១៩៧៩) ដែល សរសេរដោយលោកបណ្ឌិត ឌី ខាំបូលី បានលើកឡើងនូវចំនុចមួយថា «ដោយមានការលើកទឹកចិត្ត និងការជួយជ្រោមជ្រែងពីសំណាក់រដ្ឋាភិបាលចិន រដ្ឋាភិបាលវៀតណាមខាងជើង និងបក្សកុម្មុយនីស្តកម្ពុជា ព្រះនរោត្តម សីហនុ បានបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និងរដ្ឋាភិបាលនិរទេសមួយ ដែលមានឈ្មោះថា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា» ។

តាមរយៈប្រជាប្រិយភាពរបស់សម្តេច សីហនុ បានផ្តល់



យុទ្ធនារីកងសិល្បៈរបស់អង្គការបដិវត្តន៍

ឱកាសយ៉ាងច្រើនដល់ចលនាបដិវត្តន៍ខ្មែរក្រហម ក្នុងការអូសទាញប្រជាជនឲ្យចូលរួមចលនារបស់ខ្លួន ។ ជាពិសេស បន្ទាប់ពីមានការអំពាវនាវពីសំណាក់សម្តេចសីហនុ ឲ្យកូនចៅទាំងអស់ចូលព្រៃម៉ាគី ដើម្បីធ្វើការតស៊ូប្រឆាំងផ្តួលរំលំរបប លន់ នល់ នោះ ចលនាបដិវត្តន៍របស់ខ្មែរក្រហមមានការកើនឡើងយ៉ាងឆាប់រហ័ស ។ រយៈពេលតែជាងបីឆ្នាំប៉ុណ្ណោះ (ឆ្នាំ១៩៧០-១៩៧៣) ចលនាខ្មែរក្រហមបានកើនឡើងពីបីពាន់នាក់ រហូតដល់បួនម៉ឺននាក់ ។ ក្នុងចន្លោះពេលនោះដែរ គ្រាប់បែកជាងកន្លះលានតោនត្រូវបានទម្លាក់មកលើដែនដីដ៏ស្រស់បំព្រងមួយនេះ ពីសំណាក់សហរដ្ឋអាមេរិក ក្រោមហេតុផល ទម្លាក់ដើម្បីបំផ្លាញទីតាំងលាក់ខ្លួនរបស់វៀតណាម (យៀកកុង) ក្នុងប្រទេសកម្ពុជា ។ ការពិតជាក់ស្តែងអ្នកទទួលរងគ្រោះពិតប្រាកដនោះ គឺប្រជាជនស្លូតត្រង់កម្ពុជាដែលរស់នៅទីជនបទ ចុងកាត់មាត់ញក តាមបណ្តោយព្រំដែនខាងកើត ។ ផ្ទះសម្បែង ភូមិស្ថាន ត្រូវបានខ្ទេចខ្ទីទៅជាផេះផង់ ប្រជាជនត្រូវភៀសខ្លួនចេញពីផ្ទះសម្បែង ដើម្បីរកកន្លែងសុវត្ថិភាពពីការទម្លាក់គ្រាប់បែក ។ ជាលទ្ធផលប្រជាជនខ្មែររាប់សែននាក់ បានស្លាប់និងរបួស ដោយសារការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ។

ដោយមានការឈឺចាប់នឹងទង្វើដ៏ព្រៃផ្សៃពីសំណាក់សហរដ្ឋអាមេរិក ទើបធ្វើឲ្យប្រជាជនដែលបាត់បង់ផ្ទះសម្បែង ស្រែចម្ការ និងសមាជិកគ្រួសារទាំងនោះ សម្រេចចិត្តចូលរួមធ្វើតស៊ូបដិវត្តន៍ជាមួយចលនាខ្មែរក្រហម ។ តាមរយៈបទសម្ភាសន៍របស់ខ្ញុំជាមួយស៊ីវ តេង ដែលជាអតីតយុទ្ធជនម្នាក់ក្នុងរបបខ្មែរក្រហម បានឲ្យដឹងថា គាត់ចូលរួមតស៊ូ គឺចង់រួចផុតពីការជិះជាន់ កេងប្រវ័ញ្ច ពីសំណាក់ពួកនាយទុន សក្តិភូមិ ។

ស្ថិតក្នុងត្រកូលកសិករក្រីក្រគោកយ៉ាកមួយ ដែលរស់នៅស្រុកឈូក ខេត្តកំពត គ្រួសាររបស់ តេង ត្រូវរស់នៅយ៉ាងលំបាក ដោយធ្វើស្រែចម្ការ មិនទាំងគ្រប់បង់ការប្រាក់ឲ្យម្ចាស់បំណុលផង ។ នៅទីបំផុត ដីស្រែដែលជាអាយុជីវិតតែមួយគត់របស់គ្រួសារ តេង ត្រូវម្ចាស់បំណុលរឹបអូសយក ។ ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ ខ្មែរក្រហមបានចុះមកឃោសនាអប់រំ ពីការតស៊ូវណ្ណៈ ប្រឆាំងនឹងសក្តិភូមិ នាយទុន ប្រតិកិរិយា ជាដើម ហើយ តេង ក៏ដូចជា អ្នកភូមិជាមួយគ្នា ក៏សម្រេចចិត្តចូល រួមធ្វើបដិវត្តន៍ជាមួយខ្មែរក្រហមតាំងពីពេលនោះមក ។

មិនខុសអ្វីនឹង កែវ វឿន ដែលជាអតីតប្រធានវរសេនាតូចរបស់ខ្មែរក្រហមនោះទេ ជាកសិករដែលរស់នៅភូមិដាច់ស្រយាលមួយនៃខេត្តកំពង់ឆ្នាំង វឿន ស្ម័គ្រចិត្តចូលរួមតស៊ូបដិវត្តន៍នៅឆ្នាំ ១៩៧០ ហេតុផលតែមួយដែលបណ្តាលឲ្យគាត់ចូលរួមគឺ ធ្វើការតស៊ូវណ្ណៈ ប្រឆាំងនឹងរបបសក្តិភូមិ ។

មុន និងក្រោយរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ការចុះឃោសនារបស់ខ្មែរក្រហម គឺមានស្ថានភាពខុសគ្នា ដោយតំបន់ខ្លះឃោសនាពីរឿងតស៊ូវណ្ណៈ ប្រឆាំងនឹងរបបនាយទុន សក្តិភូមិ ប្រតិកិរិយា ចក្រពត្តិនិយម និងតំបន់ខ្លះទៀត ឃោសនាពីការតស៊ូផ្តួលរំលំរបបសាធារណរដ្ឋខ្មែរ ដើម្បីដណ្តើមអំណាច និងនាំ យកសម្តេចឲ្យមកគ្រប់គ្រងប្រទេសវិញ ។ ជាក់ស្តែង ពុំ ខូ ដែលជាអតីតគណៈស្រុកព្រះនេត្រព្រះ ជាកម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់មួយរូប ដែលរួចជីវិតពីការធ្វើបន្សុទ្ធកម្មផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងអំឡុងឆ្នាំ១៩៧៧ បានឲ្យដឹងថា នៅឆ្នាំ១៩៧១ គាត់បានចាកចេញពីភូមិកំណើត និងគ្រួសារចូលព្រៃតស៊ូប្រឆាំងនឹងរបប លន់ នល់ ដើម្បីដណ្តើមអំណាចថ្វាយសម្តេចឪវិញ ។ ក្នុងការងារតស៊ូ ខូ បានចុះឃោសនាប្រជាជនពីមាគ៌ារបស់បដិវត្តន៍ ។ នៅទីបំផុត ខូ ស្ទើរតែមិនអាចរក្សាជីវិតខ្លួនឯងបានពីការធ្វើបន្សុទ្ធកម្មរបស់បក្ស ។ ខូ រួចជីវិតបានដោយសារ តែកម្មាភិបាលដែលមកពីខាងភូមិភាគនិរតី ទុកសម្រាប់ជួយសម្រួលការងារចាប់ចង និងដឹកនាំប្រជាជន ពីព្រោះអ្នកមកពីភាគនិរតីទាំងនោះ មិនស្គាល់ភូមិសាស្ត្រ និងកម្មាភិបាលដឹកនាំចាស់នៅតាមឃុំ តាមសហករណ៍ក្នុងស្រុកព្រះនេត្រព្រះទេ ។

ដូចអ្វីដែល អ៊ុន ភឿន លើកឡើងក្នុងកិច្ចសម្ភាសជាមួយគាត់ដែរ គឺដោយសារ ការគោរព ស្រឡាញ់ សម្តេច សីហនុ ហេតុនេះគាត់បានចូលរួមធ្វើបដិវត្តន៍ដើម្បីសម្តេចឪ ។ ភឿន គឺជាអតីតមេក្រុមពិសេសផ្នែកជើងទឹក ឈរជើងនៅកោះពូលូវៃ និងកោះក្រចកសេះ ។ ភឿន បានស្ម័គ្រចិត្តចូលបដិវត្តន៍នៅឆ្នាំ១៩៧០ តាមរយៈខ្មែរក្រហម ដែលចុះមកឃោសនានៅក្នុងភូមិរបស់គាត់ ។ នៅពេលនោះមិនមែនតែគាត់ម្នាក់ទេ ដែលចូលរួម គឺមានប្រជាជនយុទ្ធជនយុទ្ធនារីជាច្រើនទៀត ។

ក្រោយជ័យជម្នះ ១៧ មេសា ឆ្នាំ១៩៧៥ របស់កងទ័ពរំដោះខ្មែរក្រហម ប្រជាជនម្នាក់ៗ ក៏ដូចជាទាហាន លន់ នល់ ដែលបាក់ទ័ពចុះចាញ់ មានសេចក្ដីរីករាយយ៉ាងខ្លាំង ជាពិសេសអ្នករស់នៅទីក្រុងភ្នំពេញ ព្រោះអ្នកគ្រប់គ្នាសង្ឃឹមក្នុងចិត្តថា ប្រទេសកម្ពុជា ដែលធ្លាប់តែញាំញីដោយសារសង្គ្រាម៥ឆ្នាំមកនេះ នឹងមានសុខសន្តិភាពដូចពីមុន ហើយខ្មែរក៏ឈប់បង្ហូរឈាមខ្មែរដូចគ្នាទៀតដែរ ។ ប្រជាជនបានចេញមកស្វាគមន៍កងទ័ពរំដោះ ដោយមានចងទង់ជ័យស ជាសញ្ញានៃសន្តិភាព នៅតាមមុខផ្ទះរៀងៗខ្លួន ។ តែភាពរីករាយប្រកបដោយក្ដីសង្ឃឹមនេះ បានរលាយបាត់ទៅវិញ ដែលជំនួសដោយភាពភ័យខ្លាច ស្រឡាំងកាំង នឹកស្មានមិនដល់ បន្ទាប់ពីឮការប្រកាសឲ្យប្រជាជនទាំងអស់ចេញពីផ្ទះរយៈពេលបីថ្ងៃសិន ។ សំឡេងហៅរកបងប្អូន ប្រពន្ធកូន សំឡេងក្មេងយំរំពុងឪពុកម្ដាយ សំឡេងថ្ងូចថ្ងូររបស់អ្នកជំងឺ សំឡេងសម្លុតគំរាមកំហែងពីសំណាក់កងទ័ពអាវខ្មៅ បានឮទ្រហឹងពេញទីក្រុងភ្នំពេញ ។

រឿងដែលនឹកស្មានមិនដល់នេះ មិនត្រឹមតែកើតមានចំពោះប្រជាជននោះទេ សូម្បីតែខ្មែរក្រហមខ្លួនឯងមួយចំនួន ក៏មិនបានដឹងពីអ្វីដែលនឹងកើតឡើងបន្ទាប់ទៀតដែរ ។ ស៊ុំ សុខន បានរៀបរាប់ប្រាប់ខ្ញុំថា គាត់ស្ម័គ្រចិត្តចូលធ្វើបដិវត្តន៍ គឺដើម្បីទាមទារអំណាចថ្វាយសម្ដេចឪវិញ ។ តែទីបំផុត បន្ទាប់ពីជ័យជម្នះ ១៧មេសា ឆ្នាំ១៩៧៥ នេះ គឺមិនដូចអ្វីដែលខ្មែរក្រហមធ្លាប់សន្យានោះទេ ។ អ្វីៗហាក់ប្រែប្រួលអស់ សូម្បីតែកងរបស់គាត់ ក៏ត្រូវអង្គការដកហូតអាវុធ បន្ទាប់ពីស្នាក់នៅទីក្រុងភ្នំពេញ បានប៉ុន្មានខែប៉ុណ្ណោះ ហើយត្រូវបញ្ជូនឲ្យទៅធ្វើស្រែវិញ ។ សុខន បានឲ្យដឹងថា ការងារកងទ័ព គឺដឹងតែការងារខ្លួនឯងប៉ុណ្ណោះ ចំពោះរឿងរ៉ាវខាងក្រៅមិនដឹងនោះទេសូម្បីតែរឿងគ្រួសារ ព្រោះអង្គការតែងតែប្រាប់ថា ឲ្យខំប្រឹងធ្វើការទៅ ចំពោះគ្រួសារនៅខាងក្រោយ អង្គការមើលថែទាំទំនុកបម្រុងបានល្អហើយ ។ ក្រោយរបបខ្មែរក្រហមដួលរលំ សុខន ស្ទើរតែមិនជឿចំពោះអ្វីដែលបានកើតឡើងចំពោះប្រជាជនកម្ពុជារាប់ម៉ឺននាក់ ដែលបានស្លាប់ដោយសារ អត់អាហារ ជំងឺ ធ្វើការហួសកម្លាំង និងសម្លាប់ ។ ទីបំផុត បងប្អូនប្រុសបីនាក់ដែលចូលបដិវត្តន៍ ជាមួយគ្នា គឺមានតែគាត់ម្នាក់ប៉ុណ្ណោះ ដែលមានជីវិតរស់ ហើយគាត់ពិតជាចង់ដឹងណាស់ថា តើមានអ្វីកើតឡើងចំពោះបងប្អូនទាំងពីររបស់គាត់ ។

ផ្ទុយពីអ្វីដែលខ្ញុំបានលើកឡើងខាងលើអំពីការស្ម័គ្រចិត្តចូលរួមធ្វើបដិវត្តន៍រំដោះប្រទេស តស៊ូវណ្ណៈ និងដណ្ដើមអំណាចថ្វាយសម្ដេចឪនោះ យ៉ែម ហ៊ុន ជាអតីតយោធាខ្មែរក្រហមមួយរូប នៅក្នុងកិច្ចសម្ភាសន៍បានប្រាប់ថា គាត់ចូលរួមតស៊ូបដិវត្តន៍នេះមិនមែនដោយការស្ម័គ្រចិត្តនោះទេ គឺដោយសារតែមានការគាបសង្កត់ពីមេឃុំ និងមេភូមិ ដែលគាត់រស់នៅ ។ អ្នកទាំងនោះ តែងតែធ្វើទុកបុកម្នេញចំពោះគ្រួសារដែលមានកូនមិនឲ្យចូលធ្វើយោធា ។ ដោយទ្រាំមិនបាននឹងការបង្ខិតបង្ខំ និងដើម្បីរួចផុតពីការធ្វើបាបគ្រប់ពេលបែបនេះ នៅឆ្នាំ១៩៧២ ហ៊ុន បានសម្រេចចិត្តចូលធ្វើយោធាខ្មែរក្រហម នៅស្រុកកំពង់សៀម រហូតដល់ថ្ងៃដែលរបបខ្មែរក្រហមត្រូវបានបញ្ចប់ ។

តាមរយៈការសម្ភាសរបស់ខ្ញុំផ្ទាល់ជាមួយនឹងបងប្អូនអតីតខ្មែរក្រហម និងកិច្ចសម្ភាសនានារបស់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលចុះសម្ភាសផ្ទាល់ជាមួយអតីតយុទ្ធជន យុទ្ធនារីកម្មាភិបាលខ្មែរក្រហមទាំងនោះ បានបង្ហាញឲ្យឃើញថា ហេតុផលដែលអ្នកទាំងអស់គ្នាចូលរួមធ្វើបដិវត្តន៍ ស្ទើរតែមានភាពដូចគ្នា ។ ដូចជាអ្វីដែលខ្ញុំបានលើកឡើងនៅក្នុងអំណោះអំណាងខាងលើស្រាប់ គឺ តស៊ូដើម្បីប្រឆាំងវណ្ណៈសក្ដិភូមិ នាយទុន ប្រតិកិរិយា ប្រឆាំងនឹងចក្រពត្តិអាមេរិក និងផ្ដួលរំលំរបបសាធារណរដ្ឋខ្មែរ ដើម្បីដណ្ដើមអំណាច និងប្រទេសថ្វាយសម្ដេច ព្រះនរោត្តម សីហនុ វិញ ។ ខ្មែរក្រហមបានយកព្រះកិត្តិនាមរបស់សម្ដេចឪ ដើម្បីធ្វើការអូសទាញទឹកចិត្តប្រជាជនដែលស្រឡាញ់ និងគោរពព្រះអង្គ ហើយខ្មែរក្រហមក៏ទទួលបាននូវការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់ប្រជាជននាពេលនោះដែរ ។ ភ្លាមៗបន្ទាប់ពីជ័យជម្នះ ខ្មែរក្រហមបានប្រកាសទៅកាន់ប្រជាជនទាំងអស់ថា អ្នកដែលធ្លាប់ធ្វើការពីមុនមក សូមមកចុះឈ្មោះដើម្បីទៅធ្វើការនៅកន្លែងចាស់ វិញ អង្គការត្រូវការអ្នកទាំងអស់គ្នា ដើម្បីទៅទទួលសម្ដេចឪ និងកសាងប្រទេសឡើងវិញ ។ ពេលនោះ អតីតអ្នករដ្ឋការ ប៉ូលីស ទាហានជាច្រើន បាននាំគ្នាទៅចុះឈ្មោះតាមការប្រកាស ។ ជាចុងក្រោយ ពុំមាននរណាម្នាក់ដឹងដំណឹង និងដោគវាសនារបស់អ្នកដែលចុះឈ្មោះទាំងនោះឡើងសូម្បីតែក្រុមគ្រួសាររបស់អ្នកទាំងនោះផ្ទាល់ ។

**ឆាយ សារៈមុនិន្ទ**

# នីរសារ និង អ្នកបើកឡានឱ្យ សោ ភឹម «ខ្ញុំរស់ជីវិតដោយសារលាក់ខ្លួន»

រស់នៅក្នុងផ្ទះសង់ពីឈើ ប្រក់ស័ង្កសីចាស់ទ្រុឌទ្រោម នៅឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ រួមជាមួយជំងឺផ្លូវដង្ហើមប្រចាំកាយក្នុងវ័យ៦៨ឆ្នាំ នង នឹម បានរៀបរាប់ថា "គាត់ត្រូវជាបងប្អូនជីដូនមួយ ជានីរសារ និងជាអ្នកបើកឡានឲ្យ សោ ភឹម លេខាភូមិភាគបូព៌ា ដែលខ្មែរក្រហមតាមចាប់ខ្លួនដោយចោទថា ក្បត់" ។ នឹម បានរួចរស់ជីវិតពីការតាមសម្លាប់ ដោយសារតែគាត់លាក់ខ្លួន និងលាក់ប្រវត្តិរូបជាមួយយោធាខ្មែរក្រហម ហើយរហូតមកដល់សព្វថ្ងៃនេះ ក៏គាត់មិនដែលនិយាយពីប្រវត្តិរបស់គាត់ប្រាប់ដល់អ្នកភូមិដែលរស់នៅក្បែរខាងដែរ ដោយសារតែគាត់ខ្លាចមានការស្អប់ខ្ពើម និងការគុំគួន ព្រោះតែគាត់ជាអតីតយោធាខ្មែរក្រហម ។

នឹម មានស្រុកកំណើតនៅភូមិថ្មី ឃុំគគីរសោម ស្រុកស្វាយទាប ខេត្តស្វាយរៀង ។ នឹម មានឪពុកឈ្មោះ យស និងម្តាយឈ្មោះ សោ និងមានបងប្អូនបង្កើតចំនួន៤នាក់ (ស្រី១ ប្រុស២) ហើយគាត់ជាកូនពៅ ។ នឹម ត្រូវជាបងប្អូនជីដូនមួយជាមួយ សោ ភឹម ព្រោះម្តាយរបស់ សោ ភឹម ត្រូវជាបងប្អូនរបស់ម្តាយ នឹម ។

កាលពីកុមារ នឹម រៀនបានត្រឹមថ្នាក់ទី១០ ក៏ឈប់រៀន ហើយមកឃ្វាលគោ និងជួយធ្វើស្រែឪពុកម្តាយវិញ ។ នៅឆ្នាំ១៩៧១ នឹម បានចាកចេញពីស្រុកកំណើតមករស់នៅស្រុកឆ្លូង ខេត្តក្រចេះ ដោយកាលណោះ ឈ្មោះ ឌុល ត្រូវជាបងជីដូនមួយរបស់ នឹម និងជាប្អូនបង្កើតរបស់ សោ ភឹម ជាអ្នកនាំមក ។ ឌុល បានប្រគល់ នឹម ទៅឲ្យ សោ ភឹម ហើយ សោ ភឹម ក៏បានជ្រើស នឹម ឲ្យធ្វើជាអង្គរក្សគាត់ផ្ទាល់ ។ នឹម បានស្នាក់នៅជាមួយ សោ ភឹម នៅមន្ទីរដែលត្រូវបាន


នង នឹម ថតនៅមុខផ្ទះរបស់គាត់ នៅឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ

សាងសង់ឡើងនៅក្នុងព្រៃ និងមានកងការពារសរុបទាំងអស់១២ នាក់ រួមមានឈ្មោះ ម៉េង, គីម ជាសាច់ញាតិប្រពន្ធ សោ ភឹម (មានស្រុកកំណើតនៅមុំវត្តថ្កូវ ឃុំថ្កូវ ស្រុកកំចាយមា ខេត្តព្រៃវែង), ជឿក (ត្រូវជាក្មួយជីដូនមួយ សោ ភឹម) និងកងការពារមួយចំនួនទៀតដែលគាត់មិនចាំឈ្មោះ ។

នីម ធ្វើការនៅស្រុកឆ្លូងបានរយៈពេលជិតមួយឆ្នាំ ទើបគាត់ផ្លាស់មកនៅឃុំរកាខ្នុរ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ដោយគាត់ត្រូវបានចាត់តាំងឲ្យប្រចាំការនៅមន្ទីរការពារតែម្តង ។ បន្ទាប់ពីស្នាក់នៅរកាខ្នុរបានមួយឆ្នាំ នីម ក៏បានផ្លាស់ទៅនៅមន្ទីរសំរោង ស្ថិតនៅភូមិសំរោង ឃុំដូនតី ស្រុក ពញាក្រែក ខេត្តកំពង់ចាម ជាមួយ សោ ភឹម ទៀត ។ នៅក្នុងមន្ទីរសំរោង មានកងការពារថ្មី ចាស់សរុបទាំងអស់ជាង៣០ នាក់ តែកងការពារដែលនៅផ្ទាល់ជាមួយ សោ ភឹម មានតែ១២នាក់ប៉ុណ្ណោះ ។ កងការពារថ្មីទាំងអស់នោះ សោ ភឹម ជាអ្នកជ្រើសរើសផ្ទាល់ ដោយពុំចាំបាច់ហាត់រៀនក្បួនយុទ្ធសាស្ត្រការពារទេកាលពីជំនាន់នោះ ។ សោ ភឹម បានជ្រើសរើសកងការពារថ្មីៗមកជំនួសកងការពារចាស់ ព្រោះកងការពារចាស់ៗគាត់ចាត់តាំងឲ្យទៅគ្រប់គ្រងនៅតាមអង្គភាពទ័ពវិញ ដែលភាគច្រើនទៅធ្វើជាមេទ័ពតែម្តង ។

នៅឆ្នាំ១៩៧៣ នីម បានចាប់ផ្តើមរៀនបើកបររថយន្ត ។ ក្រោយពីចេះបើកស្ទាត់ហើយ សោ ភឹម ក៏ឲ្យ នីម បើកជំនួស សំ (អតីតអ្នកបើកឡានឲ្យគាត់តាំងពីឆ្នាំ១៩៧១) រួចផ្លាស់ សំ ឲ្យទៅធ្វើការនៅអង្គភាពផ្សេងវិញ ។ ឡានដែល នីម បើកនៅសម័យនោះ មានដូចជា ម៉ែកសឺដេស, តូយូតា, សូឡេ, ឡង់រ៉ូវែរ និង ហ្ស៊ីបអាជី ។ នីម បានបើកឡានជូន សោ ភឹម ចុះទៅធ្វើការនៅស្រុកដែលពេលចុះទៅម្តងៗមានគ្នា១២នាក់ និងឡានពីរគ្រឿង ហើយពេលខ្លះក៏មានម៉ូតូអមទៅជាមួយដែរ ។ កងការពារទាំងអស់ កាន់កាំភ្លើងគ្រប់ដៃ មានដូចជា អាកា រ៉េបាដេ និងបេ ដែលមានឈ្មោះ ចេង ប្រធានកងការពារជាអ្នកចាត់ចែង ។ ចំពោះកងការពារទាំងអស់ សោ ភឹម មិនដែលស្តីបន្ទោស និងរករឿងទេ ប៉ុន្តែនៅពេលកងការពារទាំងនោះធ្វើខុស គឺ ចេង ជាអ្នកហៅមកអប់រំ និងកសាង ។ ក្រៅពីធ្វើជាប្រធានកងការពារ ចេង ក៏មានតួនាទីជាស្មៀនផ្ទាល់របស់ សោ ភឹម ដែរ ហើយរាល់ការសរសេរសំបុត្រឆ្លងឆ្លើយរវាងតំបន់ មន្ទីរ និងភូមិភាគ គឺ ចេង ជាអ្នករៀបចំចាត់ចែងសរសេរទាំងអស់ ។ ក្នុងចំណោមកងការពាររបស់ សោ ភឹម ១២នាក់ គឺមានតែអ្នកនៅខាងផ្នែកចុងភៅឈ្មោះ សុទ្ធ (ស្លាប់ជាមួយ សោ ភឹម) ប៉ុណ្ណោះដែលជិតស្និទ្ធនឹង សោ ភឹម ។ ព្រមជាមួយនោះ សោ ភឹម ក៏មានពេទ្យឈ្មោះនារី ឈុនលី ក្រោយពេលពេទ្យឈ្មោះ សែន (ផ្លាស់ចេញទៅ) នៅប្រចាំការព្យាបាលគាត់ដែរ ព្រោះគាត់មានជំងឺរមាស់នៅត្រង់ក្បាល ។




ទន្ទឹមនោះ នីម ក៏មានភារកិច្ចបើកឡានជូន សោ ភឹម ទៅប្រជុំនៅភ្នំពេញ តាមការកោះហៅរបស់ ប៉ុល ពត រយៈពេលមួយខែម្តងដែរ ដោយ សោ ភឹម ជិះឡានឡង់រ៉ូវែររបស់គាត់ផ្ទាល់ ។ ចំណែកកងការពារជិះឡានហ្ស៊ីបអាជី ។ ពេលជូន សោ ភឹម ទៅដល់កន្លែងប្រជុំ នីម ត្រូវទៅឈប់ចាំនៅមន្ទីរពាណិជ្ជកម្មភូមិភាគបូព៌ា (នៅទល់មុខវត្តខណ្ឌលោម) ។

ក្រៅពីបើកឡានជូន សោ ភឹម ចុះទៅធ្វើការនៅតាមក្រសួង មន្ទីរ តំបន់ ស្រុក នៅក្នុងភូមិភាគបូព៌ា និងនៅភ្នំពេញ នីម បានជូន សោ ភឹម ពីកំពង់ចាមកាត់តាមព្រែកក្តាមទៅធ្វើការ និងទៅលេងនៅភូមិភាគពាយ័ព្យ មួយឆ្នាំពីរដងទៀត ព្រោះកូនស្រីរបស់ សោ ភឹម ឈ្មោះ ស៊ី បានរៀបការជាមួយកូនរបស់ រស់ ញឹម ជាលេខាភូមិភាគពាយ័ព្យឈ្មោះ ជាល នៅរកាខ្នុរ តាំងពីក្រោយពេលបែកភ្នំពេញឆ្នាំ១៩៧៥ (រួចហើយបាននាំគ្នាទៅរស់នៅស្វាយស៊ីសុផុន) ។ ការរៀបការ រវាង ជាល និង ស៊ី គឺឪពុកម្តាយជាអ្នករៀបចំឲ្យ ព្រោះ សោ ភឹម និង រស់ ញឹម ជាមិត្តភក្តិជិតស្និទ្ធនឹងគ្នាតាំងពីសម័យតស៊ូនយោបាយ និងប្រដាប់អាវុធ ។ កូនប្រសារ សោ ភឹម ជាមនុស្សចូលចិត្តនិយាយលេងច្រើន មានមាឌល្អិត និងមានសម្បុរខ្មៅ ។ នីម បានបើកឡានជូន សោ ភឹម ទៅលេង និងទៅនៅសម្រាកនៅកន្លែង

ជន្ទងរបស់គាត់ នៅមន្ទីរភូមិភាគពាយ័ព្យ ក្នុងក្រុងបាត់ដំបង ។ សោ ភឹម និង ញឹម មានអាយុស្របាលគ្នា ហើយនៅពេលជួបគ្នាម្តងៗ គាត់ទាំងពីរនាក់តែងតែនិយាយលេងសើចរកគ្នា ដូចជា សោ ភឹម ហៅ រស់ ញឹម ថា "អាសៀម" ចំណែក រស់ ញឹម វិញហៅ សោ ភឹម ថា "អាយួន" ។ អ្នកទាំងពីរបានហូបបាយជុំគ្នា តែមិនមានពិធីជប់លៀង ឬផឹកស្រានោះទេ ។ សោ ភឹម ជាមនុស្សចូលចិត្តហូបម្ហូបសាមញ្ញតាមបែបអ្នកស្រុកស្រែ ដូចជា សម្ងនទោង ក្តិបឪឡឹក និងសម្លម្ជូរជាមួយត្រីជាដើម ។ បន្ទាប់ពីស្នាក់នៅបាត់ដំបងរយៈពេល ២-៣ថ្ងៃ តាញឹម ក៏បានជូនដំណើរ សោ ភឹម ទៅលេងនៅប្រាសាទអង្គរវត្ត ខេត្តសៀមរាប ។ នៅឱកាសនោះដែរ សោ ភឹម ក៏បានទៅសម្រាកនៅកន្លែងកូនប្រសារ និងកូនស្រីរបស់គាត់ នៅមន្ទីរតំបន់៥ (ស្ថិតនៅម្តុំផ្សារស្វាយស៊ីសុផុន) រយៈពេលពីរបីថ្ងៃទៀត ទើបគាត់ត្រឡប់ មកភូមិភាគបូព៌ាវិញ ។

ចំណែក រស់ ញឹក ក៏មកលេង សោ ភឹម និង ប្រពន្ធរបស់ សោ ភឹម ឈ្មោះ ផាន (ហៅ យាយការ៉ូ) នៅមន្ទីរកសិដ្ឋានទួលព្រាប និងទួលសំរោង រយៈពេលមួយឆ្នាំពីរដងដែរ ។ ពេល រស់ ញឹម មកម្តងៗ មានឡានពីរគ្រឿងម៉ាកហ្ស៊ីបអាជី និងមានអង្គរក្សមួយចំនួនមកជាមួយ ហើយគាត់ស្នាក់នៅតែរយៈពេល២-៣បីថ្ងៃប៉ុណ្ណោះ ក៏ត្រឡប់ទៅវិញហើយ ។

ក្រោយមក សោ ភឹម បានផ្លាស់ទៅធ្វើការនៅមន្ទីរមួយទៀត គឺមន្ទីរការពារនៅសួង ហើយពេលនោះ អង្គការក៏បានចាប់ផ្តើមបែងចែកតំបន់រដ្ឋបាលគ្រប់គ្រងរបស់ខ្លួនដែរ ដូចជា តំបន់២០ មានមន្ទីរតំបន់ ស្ថិតនៅភូមិអង្គរ ឃុំដូនតី ស្រុកពញាក្រែក (ខេត្តកំពង់ចាម) គ្រប់គ្រងដោយ តាស៊ុន, តំបន់២១ មានមន្ទីរតំបន់ស្ថិតនៅតាប៉ាវ ម្តុំចម្ការកៅស៊ូជប់ ស្រុកត្បូងឃ្មុំ (ខេត្តកំពង់ចាម) គ្រប់គ្រងដោយ តាសុត, តំបន់២២ គ្រប់គ្រងដោយ តាវែង ហៅ ឈាន, តំបន់២៣ មានមន្ទីរតំបន់ (ស្ថិតនៅក្រុងស្វាយរៀង) គ្រប់គ្រងដោយ តាគួន និង តំបន់២៤ មានមន្ទីរតំបន់ស្ថិតនៅភ្នំឈើកាច់ ស្រុកបាភ្នំ (ខេត្តព្រៃវែង) គ្រប់គ្រងដោយ តាឈូក ។ ចំណែក ភូមិភាគបូព៌ាទាំងមូល សោ ភឹម ជាអ្នកគ្រប់គ្រង ដោយមាន តាសេង ហុង ជាអនុប្រធាន និង តាពាម ជាសមាជិក ។

អំឡុងពេលនោះ នួន ជា ក៏ខស្សាចុះមកធ្វើការ និងមកជួបប្រជុំជាមួយ សោ ភឹម ដែរ ហើយពេលមកម្តងៗមានគ្នា៤-៥នាក់ រួមជាមួយ កងពារ និងឡាន៤-៥គ្រឿងទៀត ។ នីម បានស្គាល់ នួន ជា ច្បាស់ជាង ប៉ុល ពត ព្រោះគាត់ទើបតែឃើញ ប៉ុល ពត ក្រោយពេលបែកភ្នំពេញឆ្នាំ១៩៧៥ ប៉ុណ្ណោះ ។ ពេលខ្លះ ប៉ុល ពត និង នួន ជា ចុះមកធ្វើការជាមួយ សោ ភឹម រួមគ្នា ហើយពេលខ្លះបានចុះមកឆ្លាស់គ្នា ។ អ្នកទាំងបីធ្វើការស្និទ្ធស្នាលនឹងគ្នា ។ ក្រៅពីមេដឹកនាំទាំងពីរ យូរៗ ម្តង នីម ឃើញ វន វេត រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច, សុន សេន រដ្ឋមន្ត្រីក្រសួងការពារជាតិ និង អៀង សារី រដ្ឋមន្ត្រីក្រសួងការបរទេស បានចុះមកធ្វើការជាមួយ សោ ភឹម ដែរ ។ រហូតដល់មានព្រឹត្តិការណ៍ជម្លោះព្រំដែនជាមួយវៀតណាម ទើប នីម ឃើញ កែ ពក លេខាភូមិភាគកណ្តាល បានចុះមកធ្វើការជាមួយ សោ ភឹម បន្ថែមទៀត និងបានបោះមូលដ្ឋានទ័ពរបស់ខ្លួន (ទ័ពរបស់ កែ ពក) នៅមន្ទីរទួលសំរោង ។ ខណៈនោះ នីម ក៏ឃើញភ្ញៀវបរទេស ដូចជា កូរ៉េ និង ចិន បានចុះមកធ្វើទស្សនកិច្ច និងពិនិត្យមើលកសិករដាំស្រូវនៅវាលស្រែ និងដាំពោតនៅតាមចម្ការ ក្នុងភូមិភាគបូព៌ា ដែរ ។

មេដឹកនាំធំៗទាំងនោះ បានចុះមកធ្វើការជាមួយ សោ ភឹម រហូតដល់មានព្រឹត្តិការណ៍ចាប់កម្មាភិបាលខាងភូមិភាគបូព៌ា នៅឆ្នាំ១៩៧៧ ទើប នីម លែងឃើញមេខ្មែរក្រហមទាំងនោះចុះមកធ្វើការជាមួយ សោ ភឹម ទៀត ។ ប៉ុន្តែ ឃើញមានកម្មាភិបាលនៅតាមក្រសួង មន្ទីរ តំបន់ និងស្រុក នៅចុះឡើងធ្វើការជាមួយ សោ ភឹម ដដែល ។ ចំណែក នីម ក៏ខស្សាហ៍ជូន សោ ភឹម ទៅប្រជុំនៅតាមតំបន់ និងស្រុកដែរ តែត្រូវមកសម្រាកនៅតាមមន្ទីរតំបន់វិញ ដែលនៅពេលនោះមានកម្មាភិបាលជាច្រើនបានស្គាល់ នីម ។ នៅពេលប្រជុំម្តងៗ មានរយៈពេលប្រមាណមួយម៉ោង ហើយ នីម ក៏មិនដែលបានចូលទៅប្រជុំជាមួយ សោ ភឹម ដែរ គឺគាត់រង់ចាំនៅខាងក្រៅ ។ រហូតដល់ពេលប្រជុំ ចប់ ទើប នីម បើកឡានទៅទទួល សោ ភឹម ចាកចេញតែម្តង ដោយមិនមានពិធីជប់លៀងទេ ។ ស្របពេលនោះ នីម ក៏បានជូន សោ ភឹម ទៅប្រជុំជាមួយ តាសាឡាត់ ហៅ ស៊ឹម គណៈស្រុកពញាក្រែកដែរ ព្រោះប្រពន្ធ តាឡាត់ និងប្រពន្ធ សោ ភឹម ត្រូវជាបងប្អូនជីដូនមួយគ្នា ។

ក្រោយមក សោ ភឹម បានចាកចេញពីមន្ទីរការពារនៅសួង មកនៅមន្ទីរកសិដ្ឋានទួលព្រាបវិញ ។ ស្រាប់តែរយៈពេល៤-៥

ថ្ងៃក្រោយមក កងទ័ពមជ្ឈិមរបស់ ប៉ុល ពត បានបាញ់ផ្លោងដាក់មន្ទីរការពាររបស់ សោ ភឹម នៅស្វាង ។ តែក៏មានការវាយទប់តបតពីសំណាក់កងទ័ពភូមិភាគបូព៌ា ដែលប្រមូលផ្ដុំ និងបង្កើតឡើងដោយ ម៉ៅ ភោគ (ហៅ កង០៩) នៅមុំវត្តវិហារទន្ទឹមវិញដែរ ។ នៅក្នុងហេតុការណ៍នោះ សោ ភឹម បានចាត់តាំង នីម ឲ្យជិះម៉ូតូរត់សំបុត្រពីមន្ទីរទួលព្រាបទៅកង ពលលេខ៥ ស្ថិតនៅភូមិហួច ស្រុកមេមត់ ដែលមាន សមមិត្ត គឹម ជាលេខា និងកងពលលេខ៤ ស្ថិតនៅភូមិអន្ទង់ជ្រៃ ស្រុកពញាក្រែ ដែលមាន សមមិត្ត រិន ជាលេខា នីម បានស្គាល់ និងធ្វើការជាមួយសមមិត្ត រិន តាំងពីសម័យសង្គ្រាមវាយជាមួយ លន់ នល់ មកម្ល៉េះ ដោយពេលនោះ នីម នៅផ្នែកនីរសារ ចំណែក សមមិត្ត រិន នៅអគ្គសេនាធិការ (ផ្នែកជញ្ជូនគ្រាប់) ។ ប៉ុន្តែ នីម ត្រូវត្រឡប់មកជួប សោ ភឹម នៅមន្ទីរទួលព្រាបវិញ នៅរៀងរាល់ពេលល្ងាច ។

បន្ទាប់ពីផ្ញើសំបុត្រទៅកងពលរួច នីម ក៏មកជួប សោ ភឹម ពេលនោះ សោ ភឹម បានផ្ដាំ នីម ឲ្យនៅប្រចាំការនៅមន្ទីរ ព្រោះគាត់ត្រូវចាកចេញទៅក្រៅ ដោយឲ្យឈ្មោះ ម៉េង ជាអ្នកបើកឡានជូនគាត់ផ្ទាល់ និងឈ្មោះ គីម បើកឡានដឹកកងការពារ ។ សោ ភឹម បានប្រាប់ នីម ថា គាត់ទៅ ចាំនៅស្នាក់ការរបស់ កែវ សំណាង នៅខេត្តព្រៃវែង ។

នៅវេលាម៉ោង៧ព្រឹកថ្ងៃបន្ទាប់ នីម បានជិះម៉ូតូមួយគ្រឿងទៅតាម សោ ភឹម ។ ពេល នីម ទៅដល់ស្នាក់ការនៅទីរួមខេត្តព្រៃវែង វេលាម៉ោង១០ ព្រឹក កងការពាររបស់ កែវ សំណាង បានប្រាប់គាត់ថា សោ ភឹម ចេញទៅស្រុកស្រីសន្ធរហើយ ។ នីម ក៏វិលត្រឡប់មកមន្ទីរទួលព្រាប តែដោយឮដំណឹងថា មានការតាមចាប់ខ្លួនកម្មាភិបាលនៅខាងបូព៌ា ទើប នីម និង ចេង ប្រធានកងការពារ របស់ សោ ភឹម បានជិះម៉ូតូចេញទៅតាមរក សោ ភឹម នៅស្រីសន្ធរ ។ ពេលទៅដល់ខាងលិចស្វាយអន្ទរ ស្រាប់តែ នីម ឃើញកងទ័ពមជ្ឈិមដាក់បារ៉ាស់ស្កាត់ផ្លូវ ឃើញដូច្នេះ នីម ក៏ជិះម៉ូតូបកមកក្រោយវិញ ។ កងទ័ពមជ្ឈិមទាំងនោះបានជិះម៉ូតូដេញតាម នីម និង ចេង តែដេញមិនទាន់ ។

នីម និង ចេង បានត្រឡប់មកនៅមន្ទីរទួលព្រាបបានមួយរយៈ កងទ័ពមជ្ឈិមក៏មកឡោមព័ទ្ធបាញ់ ដូច្នេះគាត់ទាំងពីរនាក់ក៏ជិះម៉ូតូគេចទៅទីរួមខេត្តព្រៃវែង ។ ស្រាប់តែមកដល់ដើមពោធិ៍ធំ ក្នុងស្រុកកញ្ជៀច នីម បានជួប សមមិត្តរិនរួមជាមួយកងការពារ និងអ្នកបើកឡានរបស់គាត់ពីរនាក់ទៀត ។ ពេលនោះ នីម បានឃាត់ សមមិត្ត រិន ដោយប្រាប់ថា «បងកុំទៅមុខទៀត តែទៅគេ (កងទ័ពមជ្ឈិម) ចាប់ខ្លួនហើយ» ។ ឮដូច្នេះ រិន ក៏បកទៅឈប់នៅឃុំអំពិល មុំឡាតដ្ឋ) ក្នុងស្រុកអូររាំង ដើម្បីសម្រាកហូបបាយ នៅរោងសហករណ៍អំពិល ដែលពេលនោះ នីម ក៏ជិះម៉ូតូទៅហូបបាយជាមួយដែរ ។ ស្រាប់តែហូបបាយមិនទាន់រួចរាល់ផង នីម ឃើញរថក្រោះរបស់កងទ័ពមជ្ឈិមចេញមកពីទីរួមស្រុកអូររាំង បាញ់សំដៅមក ។ កម្មករនៅក្នុងសហករណ៍ បានរត់ប្រសេចប្រសាចពេញវាលស្រែ ចំណែក រិន ក៏រត់ចោលឡានហ្ស៊ីបរបស់គាត់ ឃើញដូច្នេះ នីម និង ចេង ក៏រត់ចោលម៉ូតូដែរ ។

វេលាម៉ោង១២យប់ នីម និង ចេង បានទៅដល់ស្ពានថ្មទឹកដាច់ នៅក្នុងស្រុកកញ្ជៀច ។ ព្រឹកឡើង ទើបគាត់ទាំងពីរនាក់បន្តដំណើរទៅមុខទៀត ។ នៅតាមផ្លូវ នីម បានឃើញកងទ័ពមជ្ឈិម ចុះមកចាប់កម្មាភិបាលនៅតាមភូមិឃុំ និងសហករណ៍ជាបន្តបន្ទាប់ទៀត ឃើញដូច្នេះគាត់ក៏ដើរចេញពីផ្លូវថ្នល់សំដៅទៅផ្លូវលំ ដើម្បីងាយស្រួលលាក់ខ្លួន ។ មកដល់វាលល្មា ក្នុងស្រុកកំចាយមា នីម ក៏បានបែកចេញពី ចេង ក្រោយមកឮដំណឹងថា ចេង ត្រូវកងទ័ពមជ្ឈិម (ចាប់ខ្លួនបាននៅភូមិអង្គរ) ។ ចំណែក នីម បានមកលាក់ខ្លួននៅផ្ទះខាងប្រពន្ធ (ធ្វើការនៅក្នុងកងចល័តជាមួយយាយការ៉ូ) ស្ថិតនៅឃុំដូនតី ស្រុកពញាក្រែក ។ ប៉ុន្តែមកស្នាក់នៅផ្ទះបានរយៈពេល៥ថ្ងៃ នីម បានឮដំណឹងថា អង្គការរកចាប់ខ្លួនគាត់ទៀត ទើបគាត់រត់គេចខ្លួនចូលក្នុងព្រៃ ដោយទុកប្រពន្ធឲ្យចាំនៅផ្ទះ ។

ក្រោយមក ដោយសារគ្មានអាហារបរិភោគ នីម ក៏រត់គេចខ្លួនទៅស្រុកកំណើត នៅឃុំគគីរសោម ស្រុករំដួល ខេត្តស្វាយរៀងវិញ ។ តែគាត់ត្រូវកងទ័ពមជ្ឈិមចាប់ខ្លួនបាន និងយកទៅដាក់គុកស្ថិតនៅខាងជើងក្រុងស្វាយរៀង ។ នីម ជាប់ឃុំរយៈពេលពីរខែ រហូតដល់កងទ័ពវាយបុកចូលមកខ្លាំង ទើបអង្គការជម្លៀសគាត់ទៅនៅស្រុកស្អាង ខេត្តកណ្ដាល ។ ចាប់តាំងពីពេលនោះមក ទើបអង្គការលែងកត់ចំណាំប្រវត្តិរូបរបស់គាត់បាន ហើយគាត់ក៏មិនដែលនិយាយពីប្រវត្តិរបស់គាត់ប្រាប់អ្នកផ្សេងដែររហូតមកដល់សព្វថ្ងៃនេះ ។ **សោម ប៊ុនថន**

# រត់ចេញពីគុកដើម្បីរស់

*អ៊ឹ យិក អាយុ៦៦ឆ្នាំ គឺជាកសិករមួយរូបក្នុងភូមិចម្ការបី នៃឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប ។ គាត់មានស្រុកកំណើតក្នុងភូមិដំណាក់ត្រយឹង ។ ចាប់តាំងពីកុមារភាព គាត់អាចអាន និងសសេរបាន ។ នាឆ្នាំ១៩៧០ គាត់បានរៀបការ និងមានកូនចំនួន ៤នាក់ ។ ក្រៅពីមុខរបរជាកសិករ គាត់ប្រកបរបរជីកថ្មសលក់នៅឯផ្សារទូកមាសផងដែរ ។ គាត់រស់នៅក្នុងជីវិតយ៉ាងសាមញ្ញមួយ ។ រហូតដល់ថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ប្រជាជន ១៧មេសាចំនួន៨នាក់ ត្រូវបានជម្លៀសឲ្យមកនៅជាមួយគាត់ ។ ដោយសារគាត់ត្រូវបានអង្គការចាត់តាំងជាកម្មាភិបាលខ្មែរក្រហម គាត់ត្រូវបានអង្គការបញ្ជាឲ្យយកប្រជាជន១៧មេសា ពីរនាក់ ទៅក្រោលគោមួយនៅឯភ្នំក្បាលទិញ ។ បើទោះជាយ៉ាងនេះក្ដី គាត់ពុំបានធ្វើតាមទេ ដោយគាត់ដឹងថាប្រសិនបើគាត់យកគេទាំងពីរទៅ គេប្រាកដជាត្រូវយកទៅសម្លាប់មិនខាន ។ ការបដិសេធនេះធ្វើឲ្យគាត់ជាប់ឈ្មោះនៅក្នុងបញ្ជីសង្ស័យរបស់ខ្មែរក្រហម ។*

*នៅពាក់កណ្ដាលឆ្នាំ១៩៧៧ គាត់ត្រូវបានចាត់តាំងឲ្យក្លាយជាប្រធានកងមើលគោក្របី ដែលមានប្រធានកងឈ្មោះ អន ។ ការងាររបស់គាត់គឺមើលថែគោក្របីពី ៥០ទៅ៦០ក្បាល ។ នៅក្នុងកងរបស់គាត់មានរួមបញ្ចូលនូវសមាជិកចំណាស់៣នាក់ និងក្មេង២នាក់ ។ ថ្ងៃមួយ មានកូនគោមួយពុំព្រមចូលក្រោលវិញទេ ។ វាមានភាពរឹងរូសជាពន់ពេក ។ ដោយអស់មធ្យោបាយ គាត់ក៏បណ្ដោយឲ្យកូនគោនោះនៅខាងក្រៅក្រោលនោះ ។ ជាអកុសល ប្រធានភូមិបានយកកូនគោនោះទៅបរិភោគ ។ ពីបីថ្ងៃកន្លង យិកបានត្រូវអង្គការដកចេញពីប្រធានកង ។ គាត់ត្រូវបានបញ្ជូនទៅបម្រើទ័ព និងប្រយុទ្ធនៅសមរភូមិមុខនៅឯព្រែកជីក ដែលស្ថិតនៅក្បែរព្រំប្រទល់ប្រទេសវៀតណាម ។ ថ្ងៃមួយ មានមនុស្សមករកគាត់ ហើយបានប្រាប់គាត់ថា កូនរបស់គាត់ឈឺ ហេតុនេះគាត់ត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ ចំនួន១ខែ ។ គាត់មានភាពរីករាយជាពន់ពេក ដោយបានជួបជុំជាមួយគ្រួសាររបស់ខ្លួនវិញ ។*

*ផ្ទុយទៅវិញ គាត់បែរជាត្រូវបានបញ្ជូនទៅកាន់គុកទូកមាសទៅវិញ ។ គាត់ត្រូវបានអង្គការចោទប្រកាន់ពីបទដោះលែងប្រជាជន ១៧ មេសា ពីរនាក់ និងសម្លាប់កូនគោ ។ អង្គការសម្រេចបញ្ជូនគាត់ទៅកាន់ខេត្តកំពត ។ គាត់ចំណាយពេលមួយយប់ដើម្បីទៅដល់ទីនោះ ។ ដើម្បីបញ្ជូនគាត់ទៅដល់ទីនោះ គាត់ត្រូវខ្មែរក្រហមចង និងដាក់ខ្នោះ រួចបោះបញ្ចូលទៅក្នុងឡាន ។*

*នៅពេលដែលទៅដល់កំពត គាត់នៅជាប់ចំណង និងខ្នោះនៅឡើយ ។ ក្នុងរយៈពេលបីថ្ងៃដំបូង គាត់ត្រូវបាននាំទៅសួរចម្លើយ ហើយគាត់ត្រូវបានសួរចម្លើយ និងវាយដំបីដងក្នុងមួយថ្ងៃ ។ អំឡុងពេល សួរចម្លើយឆ្មាំគុកសួរគាត់ថា គាត់ធ្វើខុសអ្វី ។ គាត់ឆ្លើយថា គាត់ពុំបានធ្វើអ្វីខុសទេ ។ គាត់នៅតែបន្តឆ្លើយដូច្នេះ ។ តែឆ្មាំគុកពុំស្ដាប់គាត់ទេ ។ ឆ្មាំគុកបានលើកឡើងថា “ប្រសិនបើមិត្តមិនធ្វើខុស អង្គការមិនឃាត់ខ្លួនមិត្តទេ ។ អង្គការមិនដែលឃាត់ខ្លួននរណាម្នាក់ដោយគ្មានហេតុផលទេ” ។ ឆ្មាំគុកក៏បានសួរគាត់ពីជីវប្រវត្តិរបស់គាត់ ហើយគាត់បានឆ្លើយប្រាប់ថា គាត់ជាកសិករ ។ លើសពីនេះ ឆ្មាំគុកនៅតែបន្តសួរគាត់ពីមូលហេតុដែលគាត់ត្រូវអង្គការបញ្ជូនមកកាន់ទីនោះ ។ ដោយពុំផ្ដល់ចម្លើយឲ្យឆ្មាំគុកពេញចិត្តគាត់ ត្រូវបានឆ្មាំគុកវាយនឹងដែកចម្រឹងបង្អួច ។ ដោយពុំអាចទ្រាំទ្រនឹងការឈឺចាប់ គាត់បានសន្លប់ ។ ចុងក្រោយគាត់ត្រូវបានឆ្មាំគុកដាក់ប្រវ៉ាក់ ។ គាត់ទទួលបានអាហារពីរពេល ដែលរួមមាន បាយ និងបបរ ។ នៅក្នុងបន្ទប់មួយ ឆ្មាំគុកដាក់អ្នកទោសចំនួន ១០នាក់ អ្នកទោសទាំងនោះត្រូវបានឆ្មាំគុកភ្ជាប់ដោយរបាដែកមួយរួមគ្នា ។ ឆ្មាំគុកបានដាក់កេសគ្រាប់សម្រាប់ឲ្យអ្នកទាំងនោះបន្ទោរបង់ផងដែរ ។ មានអ្នកទោសខ្លះបានស្លាប់ ។ បរិយាកាសទីនោះ ពោរពេញដោយក្លិនស្អុយឈ្លួល ដោយសារតែរហូតដល់រយៈពេលមួយយប់មួយថ្ងៃទើបឆ្មាំគុកយកសាកសព និងកេះលាមកនោះចេញ ។ គាត់ត្រូវដេកជាមួយសាកសពនៅជុំវិញ ។ គាត់ពុំមានឱកាសងូតទឹកទេ ។ គាត់នៅទីនោះ បានចំនួន ៣ខែ និង២០ថ្ងៃ ។ បន្ទាប់មក គាត់ត្រូវបាននាំទៅទីតាំងថ្មីគឺឃ្លាំង*

ជាមួយអ្នកទោស១០អ្នកដទៃទៀត តាមឡាន ។

នៅល្អាង គាត់បានចាត់តាំងឲ្យធ្វើស្រែ លើកដី និងរុករានព្រៃយកដីដាំដំណាំ ។ នៅទីនោះរួមមាន អ្នកទោសសរុបទាំងប្រុសទាំងស្រី ចំនួន៦០០នាក់ ។ អាហារដែលគាត់ទទួលបានគឺបាយលាយជាមួយដំឡូងមី ។ នៅទីនោះ មានអ្នកទោសស្រីមួយចំនួនបានរត់គេចហើយត្រូវឃាត់ខ្លួន ។ បន្ទាប់ពីឃាត់ខ្លួនអ្នកទាំងនោះ ត្រូវបានចងរយៈពេលពីរថ្ងៃពីរយប់ ។ ក្រោយមក ខ្មែរក្រហមបានឲ្យអ្នកទោសទាំងអស់ឈរជាជួរដើម្បីឲ្យអ្នកដែលរត់គេចខ្លួនទាំងនោះស្នើសុំអ្នកធានារបស់ខ្លួន ដោយធានាថាខ្លួននឹងពុំរត់ទៀតទេ ។ ប៉ុន្តែពុំមាននរណាម្នាក់ហ៊ានធ្វើជាអ្នកធានាទេ ។ ជាលទ្ធផលស្ត្រីទាំងនោះត្រូវបានឆ្កាំគុកសម្លាប់ ។ យិ មើលឃើញដោយផ្ទាល់នូវហេតុការណ៍សម្លាប់ចំនួនបីដង ។ ស្ត្រីពីរនាក់ត្រូវបានសម្លាប់ដោយត្បូងចប និងបុរសម្នាក់ត្រូវបានសម្លាប់ផ្ទាល់នៅនឹងមុខគាត់ និងអ្នកទោសដទៃ ។

នៅក្នុងឆ្នាំ ១៩៧៨ មានតែអ្នកទោស៣០០នាក់ប៉ុណ្ណោះដែលនៅសល់ ។ ចំនួនអ្នកទោសត្រូវបានកាត់បន្ថយអស់ពាក់កណ្តាល ។ ក្នុងឆ្នាំនេះ ខ្មែរក្រហមត្រូវទប់ទល់នឹងវៀតណាមនៅកោស្លា ហេតុនេះអ្នកទោសទាំងអស់ត្រូវបានបញ្ជូនឲ្យទៅជួយ ។ អ្នកទាំងនេះមានតួនាទីស្ពាយស្បៀងឲ្យទាហានខ្មែរក្រហម ។ មានពេលមួយ យិក បានឃើញអ្នកទោសត្រូវបានសម្លាប់ ។ គាត់គិតថា គាត់នឹងត្រូវគេសម្លាប់ដែរ ។ បន្ទាប់មក អង្គការបានមកត្រួតពិនិត្យអ្នកទោសហើយសម្លាប់ចោលម្តងម្នាក់ៗ ។ ដើម្បីរស់រាន គាត់សម្រេចចិត្តលួចរត់ ។ គាត់រត់ចេញបានសម្រេច ។ គាត់ត្រូវចំណាយពេល១២យប់ ១២ថ្ងៃ ធ្វើដំណើរទៅកាន់ក្បាលរមាស ដោយគាត់រត់នៅពេលយប់តែប៉ុណ្ណោះ ព្រោះខ្លាចខ្មែរក្រហមឃើញ ។ គាត់ត្រូវចំណាយពេល១៥ថ្ងៃទៀតដើម្បីសង់ខ្ទមដើម្បីស្នាក់នៅ ។ ក្រោយមក ឪពុករបស់គាត់បានបររទេះសេះទៅទទួលគាត់ត្រឡប់មកភូមិវិញ ។

**សុភក្រ្ត ភាណា**

# ដំណឹងស្វែងរកឪពុកមា

ខ្ញុំបាទឈ្មោះ ច័ន្ទ រិទ្ធី បច្ចុប្បន្នរស់នៅខណ្ឌសែនសុខ សង្កាត់ភ្នំពេញថ្មី ក្រុងភ្នំពេញ ។ ខ្ញុំបាទសូមប្រកាសរកឪពុកមា ឈ្មោះ សាប់ សំផន ដែលបានបាត់ខ្លួនក្នុងឆ្នាំ១៩៧៥ ក្រោយខ្មែរក្រហមរំដោះទីក្រុងភ្នំពេញ ។ លោកមា សាប់ សំផន មានស្រុកកំណើតនៅភូមិព្រៃលាភ ខេត្តកណ្តាល ។ គាត់មានឪពុកឈ្មោះ សាប់ ឈុន (ស្លាប់) និងម្តាយ ងួន វ៉ាន់ (រស់) និងមានបងប្អូនប្រុសស្រី៦នាក់ រួមមាន ៖ ១) សាប់ សេរីឃុំ ភេទស្រី (ស្លាប់ក្នុងរបបខ្មែរក្រហម), ២) សាប់ សំផន ភេទប្រុស (បាត់ខ្លួនក្នុងរបបខ្មែរក្រហម), ៣) សាប់ ធីតន្ធ ភេទស្រី (ស្លាប់ក្នុងរបបខ្មែរក្រហម), ៤) សាប់ សុខារី ភេទស្រី, ៥) សាប់ វ៉ាន់នីន ភេទប្រុស, ៦) សាប់ ភូមិរិន្ទ ភេទស្រី ។

សូមបញ្ជាក់ថា ក្នុងរបបសាធារណរដ្ឋខ្មែរ លោកមា សាប់ សំផន ជាទាហាននៅបន្ទាយស៊ឹងមានជ័យ និងក្រោយមក ផ្លាស់ទៅធ្វើជាទាហានជើងទឹកនៅកំពង់សោម ខេត្តព្រះសីហនុ ។ ក្រោយថ្ងៃរំដោះ១៧មេសា ឆ្នាំ១៩៧៥ កូនទាហានម្នាក់បានជូនគាត់ឡើងគោកក្នុងគោលបំណងជូនលោកមាមករកក្រុមគ្រួសារ ហើយក៏បាត់ដំណឹងតាំងពីពេលនោះមក ។

អាស្រ័យហេតុនេះ បើបងប្អូនណាបានឃើញ និងស្គាល់លោកមារបស់ខ្ញុំឈ្មោះ សាប់ សំផន ដូចដែលបានរៀបរាប់ខាងលើ សូមទាក់ទងមកខ្ញុំបាទតាមទូរស័ព្ទលេខៈ ០១៦ ៨៧៩ ៣៩៨ ឬ ទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬ តាមរយៈទូរស័ព្ទ ០២៣ ២១១ ៨៧៥ ។ ***សូមអរគុណ!***

# ការបាត់បង់ បន្សល់ទុកត្រឹមតែអនុស្សាវរីយ៍


សួន សុខ

ពេលវេលាមួយដែលមិនអាចបំភ្លេចបាន វាក៏ជាពេលវេលាមួយដែលតក់ស្លុតបំផុតនោះគឺពេលដែលឃើញមនុស្សដែលខ្លួនស្រលាញ់បានចាកចេញទៅ ដោយប្រាប់ថា «កុំបារម្ភពីខ្ញុំអី គ្មានបញ្ហាអីទេ» នេះជាពាក្យសម្តីចុងក្រោយ ដែល សួន សុខ មិនអាចបំភ្លេចបានក្នុងមួយជីវិតរបស់គាត់ ។

សួន សុខ ជាអ្នកភូមិរស់នៅក្នុងភូមិសង្គម ឃុំនាងទើត ស្រុកតំបែរ ខេត្តត្បូងឃ្មុំ (ខេត្តត្បូងឃ្មុំទើបតែត្រូវបានបំបែកចេញពីខេត្តកំពង់ចាម) ហើយគាត់ គឺជាកូនទីពក្នុងចំណោមបងប្អូន៦នាក់ ដែលម្នាក់បានបាត់ខ្លួន ដោយមិនដឹងថា មានរឿងអ្វីកើតឡើងចំពោះរូបគាត់នៅក្នុងរបបខ្មែរក្រហម ។ សុខ ក៏បានបន្ថែមទៀតថា បន្ទាប់ពីខ្មែរក្រហមឡើងគ្រប់គ្រងអំណាច នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសាររបស់គាត់ត្រូវបានជម្លៀសពីកន្លែងមួយទៅកន្លែងមួយ ទោះបីជាគ្រួសាររបស់គាត់ជាប្រជាជនចាស់ក៏ដោយ ដែលនៅពេលនោះទ្រព្យសម្បត្តិទាំងអស់ត្រូវបានរឹបអូសយក លើកលែងតែរបស់របរដែលប្រើប្រាស់ជាប្រចាំថ្ងៃ ។ បន្ទាប់ពីទៅដល់កន្លែងថ្មី សមាជិកគ្រួសារត្រូវបានចាត់តាំងទៅកងចល័តរៀងៗខ្លួន ។ នៅពេលនោះ សុខ មានអាយុប្រហែលជាជាង១០ឆ្នាំ ដូចច្នេះ ខ្មែរក្រហមបានឲ្យគាត់ទៅដើររើសលាមកសត្វ និងការងារផ្សេងទៀតដែលអាចធ្វើបាន ។ ទោះបីជាបងប្រុសរបស់គាត់ត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើការនៅកងចល័តដែលនៅឆ្ងាយពីក្រុមគ្រួសារក៏ដោយ ក៏ប៉ុន្តែ សុខ រួមទាំងប្អូនៗប្រុសស្រីរបស់គាត់អាចរស់នៅជាមួយឪពុកម្តាយ បន្ទាប់ពីធ្វើការងាររួច ដែលនៅពេលនោះឪពុកម្តាយរបស់សុខមិនអាចធ្វើអ្វីក្រៅពីធ្វើស្រែចម្ការឡើយ ។ ជារៀងរាល់ថ្ងៃ អង្គការឲ្យក្មេងៗទាំងអស់ឈរជាជួរសម្រាប់ពិនិត្យមើលថាតើមាននរណាម្នាក់អត់ធ្វើការ បើសិនជាដឹងថាមានអ្នកណាខ្ជិលធ្វើការអង្គការនឹងមិនឲ្យចូលរោងបាយដើម្បីទទួលរបបអាហារនោះទេ ។

នៅឆ្នាំ១៩៧៧ បងប្រុសរបស់សុខ ឈ្មោះ សួន អ៊ុន បានត្រលប់មកផ្ទះ ហើយបានប្រាប់ឪពុកម្តាយថា គាត់មិនចង់ទៅវិញទេ ពីព្រោះតែខ្មែរក្រហមបានឲ្យគាត់ធ្វើជាទាហាន ។ បន្ទាប់ពីនៅផ្ទះបានប្រហែលជា២សប្តាហ៍ ប្រធានសហករណ៍បានមកនាំ អ៊ុន ឲ្យទៅសាងសង់ទំនប់ទឹក ដែលវាហាក់ដូចជាការដាក់ទារុណកម្មផងដែរ ពីព្រោះនៅពេលនោះ មានមនុស្សតែ២នាក់តែប៉ុណ្ណោះ ដែលខ្មែរក្រហមបានចាត់តាំងឲ្យធ្វើទំនប់ទឹកនោះ ។ បន្ថែមពីលើនេះទៀត របបអាហារសម្រាប់ទទួលទានក៏មិនគ្រប់គ្រាន់ដែរ រហូតស្ទើរតែដួលម្តងៗនៅពេលកំពុងធ្វើការ ។ ដោយមិនអាចទ្រាំបានជាមួយនឹងការបង្ខំឲ្យធ្វើការហួសកម្លាំងបែបនេះ អ៊ុន ក៏បានសម្រេចចិត្តត្រលប់ទៅបន្ទាយទាហានគាត់វិញ ។

២-៣ខែក្រោយមក ហាក់ដូចជាមានរឿងចម្លែកកើតឡើង ពីព្រោះ អ៊ុន បានត្រលប់មកផ្ទះម្តងទៀត ដោយបង្ហាញទឹកមុខភ័យខ្លាច ។ គាត់បានប្រាប់ថា គាត់ស្ទើរត្រូវបានបញ្ជូនទៅសមរភូមិ ហើយនេះគឺជាអ្វីដែលគាត់ខ្លាចបំផុត ដូច្នេះបានជាគាត់សម្រេចចិត្តត្រលប់មកផ្ទះវិញ ។ នៅពេលនោះ សុខ មិនបានចាប់អារម្មណ៍នូវអ្វីដែលបងប្រុសនិយាយនោះទេ ពីព្រោះតែគាត់នៅក្មេងពេក ។ នៅព្រឹកបន្ទាប់ មានមនុស្ស៣-៤នាក់មកយកគាត់ទៅ ។ មុនពេលចាកចេញទៅ អ៊ុន បាននិយាយថា «ដល់ពេលខ្ញុំទៅហើយ ព្រោះមេខ្ញុំហៅខ្ញុំទៅវិញ ដូច្នេះកុំបារម្ភពីខ្ញុំអី វាគ្មានបញ្ហាអ្វីទេ» បន្ទាប់ពីនិយាយផ្តែផ្តាំជាលើកចុងក្រោយ គ្មាននរណាម្នាក់អាចធ្វើអ្វីកើតនោះទេ ក្រៅពីមើលគាត់ចាកចេញទៅជាលើកចុងក្រោយ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៧ដល់ឆ្នាំ១៩៧៨ គ្រួសារសុខមិនត្រឹមតែធ្វើការកាន់តែនឿយហត់នោះទេ ថែមទាំងបានបាត់បង់សមាជិកម្នាក់ ស្របពេលដែលរបបអាហារនៅពេលនោះកាន់តែតិចទៅៗ ។ ទោះយ៉ាងណាដោយ ក៏គ្មាននរណាម្នាក់នៅក្នុងគ្រួសារ

ហ៊ានបង្ហាញពីប្រតិកម្ម ឬក៏អារម្មណ៍ណាមួយឡើយ ដោយសម្តែងហាក់ដូចជាគ្មានរឿងអ្វីកើតឡើង ពីព្រោះតែខ្លាចគេហៅទៅអប់រំ ។ គួសបញ្ជាក់ថា មនុស្សដែលអង្គការបញ្ជូនទៅដើម្បីអប់រំ គឺមិនដែលត្រលប់មកវិញទេ ។ ជាក់ស្តែង សុខបានឃើញដោយផ្ទាល់ភ្នែក អ្នកភូមិរបស់គាត់ម្នាក់ឈ្មោះ លិញ ហ៊ានតវ៉ាជាសាធារណៈ នូវអ្វីដែលចាត់តាំងដោយអង្គការ ជាលទ្ធផល លិញ ត្រូវបានបញ្ជូនទៅអប់រំ ដោយមិនដែលបានឃើញគាត់ត្រលប់មកភូមិវិញឡើយ ។ បន្ទាប់ពីដឹងរឿងដែលមិនគួរឲ្យជឿនេះមក សុខ និងក្រុមគ្រួសារធ្វើហាក់ដូចជាមិនដឹងរឿងអ្វី ព្រោះតែខ្លាចស្លាប់ ។ សុខ បានបញ្ជាក់ថា “នៅជំនាន់ខ្មែរក្រហម យកល្អកុំនិយាយផ្តេសផ្តាសដើម្បីរក្សាជីវិតរបស់ខ្លួន”

បន្ទាប់ពីរំដោះឆ្នាំ១៩៧៩ សុខ អាចជួបជុំជាមួយគ្រួសារវិញ ហើយត្រលប់មករស់នៅភូមិកំណើតវិញ ដោយបាត់ដំណឹងបងប្រុសម្នាក់ឈ្មោះ សួន អ៊ុន ។ គាត់ពិតជាមិនយល់ថាហេតុអ្វីបានបងប្រុសរបស់គាត់បាន បាត់ខ្លួនយ៉ាងនេះទេ ដោយមិនដឹងថាមានរឿងអ្វីបានកើតឡើងនៅពេលនោះឡើយ ។ សុខ គ្មានសង្ឃឹមថានឹងជួបបងប្រុសរបស់គាត់ម្តងទៀតទេ ដោយសារតែគាត់សន្និដ្ឋានថា បងប្រុសរបស់គាត់ប្រាកដជាត្រូវខ្មែរក្រហមសម្លាប់បាត់ទៅហើយ ។ អ្វីដែលសុខ សោកស្តាយបំផុតក្នុងជីវិតរបស់គាត់នោះគឺគាត់មិនមានរូបថតបងប្រុសរបស់គាត់សូម្បីតែមួយសន្លឹក អ្វីៗទាំងអស់បានត្រឹមតែជាអនុស្សាវរីយ៍ និងការចងចាំប៉ុណ្ណោះ ។ **ស៊ាង ចិន្តា**

# ខ្សែភាពយន្តឯកសាររឿង «ក្បង់ទឹកទន្លេ»

“ក្បង់ទឹកទន្លេ” គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត “ក្បង់ទឹកទន្លេ” ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១៦ហើយ ។ “ក្បង់ទឹកទន្លេ” បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញកព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើប សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ និងប្រទេសអូទ្រីស ប៊ែលហ្ស៊ិក អាល្លឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី អង់គ្លេស និងប្រទេសសិង្ហបុរី ។ ខ្សែភាពយន្តឯកសារនេះ ក៏គ្រោងនឹងដាក់បញ្ចាំងតាមសាកលវិទ្យាល័យ និងភូមិចំនួន៦០ ទូទាំងប្រទេសកម្ពុជា ដើម្បីបើកឲ្យមានការពិភាក្សាស្តីពីការផ្លាស់ប្តូរបរិស្ថាន ដើម្បីស្វែងរកដំណោះស្រាយ ។ ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ព័ត៌មានបន្ថែមសូមទាក់ទង កញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខ ៖ ០១២ ៥១១ ៩១៤ ។ អ៊ីម៉ែល ៖ truthfatily.s@dccam.org គេហទំព័រ ៖ www.ariverchangescourse.com





# ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហាំបាលី៖ អត្តសញ្ញាណជនជាតិចាម នៅក្នុងយុគសម័យសកលភាវូបនីយកម្ម

## ការប្រឆាំងតវ៉ានៅភូមិទ្រា

ការតវ៉ាប្រឆាំងកើតឡើងនៅភូមិទ្រា នៅចុងឆ្នាំ១៩៧៣ ។ ភូមិនេះលាតសន្ធឹងក្នុងស្រុកក្រូចឆ្មារ ដែលត្រូវឆ្លងកាត់តាមសាឡាង ស្ថិតនៅចន្លោះស្រុកក្រូចឆ្មារ និងស្រុកស្ទឹងត្រង់ ។ សម្រាប់ជនជាតិចាម ភូមិទ្រា គឺនៅបណ្តុំនៃអ្នកបេះដឹងចាម ដែលនៅបន្តរហូតដល់សព្វថ្ងៃ ។ ចាប់ពីភូមិទ្រារហូតដល់ភូមិស្វាយឃ្លាំង ភូមិនីមួយៗ ដែលស្ថិតនៅខាងជើង គឺស្ថិតនៅជិតៗគ្នា ។ របាយប្រជាជនចាមមានភាពចង្អៀត ដូចដែលយើងឃើញសព្វថ្ងៃ ។ ដូចនេះ ទោះបីជាព័ត៌មាន និងពាក្យចចាមអារ៉ាមផ្សេងៗត្រូវបានទប់ស្កាត់ដោយខ្មែរក្រហម ក៏នៅតែត្រូវបែកចាយដឹងឮយ៉ាងលឿន ។

ការប្រឆាំងតវ៉ាដោយប្រជាជននៅភូមិទ្រាប្រឆាំងនឹងខ្មែរក្រហមបានកើតឡើងបន្ទាប់ពីមន្ត្រីសន្តិសុខស្រុកម្នាក់បានមកដល់ភូមិ ដើម្បីចាប់ជនជាតិចាមដែលមានចំណេះដឹង និងជាបុគ្គលសំខាន់ម្នាក់ ។ អ្នករស់រាន មានជីវិតចាំបានថា មន្ត្រីរូបនោះ ឈ្មោះមិត្ត អន (សមមិត្តអន) ។ មិត្តអន បានមកដល់ភូមិទ្រា ម្នាក់ឯង ដើម្បីចាប់ចាមម្នាក់ឈ្មោះ អាប្រាហ៊ីម (Abrahim) ដែលជាអ្នកមានទ្រព្យធន និងមានឥទ្ធិពលនៅក្នុងភូមិ ។ ពេលមិត្តអន មកដល់ អាប្រាហ៊ីម បានរត់គេចខ្លួនចេញតាមខាងក្រោយផ្ទះរបស់គាត់ ។ មិត្តអន បានដេញចាប់គាត់ និងបានបាញ់ អាប្រាហ៊ីម ប៉ុន្តែបាញ់មិនត្រូវ ។

ការប៉ុនប៉ងចាប់ខ្លួន អាប្រាហ៊ីម បានបង្កឲ្យអ្នកភូមិផ្ទុះកំហឹង



ជនជាតិចាម នៅភូមិទ្រា ឃុំទ្រា ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ធ្វើសំយ៉ាំងនៅវិហារមួយនៅក្នុងភូមិ

និងទាមទារឲ្យមានការពន្យល់ពីការហេតុការណ៍ទាំងនោះ និងហេតុផលនៃការចាប់ខ្លួនរបស់ អាប្រាហ៊ីម ដែលកើតឡើងនៅប៉ុន្មានខែថ្មីៗនេះ ។ ក្រោយមកនៅថ្ងៃជាមួយគ្នានោះដែរ អ្នកភូមិបានប្រមូលផ្តុំគ្នានៅកន្លែងជួបជុំសាសនា ដើម្បីពិភាក្សាអំពីសកម្មភាពប្រឆាំងនឹងខ្មែរក្រហម និងស្ថានភាពជុំវិញការចាប់ខ្លួន អាប្រាហ៊ីម ។ ជនជាតិចាមបានសម្រេចចិត្តដើរជាក្រុមទៅកាន់ទីស្នាក់ការជិតជាងគេរបស់ខ្មែរក្រហម គឺទីស្នាក់ការឃុំ ។ ជនជាតិចាមបានទាមទារជួបជាមួយមេឃុំ ដើម្បីនិយាយអំពីករណីនោះ ប៉ុន្តែមិនមានខ្មែរក្រហមណាម្នាក់ចេញមកជួបនោះទេ ។ បន្ទាប់មក អ្នកភូមិបានដុតទីស្នាក់ការសេដ្ឋកិច្ចរបស់ខ្មែរក្រហម រួចក៏ត្រឡប់ទៅភូមិវិញ ។ ប៉ុន្មានម៉ោងក្រោយមក មិត្តអន បានត្រឡប់មកវិញ រួមជាមួយទាហានរបស់គាត់ជាច្រើននាក់មកចាប់អ្នកដែលមកតវ៉ា ។ អ្នករស់រានមានជីវិតបាននិយាយថា ចាប់ពីពេលនោះមក អ្នកតវ៉ាដែលខ្លាចការចាប់ខ្លួន និងការធ្វើបាបពីសំណាក់ខ្មែរក្រហមបានរត់គេចខ្លួន ។ ខ្មែរក្រហមថែមទាំងបានចោទអ្នកដែលរត់គេចបាត់នោះថា ជាខ្មែរស ជាក្រុមដែលមានភាពស្មោះត្រង់នឹងសម្តេចសីហនុ ។ ខ្មែរក្រហមបានចាប់ខ្លួនជនទាំងឡាយណាដែលនៅសេសសល់នៅក្នុងភូមិ និងបន្តចាប់ខ្លួនរហូតអស់រយៈពេលជាច្រើនខែ ។ ការប្រឆាំងតវ៉ានេះបានធ្វើឲ្យខ្មែរក្រហមកាន់តែមានគំនិតស្អប់នឹងសត្រូវផ្ទៃក្នុងនៅស្ថិតនៅក្នុងភូមិ ។ ក្នុងករណីនេះគឺចាម ។ ការដាក់ទោស និងចាប់ខ្លួនត្រូវបានអនុវត្តជាបន្តបន្ទាប់ ។

## ការតវ៉ាប្រឆាំងនៅកោះផល

ការប្រឆាំងតវ៉ានៅកោះផលបានកើតឡើងនៅខែមិថុនា ឬកក្កដា ឆ្នាំ១៩៧៥ យោងទៅតាម ឃៀណាន់ (Kiernan) ។ ប៉ុន្តែយោងទៅតាមបទសម្ភាសន៍របស់អ្នកនិពន្ធជាមួយអ្នករស់រានមានជីវិត នៅស្វាយឃ្លាំងបានបង្ហាញថា ការប្រឆាំងតបតបានកើតឡើងនៅខែកញ្ញា ឆ្នាំ១៩៧៥ ក្នុងពេលបុណ្យ រ៉ាម៉ាដាន (Ramadan) ។ ចំណែកឯការប្រឆាំងតវ៉ានៅស្វាយឃ្លាំងបានកើតឡើងនៅប្រមាណពីរសប្តាហ៍ក្រោយ គឺនៅចុងខែកញ្ញា ឆ្នាំ១៩៧៥ ។

ហេតុការណ៍នៅកោះផល បានបណ្តាលឲ្យកើតមានរឿងហេតុនៅស្វាយឃ្លាំង ។ ភូមិនេះស្ថិតនៅចំកណ្តាលនៃទន្លេមេគង្គ ដែលប្រហែលជាពីរបីគីឡូម៉ែតនៃភាគខាងជើងស្វាយឃ្លាំង ។ បើយោងទៅតាមអ្នករស់រានមានជីវិតបានឲ្យដឹងថា ការបះបោរនៅកោះផលបានចាប់ផ្តើមពីការដែលខ្មែរក្រហមបានដាក់ការគាបសង្កត់ហួសហេតុ ដែលទាក់ទងនឹងការប្រតិបត្តិសាសនាអ៊ីស្លាម ។ ជាដំបូង ខ្មែរក្រហមបានដើរប្រមូលគម្ពីរគួរអានទាំងអស់ ហាមឃាត់អ្នកភូមិមិនឲ្យទៅសំយ៉ាំងនៅព្រះវិហារ និងហាមឃាត់មិនឲ្យប្រារព្ធពិធីបុណ្យជំនឿសាសនាផ្សេងៗ ។ អ្នករស់រានមានជីវិតបានឲ្យដឹងថា ខ្មែរក្រហមចង់ឲ្យព្រះវិហារ នៅតាមភូមិ និងសាលារៀនអ៊ីស្លាមបិទទ្វារនៅក្នុងរយៈពេលមួយសប្តាហ៍ ។ ក្នុងនាមជាសហគមន៍កោះមួយ អ្នកភូមិកោះផលមានស្មារតីរួបរួមសាមគ្គីយ៉ាងរឹងមាំ និងមានជំនឿសាសនាអ៊ីស្លាមយ៉ាងមុតមាំ ។ អ្នកភូមិមិនបានបិទវិហារ និងសាលារៀននោះទេ ។

ខ្មែរក្រហមក៏បានហាមប្រាមចាមមិនឲ្យនិយាយភាសាចាម ពោលគឺចង់ឲ្យជនជាតិចាមនិយាយភាសាខ្មែរជំនួសវិញ ។ ជនជាតិចាមត្រូវបានខ្មែរក្រហមដាក់ឈ្មោះជាភាសាខ្មែរជំនួសវិញ ។ នូ ហាលីម៉ាស់ បាននឹកឃើញឡើងវិញថាៈ

ថ្ងៃមួយ ខ្ញុំបាននិយាយទៅកាន់ប្អូនថ្លៃរបស់ខ្ញុំ ដែលកំពុងដេកឈឺនៅលើផ្ទះតូចមួយ ប៉ុន្តែយើងបានប្រើភាសាចាម ។ ខ្ញុំបានិយាយជាភាសាចាមថា "ផ្ទះរបស់យើងមានប្រហោង និងទឹកភ្លៀងស្រក់ចូលមក ។ អ្នកជួសជុលផ្ទះកំពុងតែជាប់រវល់ទៅសង់ខ្ទមថ្មីៗ ទៀតនៅកន្លែងផ្សេង ។ ខ្ញុំគិតថា ខ្មែរក្រហមប្រាកដជាយកយើងទៅនៅកន្លែងណាផ្សេងក្នុងពេលឆាប់ៗនេះ" ។ បន្ទាប់មក ឈ្លបរបស់ខ្មែរក្រហមម្នាក់ចេញមកពីក្រៀនផ្ទះដោយមានកាន់ច្រវ៉ាក់ដែកក្នុងដៃ ។ គាត់បាននិយាយថា តើអ្នកកំពុងតែនិយាយអំពីអ្វី? កុំប្រើភាសាបរទេស ។ ប្រសិនបើខ្ញុំឮអ្នកប្រើវាថ្ងៃក្រោយ ខ្ញុំនឹងចងអ្នកជាមួយនឹងច្រវ៉ាក់នេះ ។ ខ្ញុំញ័រខ្លួនអស់ហើយ និងឈប់និយាយចាម ចាប់ពីពេលនោះមក ។ ខ្ញុំហួសចិត្ត នៅពេលដែលគាត់គិតថា ភាសាចាមជាភាសាបរទេស ។ ខ្មែរក្រហមម្នាក់ទៀតឈ្មោះ ប្រុន ក៏បានចាត់ទុកភាសាចាម ជាភាសាបរទេសដែរ ។ ខ្ញុំមិនចង់ជឿសោះ ។ នៅមុនសម័យខ្មែរក្រហម ម្តាយរបស់គាត់ជារឿយៗមកលក់ពោតស្ងោរនៅមុខផ្ទះខ្ញុំ យើងស្គាល់គ្នា ហើយយើងរាក់ទាក់សួរសុខទុក្ខគ្នាទៅវិញទៅមក ។

កូង លីម បាននិយាយថា "នៅពេលខ្ញុំនិយាយចាម ប្រធានក្រុមរបស់ខ្ញុំស្រែកំហកឲ្យខ្ញុំ ។ ខ្ញុំមិនហ៊ាននិយាយម្តងទៀតទេ ។ ទោះជាយ៉ាងនេះក្តី ខ្ញុំជៀសមិនរួចពីនិយាយខ្មែរ ដោយមានលាយ

ពាក្យចាមខ្លះៗ ទៅកាន់សាច់ញាតិរបស់ខ្ញុំ ដោយសារតែការបញ្ចេញសំឡេងរបស់ខ្ញុំដូចភាសាចាម ហើយមិនតែប៉ុណ្ណោះ ខ្ញុំមិនអាចនឹកឃើញពាក្យខ្លះជាភាសាខ្មែរបាននោះទេ ។ ខ្ញុំប្រើភាសាខ្មែរទាំងខ្លាច ។» សុះ មេត បានបន្ថែមថា «យប់មួយខ្ញុំទៅលេងប្អូនប្រុសខ្ញុំដែលកំពុងយំ ។ នៅសម័យខ្មែរក្រហម ខ្មែរក្រហមអនុញ្ញាតឲ្យយើងច្រៀងតែបទចម្រៀងបដិវត្តន៍ដែលរៀបរាប់ពីអង្គការ ដូចជាការបែងចែកក្រុមការងារជាដើម ។ ប្អូនប្រុសខ្ញុំបានច្រៀងចម្រៀងទាំងនោះ ។ ខ្ញុំប្រាប់ប្អូនខ្ញុំឲ្យឈប់ច្រៀងជាភាសាចាម ។ បន្ទាប់មក ឈ្លបខ្មែរក្រហមបានមកដល់ផ្ទះយើងមួយរំពេច» ។

វាជាការងាយស្រួលដើម្បីយល់ថាហេតុអ្វីបានជាខ្មែរក្រហមចាត់ទុកចាមនិយាយភាសាចាមជាសមាសភាពគ្រោះថ្នាក់ ប៉ុន្តែយើងក៏អាចនិយាយបានដែរថា ការហាមប្រាមចំពោះចាមគឺជាឧទាហរណ៍មួយទៀតនៃការប្រកាន់ពូជសាសន៍របស់ខ្មែរក្រហម ។ នៅក្នុងរបបដែលប្រកបដោយភាពសង្ស័យ និងភាពភ័យខ្លាចហួសប្រមាណរួមទាំងការចេតនាចង់គ្រប់គ្រងប្រជាជន និងរចនាសម្ព័ន្ធរដ្ឋាភិបាលទាំងស្រុងផងនោះ ការប្រើប្រាស់ភាសាដែលខ្មែរក្រហមមិនចេះត្រូវបានគិតថា អាចជាប់ទាក់ទងនឹងបណ្តាញភ្នាក់ងារស៊ើបការណ៍ និងជាបណ្តាញក្បត់ ។ ដូចនេះ វាមិនមានអ្វីប្លែកទេ ដែលខ្មែរក្រហមបានហាមឃាត់មិនឲ្យនិយាយភាសាចាម ហើយវាជាការសមហេតុសមផលដើម្បីរក្សាសន្តិសុខរបស់ខ្លួន ជាពិសេស នៅពេល ដែលខ្មែរក្រហមដាក់ការគាបសង្កត់លើសាសនា និងវប្បធម៌របស់ខ្លួនឯងផងដែរនោះ ។ ប៉ុន្តែភាសាចាម គឺជាសសរទ្រូងដ៏រឹងមាំមួយ សម្រាប់ទ្រទ្រង់អត្តសញ្ញាណរបស់ចាម ខណៈដែលភាសានេះជាកេរដំណែលពីប្រទេសចម្ប៉ា ។ បើយោងទៅតាមការសង្កេតមើលសព្វថ្ងៃនេះ នៅតាមសហគមន៍ ដែលមានចាមរស់នៅច្រើន ក្មេងតូចៗនៅថ្នាក់មតេយ្យមិននិយាយភាសាខ្មែរនោះទេ ។ ស្ត្រីចាមដែលមិនសូវចេញទៅធ្វើការនៅក្រៅផ្ទះ និយាយភាសាខ្មែរតិចតួចណាស់ប៉ុណ្ណោះ ។ ការហាមឃាត់ជនជាតិចាមមិនឲ្យនិយាយភាសាចាមមានន័យថា ខ្មែរក្រហមចង់ឲ្យជនជាតិចាមបោះបង់ចោលនូវរបៀបរបបរស់នៅចាស់ និងចាប់យករបៀបរស់នៅថ្មី ។ ភាសាចាមជាផ្នែកមួយនៃមរតកតែមួយគត់ ដែលជនជាតិចាម នៅសេសសល់ពីប្រទេសចម្ប៉ា ដែលមិនមែនជាសាសនាអ៊ីស្លាម និងស្ថាប័នអ៊ីស្លាមនោះទេ ។

ស្ត្រីចាម ក៏ត្រូវបានរឹតបន្តឹងផងដែរ ។ វាជាប្រពៃណីដែលក្មេងស្រីជនជាតិចាមត្រូវទុកសក់វែង និងហ៊ុមគ្របសក់នឹងហែចាប់ (Hijab) ឬក្រមា ។ សម្រាប់ស្ត្រីជនជាតិចាមវិញ ត្រូវទុកសក់វែងដោយ ហ៊ុមគ្របសក់នឹងហែលចាប់ ឬក្រណាត់ផ្សេងៗ ។ ទោះបីជាវាមានសារសំខាន់ក្នុងការកត់សម្គាល់យ៉ាងនេះក្តី ក៏មិនមានទស្សនៈសលលណាមួយស្តីអំពី តើហែចាប់គួរតែធ្វើពីអ្វីឲ្យប្រាកដនោះទេ នេះបើយោងតាមការសង្កេតរបស់អ្នកនិពន្ធទៅលើស្ត្រីចាមសព្វថ្ងៃ អាស្រ័យទៅតាមទីតាំង និងនិកាយសាសនា ។ ស្ត្រីចាមខ្លះរុំក្រមាខណៈពេលដែលអ្នកខ្លះទៀតប្រើហែចាប់ ដែលនាំចូលពីប្រទេសម៉ាឡេស៊ី ។ ដូចនេះ ខ្មែរក្រហមខំប្រឹងប្រែងកែប្រែប្រពៃណី និងវប្បធម៌របស់ជនជាតិចាម ដោយខ្មែរក្រហមបានបង្ខំឲ្យស្ត្រីជនជាតិចាមទាំងអស់កាត់សក់ខ្លី ។ ការទុកសក់ខ្លីគឺជានយោបាយដែលដាក់ចេញឲ្យអនុវត្ត សម្រាប់ស្ត្រីទូទាំងប្រទេស ។ សម្រាប់ស្ត្រីខ្មែរ និងស្ត្រីជនជាតិដទៃទៀត មិនមានទំនៀមទម្លាប់ប្រពៃណី និងសាសនាតម្រូវឲ្យទុកសក់វែងដូចស្ត្រីចាមនោះទេ ប៉ុន្តែ គោលនយោបាយនេះបានប៉ះពាល់ដល់ស្ត្រីចាមយ៉ាងខ្លាំង ។

មុនពេលដែលខ្មែរក្រហមកាន់កាប់អំណាច ខ្មែរក្រហមត្រូវការការគាំទ្រពីប្រជាជនក្នុងស្រុក ។ ដូចនេះ ខ្មែរក្រហមហាក់ដូចជាបើកទូលាយដល់ការប្រតិបត្តិសាសនាអ៊ីស្លាមដែលជាគោលនយោបាយមួយ ដែលធ្លាប់អនុវត្តចំពោះប្រជាជននៅកោះផល ។ ប៉ុន្តែក្រោយពេលដែលខ្មែរក្រហមទទួលបានជោគជ័យ ខ្មែរក្រហមបានហាមឃាត់ការប្រណិប័តន៍ជំនឿផ្សេងៗដែលធ្វើឲ្យប្រជាជនមានអារម្មណ៍ថា ខ្លួនត្រូវបានក្បត់ បោកប្រាស់ និងរឹតបន្តឹង ។ មុនពេលការតវ៉ាចាប់ផ្តើមមេដឹកនាំចាមនៅសហគមន៍បានដឹងថា ប្រជាជនជាច្រើនបានបាត់ខ្លួននៅពេលយប់ ។

នៅពេលដែលការតវ៉ានៅកោះផលចាប់ផ្តើម ខ្មែរក្រហមបានព្រមានប្រជាជនកុំឲ្យបន្តធ្វើទៀត ។ ប៉ុន្តែ ជនជាតិចាមទាំងនោះនៅតែបន្តធ្វើ ដែលជាហេតុបង្កឲ្យខ្មែរក្រហមបាញ់គំរាមឡើងលើ និងបាញ់សំដៅទៅកាន់ហ្វូងមនុស្ស ។ ចាមបានតបតវិញដោយអំពើហិង្សា ដោយបានកាប់ទាហានខ្មែរក្រហមដោយដាវ និងកាំបិត ។ ជនជាតិចាមបាន សម្លាប់ខ្មែរក្រហមចំនួនបីទៅបួននាក់ ។ ការសម្លាប់

សមាជិករបស់ខ្មែរក្រហមរឹតតែធ្វើឲ្យខ្មែរក្រហមជឿលើការគាបសង្កត់ និងអំពើហិង្សាកាន់ខ្លាំងឡើងៗ ។ ខ្មែរក្រហមបានសងសឹកវិញ ដោយបានសម្លាប់អ្នកភូមិកាន់តែច្រើន ចាប់ខ្លួនអ្នកផ្សេងទៀត និងជម្លៀសចេញពីភូមិ ។ បន្ទាប់មកខ្មែរក្រហមបានរុះរើផ្ទះ និងដុតបំផ្លាញផ្ទះទាំងនោះចោល ។ ប្រជាជននៅកោះផលមួយចំនួន ត្រូវបានបញ្ជូនទៅរស់ទៅកាន់ឃុំតំបែរ និងគោកស្រុក មានចម្ងាយប្រហែល១៥ គីឡូម៉ែត្រ ដែលមានប្រជាជនខ្មែរភាគច្រើនជាអ្នកកាន់ព្រះពុទ្ធសាសនា ។ នេះជាឧទាហរណ៍មួយនៃការបំផ្លាញអត្តសញ្ញាណតាមរយៈការបំបែក និងបញ្ចូលទៅក្នុងសហគមន៍ផ្សេងៗទៀត ។

អ្នករស់រានមានជីវិតបានបង្ហាញថា នៅពេលព្រឹកបន្ទាប់ពីការបះបោរបុរសជនជាតិចាមត្រូវ បានខ្មែរក្រហមចាប់ចង និងបោះចូលឲ្យលង់ទឹកស្លាប់នៅទន្លេមេគង្គ ។ បន្ទាប់ពីពេលនោះមក ខ្មែរក្រហមបានប្តូរឈ្មោះ កោះផល ទៅជាកោះផេះដោយចំអក ដែលមានន័យថាជា កោះផេះ ដើម្បីទុកជាគំរូដល់សហគមន៍ចាមដទៃទៀត ដែលអាចចង់បះបោរប្រឆាំងការគ្រប់គ្រងរបស់ខ្មែរក្រហម ។ ដោយគ្មាន មនុស្សរស់នៅកោះផលបានរេចរិលចូលទៅក្នុងទន្លេមេគង្គ ។ មុនពេលតវ៉ាប្រឆាំង មានប្រជាជនប្រហែល៣៥០គ្រួសាររស់នៅលើកោះផល ។ នៅឆ្នាំ២០១០ មានប្រជាជនតែបីគ្រួសារប៉ុណ្ណោះ ដែលរស់នៅទីនោះ ។ អ្នកដែលរស់រានមានជីវិតបានឲ្យដឹងថា មានទីតាំងរណ្តៅសាកសពនៅលើកោះផល ។ ប៉ុន្តែ ជាង១០ឆ្នាំកន្លងទៅនេះ ឆ្អឹងទាំងនោះត្រូវបានធ្លាក់ចូលទៅក្នុងទន្លេតាមជំនន់ទន្លេមេគង្គនៅរដូវភ្លៀង ។

## ការបះបោរនៅស្វាយឃ្លាំង

ភូមិស្វាយឃ្លាំង ដូចជាភូមិទ្រា និងកោះផលដែរ ស្ថិតនៅតំបន់២១ នៃភូមិភាគបូព៌ា និងដឹកនាំដោយ អ៊ួច ប៊ុនជឿន ចាប់តាំងពីឆ្នាំ១៩៧៥ ។ សេងហុង ហៅ ចាន់ គឺជាប្រធានតំបន់២១ រហូតដល់ចុងឆ្នាំ១៩៧៥ ពេលដែលគាត់ត្រូវបានដំឡើងតំណែងឲ្យទៅជាអនុប្រធានគ្រប់គ្រងភូមិភាគបូព៌ា ក្រោម សោ ភឹម ។ យោងទៅតាមយៀណាន់ កងកម្លាំងដែលយកមកបង្ក្រាបការបះបោរនៅស្វាយឃ្លាំង ប្រហែលជាកម្លាំងសន្តិសុខស្រុក ។ យើងមិនច្បាស់ថា តើមានកងកម្លាំងថ្នាក់តំបន់ និងថ្នាក់ភូមិភាគ បានចូលរួមដែរឬទេ ។ ទោះបីជាយ៉ាងនេះក្តី គោលនយោបាយប្រឆាំងនឹងចាមជាបន្តបន្ទាប់នៅក្នុងស្រុកស្វាយឃ្លាំង ជាពិសេសកន្លែងដទៃទៀតនៅក្នុងប្រទេសទាំងមូល ប្រាកដចេញមកពីបញ្ជារបស់ថ្នាក់ដឹកនាំកំពូល ។

ការបះបោរនៅស្វាយឃ្លាំងកើតឡើងនៅចុងនៃពិធី រ៉ាម៉ាដាន (Ramada) ពីរសប្តាហ៍បន្ទាប់ពីការបះបោរនៅកោះផល ។ ហេតុការណ៍នេះ នាំឲ្យការប្រឆាំងនឹងការគាបសង្កត់ខាងសាសនារបស់ខ្មែរក្រហមមកលើជនជាតិចាមកាន់តែមានភាពពុះកញ្ជ្រោលឡើង ។ ភូមិស្វាយឃ្លាំងបានធ្លាក់ក្នុងការកាន់កាប់របស់ខ្មែរក្រហម នៅឆ្នាំ១៩៧០ នៅពេលដែលឥទ្ធិពលរណសិរ្សបង្រួបបង្រួមជាតិត្រូវបានផ្សព្វផ្សាយទូទាំងតំបន់២១ ។ ដំបូងឡើយ ឥរិយាបថរបស់ខ្មែរក្រហមចំពោះអ្នកភូមិស្វាយឃ្លាំង ក៏ដូចជាអ្នកភូមិទ្រាដែរ គឺការស្វាគមន៍យ៉ាងរាក់ទាក់ ។ ប្រជាជនបានអបអរចំពោះការគ្រប់គ្រងរបស់ខ្មែរក្រហមក្នុងការសម្របទៅតាមរចនាសម្ព័ន្ធសង្គម និងសេដ្ឋកិច្ចបដិវត្តន៍ថ្មីដរាបណាខ្មែរក្រហមមិនបានប៉ុនប៉ងហាមឃាត់ប្រជាជនចាមមិនឲ្យគោរពសាសនាអ៊ីស្លាម ។ ដូចជានៅភូមិទ្រាដែរ ទាហានខ្មែរក្រហមបានជួយដាំដុះ និងកសាងប្រព័ន្ធធារាសាស្ត្រផ្តល់អាហារ និងសម្លៀកបំពាក់ ។

នៅឆ្នាំ១៩៧៣ អ្វីៗទាំងអស់ត្រូវបានផ្លាស់ប្តូរ ហើយបុគ្គលសំខាន់ៗចំនួនប្រាំមួយនាក់នៅភូមិស្វាយឃ្លាំង ត្រូវបានហៅទៅប្រជុំ និងចាប់ខ្លួន ។ ការចាប់ខ្លួនប្រជាជនបានកើនឡើងនៅឆ្នាំ១៩៧៤ ជាពិសេស អ្នកដែលមានចំណេះដឹងខ្ពង់ខ្ពស់ រួមទាំង ហាកឹម ទូន និងមេជុំអាស ។ នៅដើមឆ្នាំ១៩៧៥ ការអនុវត្តការចាប់ខ្លួនរបស់ខ្មែរក្រហមកាន់តែសាយភាយទៅៗ ។ ក្នុងហេតុការណ៍មួយ ខ្មែរក្រហមបានស្នើឲ្យអ្នកភូមិស្វាយឃ្លាំងមួយក្រុមធ្វើដំណើរទៅកន្លែងមួយទៀត ហៅថា បឹងវែងដើម្បីរៀបចំដីធ្វើស្រែ ។ ប្រជាជនទាំងនោះត្រូវបានប្រាប់ឲ្យយកបាយថ្ងៃត្រង់ទៅជាមួយ ប៉ុន្តែនៅពេលដែលប្រជាជនទាំងនោះធ្វើដំណើរទៅដល់បឹងវែង ប្រជាជនទាំងនោះ ត្រូវបានខ្មែរក្រហម ហ៊ុមព័ទ្ធ និងចោទពីបទយកអាហារទៅឲ្យសត្រូវនៅក្នុងព្រៃ ។ មានតែប្រជាជនពីរបីនាក់ប៉ុណ្ណោះ ដែលត្រូវដោះលែងដើម្បីប្រាប់ពីការពិតទាំងនោះ ។ ការប្រណិប័តន៍សាសនា និងការបញ្ចេញមតិនៅក្នុងភូមិស្វាយឃ្លាំងក៏ត្រូវបានរឹតបន្តឹង ។

នៅពាក់កណ្តាលឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រមូលគម្ពីរគួរអាន នៅស្វាយឃ្លាំង ជាមួយដាវ កាំបិត និងអាវុធសំខាន់ៗផ្សេងទៀត ។ ខ្មែរក្រហមទទួលជោគជ័យក្នុងកិច្ចការនេះ ប៉ុន្តែអ្នកភូមិបាន

ដឹងថាសភាពការណ៍ហាក់ដូចជាប្រក្រតី ហើយក៏បានលាក់អ្វីដែលខ្មែរក្រហមចង់បាន ។ កោះផលស្ថិតនៅត្រឹមតែ១០គីឡូម៉ែត្រពីស្វាយឃ្លាំងប៉ុណ្ណោះ ប៉ុន្តែអ្នករស់រស់មានជីវិតនៅស្វាយឃ្លាំងបាននិយាយថា ខ្លួនមិនបានដឹងពីការតវ៉ាដោយហិង្សា និងការតបតវិញនៅកោះផលនោះទេ ។ ប្រសិនបើប្រជាជនចាម ដែលរស់នៅស្វាយឃ្លាំងបានដឹងពួកគេទាំងនោះនឹងចូលរួមគាំទ្រសកម្មភាពរបស់អ្នកភូមិកោះផល ។ យើងគួរកត់សម្គាល់ផងដែរថា ការទាក់ទងរវាងអ្នកភូមិនៅពេលនោះត្រូវបានខ្មែរក្រហមរឹតបន្តឹង ។ ទោះជាកោះផលនៅជិតស្វាយឃ្លាំង តែវាស្ថិតនៅចំកណ្តាលទន្លេមេគង្គឆ្ពោះទៅខាងជើង ។

ចុងខែកញ្ញា ឆ្នាំ១៩៧៥ ប្រហែលពីរសប្តាហ៍បន្ទាប់ពី ខ្មែរក្រហមបង្ក្រាបនៅកោះផល មួយថ្ងៃមុនបុណ្យ រ៉ាម៉ាដាន (Ramadan) បានបញ្ចប់ តំណាងអ្នកភូមិមួយក្រុមបានស្នើសុំខ្មែរក្រហមរៀបចំពិធីបុណ្យសក្ការៈរួមគ្នាមួយនៅព្រះវិហារនៅថ្ងៃបន្ទាប់ ។ នៅចុងថ្ងៃបុណ្យរ៉ាម៉ាដាន់ គឺជាថ្ងៃសំខាន់បំផុតមួយសម្រាប់ប្រជាជនមូស្លីម និងជាពេលវេលាដែលប្រារព្ធពិធីបុណ្យជាច្រើន ។ បុណ្យនេះហៅថា បុណ្យហារី រ៉ាយ៉ា អីឌុល ហ្វីទ្រី (Hari Raya Idul Fitri) ។ ដូចនេះ អ្នកភូមិស្វាយឃ្លាំងមានជំនឿថា ខ្មែរក្រហមមានចិត្តទូលាយដោយអនុញ្ញាតឲ្យពួកគេប្រារព្ធពិធីគោរពដូចដែលធ្លាប់ធ្វើមួយឆ្នាំមុន នៅពេលការគោរពរួមគ្នាត្រូវបានប្រារព្ធនៅក្នុងព្រះវិហារ ។ យើងគួរកត់សម្គាល់ថា ប្រជាជនមូស្លីមដែលមានជំនឿខ្ពស់បានបន្តបន់ស្រន់ដោយសម្ងាត់ជាប្រចាំថ្ងៃនៅឯផ្ទះរៀងៗខ្លួន ។ ការឆ្លើយតបរបស់ខ្មែរក្រហមនឹងការស្នើសុំនេះគឺមានភាពមិនច្បាស់ ។ ដូចនេះ អ្នកភូមិសន្មតថាអាចធ្វើទៅបាន ។

មុនពេលព្រលឹមស្រាងៗ ក្នុងពេលពិធីបុណ្យ ហារី រ៉ាយ៉ា អ្នកភូមិបានជួបជុំគ្នានៅព្រះវិហារ និងធ្វើពិធីសក្ការ ដើម្បីប្រណិប័តន៍តាមទំនៀមទម្លាប់ក្នុងពិធីបុណ្យ ហារី រ៉ាយ៉ា ។ ប៉ុន្តែ ខ្មែរក្រហមបានរៀបចំគម្រោងរួចជាស្រេច ។ ខ្មែរក្រហមមានបំណងព្រមានអ្នកភូមិយ៉ាងចាស់ដៃ ។ ខ្មែរក្រហមមិនបានធ្វើការឆ្លើយតប ដោយសារតែខ្មែរក្រហមសង្ឃឹមថា អ្នកភូមិទាំងឡាយនឹងមានការភ្ញាក់រឭកខាងសតិអារម្មណ៍ដែលទង្វើទាំងនេះគឺល្មើសនឹងបទបញ្ជារបស់អង្គការ ។ ខ្មែរក្រហមមិនបានផ្តល់នូវសញ្ញា ព្រមានអ្វីនោះទេប៉ុន្តែ ខ្មែរក្រហមបានកត់ឈ្មោះអ្នកដែលចូលរួមក្នុងពិធីសក្ការនៅព្រឹកព្រលឹមនោះ ។

ការបះបោរមួយត្រូវទទួលបានព័ត៌មានច្បាស់លាស់ពីអ្នកបង្ក្រាប និងគម្រោងរបស់ខ្មែរក្រហមក្នុងការបង្ក្រាប ។ នៅក្នុងករណីនេះ អ្នករស់រានមានជីវិតនៅស្វាយឃ្លាំងបានអះអាងថា ខ្លួនបានដឹងថា ខ្មែរក្រហមបានបញ្ជូនកម្មាភិបាលរបស់ខ្លួនមកស្រង់ឈ្មោះអ្នកភូមិណាដែលគិតថាមិនស្តាប់បង្គាប់ ។ អ្នកភូមិម្នាក់បានឃើញបញ្ជីឈ្មោះនោះ និងបានឃើញឈ្មោះសាច់ញាតិនៅលើបញ្ជីនោះ ។ គាត់ប្រាកដថា អ្នកដែលត្រូវបានរាយនាមនឹងត្រូវចាប់ខ្លួន ។ ព័ត៌មានពីការធ្វើបញ្ជីឈ្មោះនេះបានផ្សាយយ៉ាងលឿនមួយរំពេច ដូចភ្លើងឆាបឆេះពេញភូមិ ។ ដូចនេះ អ្នកភូមិបានប្តេជ្ញាយ៉ាងក្លាហានមួយដោយប៉ងចង់ប្រឆាំងតបនឹងការចាប់ខ្លួនរបស់ខ្មែរក្រហម ។ ប្រជាជនប្រមូលដាវ និង កាំបិត ដែលបានលាក់ទុកយកមកវិញ និងប្រមូលវត្ថុផ្សេងៗទៀត ដែលអាចប្រើជាអាវុធបានសម្រាប់ប្រឆាំងនឹងខ្មែរក្រហម និងសម្លាប់យោធាខ្មែរក្រហមម្នាក់ក្នុងចំណោមទាហានផ្សេងទៀត ដែលមកចាប់ខ្លួនអ្នកភូមិនៅយប់នោះ ។ ពេលនោះអ្នកភូមិដឹងថា ខ្មែរក្រហមនឹងត្រឡប់មកវិញ ជាមួយនឹងវិធានការខ្លាំងជាងនេះ ។ ឈ្មោះអ្នកភូមិប្រុសៗជាច្រើនដែលបានចូលរួមក្នុងការប្រារព្ធពិធីសក្ការនៅឯព្រះវិហារនៅពេលព្រឹកនោះត្រូវបានកត់ក្នុងបញ្ជីចាប់ខ្លួនរបស់ខ្មែរក្រហម ។ ការសម្លាប់យោធាខ្មែរក្រហមរឹតតែធ្វើឲ្យបទឧក្រិដ្ឋរបស់ប្រជាជនកាន់តែធ្ងន់ធ្ងរឡើង ។ អ្នកដែលមានឈ្មោះក្នុងបញ្ជីនោះមិនសង្ឃឹមថានឹងបានរស់នោះទេ ។ អ្វីដែលអាចធ្វើបាន មានតែវាយប្រឆាំងតបតវិញ ទោះបីជាឱកាសដែលនឹងទទួលបានជ័យជម្នះមានតិចតួចក៏ដោយ ។ ចាមចង់ស្លាប់ដោយកិត្តិយស និងមិនចង់បាត់បង់ជីវិតដោយអយុត្តិធម៌ដូចជនរងគ្រោះដទៃទៀតកាលពីពេលមុននោះទេ ។

អ្នកភូមិបានជ្រើសរើសកម្លាំងប្រុសៗដែលពេញកម្លាំងតាមតែអាចជ្រើសរើសបាន ។ ប្រជាជនខ្លះទៀតបានវាយស្គរឲ្យជាសញ្ញាអំពីការប្រឈមមុខដាក់គ្នា និងសញ្ញាគ្រោះថ្នាក់នានាដែលអាចកើតមាននៅក្នុងភូមិ ។ រណ្តៅជាច្រើនត្រូវបានជីកនៅតាមផ្លូវចូលសំខាន់ៗទៅក្នុងភូមិ ។ អ្នកភូមិខ្លះ បាននៅរុះរើផ្ទះមេភូមិ ដើម្បីយកគម្ពីរគួរអានដែលបានរឹបអូស និងវត្ថុផ្សេងៗទៀត ។ អ្នកភូមិចាស់ៗ បានជួបជុំគ្នា និងបន់ស្រន់ ។ អ្នកភូមិក្មេងៗបានបង្កប់ខ្លួននៅតាមទីតាំងរណ្តៅនានាប្រដាប់ដោយអាវុធក្នុងដៃ ដែលមានដូច ជាដាវ កាំបិត និង

ពូថៅ ។

ខ្មែរក្រហមបានមកដល់នៅពេលព្រឹកដោយមាននាវាដែលប្រដាប់ដោយកាំភ្លើងធុនធ្ងន់ចតនៅជ្រុងខាងជើងភូមិតាមបណ្ដោយទន្លេមេគង្គ ។ អ្នកដែលនៅរស់រានមានជីវិតបានឲ្យដឹងថា ក្នុងចំណោមអ្នកភូមិដែលចូលរួមប្រយុទ្ធទាំងនោះ មានតែកាំភ្លើងពីរដើមប៉ុណ្ណោះនៅក្នុងដៃ ។ ខ្មែរក្រហមមិនបានចំណាយពេលវេលាយូរទេ ដើម្បីបង្ក្រាបអ្នកភូមិ ផ្ទះសំបែងជាច្រើនក៏ត្រូវបានដុតឆេះជាបន្តបន្ទាប់ ។ នៅពេលរសៀល ការការពាររបស់អ្នកភូមិបានចុះចាញ់ ហើយខ្មែរក្រហមបានចូលទៅបោសសម្អាត ពីផ្ទះមួយទៅផ្ទះមួយទៀត ។ ខ្មែរក្រហមបានហៅ និងប្រមូលអ្នកភូមិជាច្រើនមកជុំគ្នានៅលើផ្លូវធំ ។ អ្នកភូមិមួយចំនួនបានបន្តការវាយតបត ដោយចាក់សម្លាប់យោធាខ្មែរក្រហមមួយចំនួនដែលទៅចាប់ខ្លួនអ្នកភូមិ ។ លើសពីនេះទៅទៀត អ្នករស់រានមានជីវិតបានឲ្យដឹងថា ខ្មែរក្រហមបានបាញ់កាំភ្លើងធំទៅលើផ្ទះ អ្នកភូមិ ឬក៏បាញ់គ្រាប់បេ៤០ *(B-40)* មុនពេលចូលទៅក្នុងភូមិ ។ ផ្ទះប្រហែលជា៣០ខ្នង ត្រូវបានបំផ្លាញនៅក្នុងហេតុការណ៍នេះ ។ ស្ត្រីម្នាក់បាននិយាយថា ប្ដីរបស់គាត់ត្រូវបានចាប់អូសចេញពីផ្ទះ និងដុតទាំងរស់នៅលើផ្លូវ ដោយសារការប្រឆាំងតវ៉ាពីក្នុងផ្ទះ ។

អ្នកភូមិត្រូវបានបណ្ដើរចេញជាច្រើនខ្សែ និងត្រូវបានបែងចែកជាក្រុម បុរសមួយក្រុម ស្ត្រីមួយក្រុម ក្មេងមួយក្រុម ។ អ្នករងរបួសត្រូវបានគិតថាជាអ្នកប្រឆាំងដែលត្រូវបានខ្មែរក្រហមនាំយកទៅសម្លាប់ចោល ។ អ្នកភូមិដែលជាបុរសត្រូវបានចាប់ដាក់ក្នុងគុកបណ្ដោះអាសន្ន នៅរោងសម្ងួតថ្នាំជក់ សាលាបឋមសិក្សា និងវត្ត ។ យើងគួរកត់សម្គាល់ថា ទោះបីជា ស្វាយឃ្លាំងជាភូមិចាម តែភូមិនេះគឺស្ថិតនៅជិតភូមិខ្មែរ ។ ចាមនៅស្វាយឃ្លាំង និងអ្នកភូមិដទៃទៀតដាំថ្នាំជក់ និងធ្វើរោងសម្ងួតជាច្រើននៅទូទាំងតំបន់នោះ ។ ស្ត្រីត្រូវបានដាក់នៅក្នុងវត្តពីរដែលស្ថិតនៅក្បែរនោះ ។ អ្នកជាប់ឃុំជាច្រើនត្រូវបានសួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់ ។ អ្នកជាប់ឃុំឃាំងទាំងនោះត្រូវបានបង្អត់អាហារ ដាក់ឲ្យសត្វល្អិតខាំ និងទុកឲ្យចុះស្គមកំប្រឹង ។ អ្នកជាប់ឃុំត្រូវបានដោះលែងប្រហែលជាមួយខែក្រោយមក និងអ្នកជាប់ឃុំជាបុរសត្រូវបានសម្លាប់ចោល ។ អ្នកដែលត្រូវបានដោះលែងត្រូវបញ្ជូនទៅស្រុកស្ទឹងត្រង់ និងតំបែរ និងក្រោយមកបំបែកឲ្យទៅជាក្រុមតូចៗ ដែលបន្ទាប់មកត្រូវបានដាក់បញ្ចូលឲ្យរស់នៅជាមួយក្រុមគ្រួសារខ្មែរ ។ អ្នករស់រានមានជីវិតខ្លះបាននិយាយថា ខ្លួនត្រូវបានដាក់នៅតំបន់ដែលសម្បូរជំងឺគ្រុនចាញ់ ។ ប្រជាជនចាមជាច្រើនស្លាប់ដោយសារជំងឺនេះ ។

នៅក្នុងឆ្នាំ១៩៧៨ អ្នកភូមិត្រូវបានហៅឲ្យត្រឡប់ទៅស្វាយឃ្លាំងវិញ នៅពេលខ្មែរក្រហមធ្វើបន្សុទ្ធកម្មនៅភូមិភាគបូព៌ា ។ អ្នកដែលបានមកដល់ស្រុកស្វាយឃ្លាំង ក្រោយមកត្រូវបានសម្លាប់ ។ ប្រជាជននៅភូមិស្វាយឃ្លាំង គឺជាប្រជាជនដែលក្លាហានគួរឲ្យកត់សម្គាល់នាំឲ្យពួកគេទទួលបានដាក់ការទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ ។ នៅឆ្នាំ១៩៧០ អ្នកភូមិមានចំនួនប្រហែល៦២០០នាក់ នៅក្នុងឆ្នាំ១៩៧៩ នៅសល់តែ៦០០នាក់ប៉ុណ្ណោះ ដែលភាគច្រើនជាស្ត្រី និងកុមារ ។ ពីពេលមួយទៅកាន់ពេលមួយ អ្នកភូមិបានរកឃើញគម្ពីរគួរអាន ដាវ និងរបស់របរផ្សេងៗ នៅពេលដែលកប់នៅក្នុងដីនៅជុំវិញផ្ទះ ។

## ៥) ភ័ស្តុតាងនៃអំពើប្រល័យពូជសាសន៍ ពីឆ្នាំ ១៩៧៥ - ១៩៧៩

បន្ទាប់ពីទទួលបានជោគជ័យ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីទីក្រុងទាំងអស់ទៅកាន់ទីជនបទ ដើម្បីដាំដុះ និងធ្វើការងារកសិកម្ម ។ ចាមនៅទូទាំងប្រទេសកម្ពុជា ត្រូវបានជម្លៀសពីទីក្រុងនានាទៅកាន់ផ្នែកផ្សេងៗនៃក្នុងប្រទេស ។ ចាមដែលរស់នៅទីក្រុងភ្នំពេញ ត្រូវបានបញ្ជូនទៅខេត្តកំពង់ឆ្នាំង បាត់ដំបង កណ្ដាល និងស្ថិតនៅក្នុងគម្រោងជម្លៀសលើកទីពីររបស់ខ្មែរក្រហមថែមទាំងជម្លៀសទៅខេត្តព្រះវិហារជាទីកន្លែងដែលចាម មិនដែលរស់នៅទាល់តែសោះ ។

ដូចប្រជាជនដែលធ្លាប់រស់នៅទីក្រុងដែរ ចាមត្រូវបានចាត់ទុកជា "ប្រជាជនថ្មី" នៅតាមទីជនបទ ។ ប្រជាជនចាមត្រូវបានស្នើឲ្យសង់ផ្ទះខ្លួនឯង ឬក៏រស់នៅជាមួយ "ប្រជាជនចាស់" ។ នៅក្នុងការគិតរបស់ខ្មែរក្រហម ប្រជាជនថ្មី គឺជាជនបដិវត្តន៍មិនស្អាតស្អំ ។ ប្រជាជនថ្មីត្រូវបានបង្ខំឲ្យធ្វើការដោយប្រើកម្លាំងពលកម្ម ដែលខ្មែរក្រហមជឿថា ប្រជាជនទាំងនោះមិនដែលធ្វើការងារទាំងអស់នោះទេ កាលពីនៅទីក្រុង ។ ពួកគេត្រូវតែទទួលការហ្វឹកហាត់ អប់រំ និងរៀនសូត្រឡើងវិញ តាមមាគ៌ាបដិវត្តន៍ ហើយពួកគេមិនអាចជឿទុកចិត្តបានទេ ។ ក្នុងគំនិតរបស់ខ្មែរក្រហម ចំពោះជនជាតិចាមគឺអាក្រក់ជាងប្រជាជនថ្មីនៅទីក្រុងទៅទៀត ។ ខ្មែរក្រហមមិនសួរ

ជាយល់ពីជនជាតិចាមប៉ុន្មានទេ បើប្រៀបទៅនឹងប្រជាជនខ្មែរ ។ បើទោះបីជា ចាមដែលរស់នៅជនបទត្រូវបានផ្លាស់ប្តូរទីកន្លែង ជនជាតិចាមទាំងនោះនៅតែត្រូវបានខ្មែរក្រហមចាត់ទុកជាប្រជាជនថ្មីនៅតំបន់ថ្មី ។ នេះជាការប៉ុនប៉ងរបស់ខ្មែរក្រហមក្នុងការបំបែក និងធ្វើឲ្យសហគមន៍ចាមឯកោ ។

ក្នុងពេលជាមួយគ្នានោះដែរ អ្នកដឹកនាំចាមជាច្រើនត្រូវបានរកមុខ និងសម្លាប់ចោល ។ មាយឃើល វិឃើរី *(Michael Vickery)* បានបញ្ជាក់ថា នៅឆ្នាំ១៩៧៥ ដល់១៩៧៧ ក្រុម សេ.អ៊ី.អា បានទទួលព័ត៌មានសំខាន់តាមរយៈឧបករណ៍លបស្តាប់អេឡិចត្រូនិចដ៏ជឿនលឿនមួយ ។ តាមព័ត៌មានដែលភ្នាក់ងារ សេ.អ៊ី.អា ទទួលបានបង្ហាញថា មេដឹកនាំចាមជាច្រើននៅក្នុងភូមិមួយត្រូវបានសម្លាប់នៅកណ្តាលប្រទេសកម្ពុជា ដែលការសម្លាប់នោះបញ្ជាមកពីភ្នំពេញ ។

ហេតុការណ៍ក្នុងអំឡុងពេលពីរឆ្នាំនោះ បានបង្ហាញថាខ្មែរក្រហមបានប៉ុនប៉ងជាច្រើនលើកក្នុងការលុបបំបាត់អត្តសញ្ញាណស្នូលរបស់ជនជាតិចាម ដោយខ្មែរក្រហមប្រើទាំងធម៌ត្រជាក់ និងធម៌ក្តៅដើម្បីសម្រេចគោលបំណងនោះ ។ ធម៌ត្រជាក់រួមមានការហាមប្រាមមិនឲ្យប្រណិប័តន៍សាសនាអ៊ីស្លាម បង្ខំឲ្យជនជាតិចាមហូបសាច់ជ្រូក កាត់សក់ស្ត្រីជនជាតិចាមឲ្យខ្លី លុបបំបាត់សម្លៀកបំពាក់ប្រពៃណី ដុតបំផ្លាញ គម្ពីរគួរអាន បំផ្លាញព្រះវិហារអ៊ីស្លាម ហាមឃាត់ការបន់ស្រន់បែបសាសនាអ៊ីស្លាម ហាមប្រើប្រាស់ភាសាចាម និងប្តូរឈ្មោះពីចាមមកខ្មែរវិញ ។ ខ្មែរក្រហមថែមទាំងបានបំបែកសហគមន៍ជាក្រុមគ្រួសារតូចៗ ហើយបញ្ជូលពួកគេទៅក្នុងភូមិខ្មែរនានានៅទូទាំងប្រទេស ។ ដូចបានរៀបរាប់ក្នុងជំពូកទី២ ប្រជាជនចាមមានទំនោរចង់រស់នៅជាសហគមន៍រួមគ្នា ដែលស្វ័យភាពផ្អែកសាសនាអ៊ីស្លាម និងហេដ្ឋារចនាសម្ព័ន្ធវប្បធម៌ ។ ចំណែកឯធម៌ក្តៅដែលខ្មែរក្រហមប្រើប្រាស់ទៅលើជនជាតិចាម គឺការសម្លាប់បុគ្គលសំខាន់ៗ របស់ជនជាតិចាមរួមមាន គ្រូបង្រៀនសាសនា ហាគីម ទួនហាជី និងអ្នកនយោបាយ មិនតែប៉ុណ្ណោះ ជនជាតិចាមសាមញ្ញក៏ត្រូវបានសម្លាប់ផងដែរ ។

ការប្រឆាំងនឹងការបះបោររបស់ជនជាតិចាម នៅចុងខែកញ្ញា និងដើមខែតុលាឆ្នាំ១៩៧៥ ដែលកើតឡើងនៅកោះផល និងស្វាយឃ្លាំងបាននាំឲ្យកើតមានបច្ច័យអាក្រក់ដល់ប្រជាជនចាមនៅស្រុកក្រូចឆ្មារ ក៏ដូចជាចាមនៅទូទាំងភូមិភាគបូព៌ា និងភូមិភាគដទៃទៀត ។ នៅក្នុងឆ្នាំ១៩៧៨ អ្នកនៅរស់រានមានជីវិតជាច្រើននាក់បានរាយការណ៍នៅគ្រប់ទីកន្លែងថា មានការសម្លាប់ជាតិសាសន៍ប្រឆាំងនឹងជនជាតិចាម ។ យូរណាស់មកហើយ ខ្មែរក្រហមមិនដែលយល់អំពីអត្តសញ្ញាណស្នូលរបស់ជនជាតិចាមទេ វាក្លាយជាផ្នែកមួយសំខាន់ក្នុងការបង្កើតឲ្យមានក្រុមអ្នកបះបោរ និងក្រុមប្រឆាំងដែលចូលរួមដោយបុរស ស្ត្រី និងកុមារ ជនជាតិចាម ។ ការសម្លាប់ជនជាតិចាមទាំងនោះក៏អាចកើតឡើងដោយសារកម្លាំងរុញច្រានឥតឈប់ឈរនៃការធ្វើបន្សុទ្ធកម្ម ដែលបានកើតឡើងនៅភូមិភាគកណ្តាល និង ភូមិភាគបូព៌ា នៅក្នុងអំឡុងពេលដូចគ្នានោះ ។

បន្ទាប់ពីអ្វីបានកើតឡើងនៅកោះផល និងស្វាយឃ្លាំង ខ្មែរក្រហមបានបើកការប្រជុំនៅទូទាំងភូមិភាគបូព៌ា ភូមិភាគឧត្តរ និងប្រហែលជានៅភូមិភាគដទៃទៀតបានព្រមានចាមពីលទ្ធផលនានានៃការបះបោរ ។ នៅពេលជាមួយគ្នានេះដែរ ខ្មែរក្រហមបានដាក់ផែនការទ្រង់ទ្រាយធំ ដើម្បីជម្លៀសចាមចេញពីភូមិភាគបូព៌ាទៅកាន់ភូមិភាគឧត្តរ បស្ចិម និងពាយ័ព្យ ។ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ កម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមឈ្មោះ ឈាន បានសរសេរទូរលេខ ១៥ ទៅកាន់ ប៉ុល ពត និងចម្លងជូន នួន ជា ។ ទូរលេខនោះ ក៏បានចម្លងជូនមន្ត្រីខ្មែរក្រហមពីរនាក់ផ្សេងទៀតឈ្មោះ ឌឿន និង យ៉ែម ។

យោងទៅតាមទូរលេខនោះ ឈាន បានសរសេរឆ្លើយតបនឹងបទបញ្ជាមួយពីការជម្លៀសប្រជាជនចាមពីដែនដីរបស់ជនជាតិចាមទាំងនោះនៅខាងកើតដងទន្លេមេគង្គ និងទូទាំងភូមិភាគបូព៌ាទាំងមូល ដែលបញ្ជានេះចេញមកដោយផ្ទាល់ពីមជ្ឈិមបក្សនៅទីក្រុងភ្នំពេញ ។ ឈាន សំដៅយ៉ាងច្បាស់ទៅរឿងនេះថា “យុទ្ធសាស្ត្របំបែកត្រូវបានលើកយកមកពិភាក្សាក្នុងការប្រជុំមុនៗ” ។ ឈាន បាន ប៉ាន់ប្រមាណថា ប្រជាជនចាមចំនួន ១៥០.០០០នាក់ នៅភូមិភាគបូព៌ា ត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ និងភូមិភាគឧត្តរ ។

ទោះបីជាយ៉ាងនេះក្តី ទូរលេខដដែលនេះ ក៏បានបង្ហាញថា ការជម្លៀសនេះមិនបានស្របទៅតាមការគ្រោងទុកទាំងស្រុងនោះទេ ដូចនេះ នាំឲ្យឈានសម្រេចចិត្តផ្ញើទូរលេខជាពិសេសនោះទៅកាន់ភ្នំពេញ ។ គាត់បានបញ្ជាក់ថាតំណាក់កាលដំបូងនៃយុទ្ធសាស្ត្របំបែកចាមគឺជម្លៀសជនជាតិចាមចេញពីស្រុកឆ្លូងនៃខេត្តក្រចេះ ស្រុកក្រូច

ឆ្នារ នៃខេត្តកំពង់ចាម ស្រុកពាមជីលាំង (សព្វថ្ងៃជាឃុំមួយនៅស្រុកត្បូងឃ្មុំ) នៃខេត្តកំពង់ចាម និងចាមទាំងឡាយដែលរស់នៅតាមបណ្ដោយព្រំដែនវៀតណាម ។ នេះគឺជាផ្នែកមួយនៃគម្រោងការចម្បង ដើម្បីជម្លៀសចាមរហូតដល់ចំនួន ៥០.០០០ នាក់ ។ ចុងបញ្ចប់ ១០០.០០០នាក់ ដែលនៅសេសសល់នៅភូមិភាគបូព៌ាអាចនឹងត្រូវជម្លៀស ។ យោងទៅតាមទូរលេខនេះ ខ្មែរក្រហមនៅភូមិភាគបូព៌ា ត្រូវប្រមូល និងដឹកជញ្ជូនចាមឆ្លងទន្លេមេគង្គ ចំណែកឯខ្មែរក្រហមដែលនៅភូមិភាគឧត្ដរនឹងប្រមូល និងបំបែកប្រជាជនចាមនៅភូមិភាគឧត្ដរ និងបញ្ជូនបន្តទៀតទៅភូមិភាគពាយ័ព្យ ។ អ្វីដែលកើតឡើងនៅពេលនោះ គឺខ្មែរក្រហមនៅភូមិភាគឧត្ដរបានបដិសេធមិនព្រមទទួលចាមទាំងនោះ ។ ឈោន បានសរសេរថា ខ្លួនអាចទទួលតែប្រជាជនខ្មែរប៉ុណ្ណោះ ។ ហេតុអ្វីបានជាមានការរើសអើងយ៉ាងនេះ? គ្មាននរណាម្នាក់ដឹងរឿងនេះទេ ។ ប៉ុន្តែ យើងអាចទស្សន៍ទាយបានថា ប្រជាជនចាមប្រហែលជាត្រូវបានចាត់ទុកថាជាសមាសភាពដែលបង្កគ្រោះថ្នាក់ ពិបាកធ្វើការអប់រំ និងគ្រប់គ្រង ដោយសារខុសជាតិសាសន៍ វប្បធម៌ និងសាសនា ។

ទូរលេខនេះក៏បានបង្ហាញពីតម្រុយមួយចំនួនផងដែរថា តើខ្មែរក្រហមគិតពីតំបន់ផ្សេងៗរបស់ចាមយ៉ាងដូចម្ដេច? ឈោន បានបញ្ជាក់យ៉ាងច្បាស់លាស់ថា ការព្រមព្រៀង ឬបទបញ្ជាមួយដាក់លាក់ ត្រូវបានដាក់ចេញនៅក្នុងកិច្ចប្រជុំមួយថា ចាមនាំចេញពីស្រុកឆ្លូងនឹងមិនត្រូវបញ្ចូលត្រឡប់ទៅស្រុកដើមវិញនោះទេ ។ ដូចបានរៀបរាប់ខាងដើម ស្រុកឆ្លូងគឺជាស្រុកដែលមានជនជាតិចាមរស់នៅច្រើនជាងគេនៅកម្ពុជា ។ ខ្មែរក្រហមដឹងថាការធ្វើដូច្នេះប្រហែលជាទទួលស្គាល់ពីសារសំខាន់នៃការបំបែកនៅស្រុកឆ្លូង ។ ខ្មែរក្រហមបានប្រើលេសយ៉ាងសមរម្យក្នុងការជម្លៀសប្រជាជនចាម ដូចជាប្រាប់ពួកគេថា ការជម្លៀសប្រជាជនចាមទៅភូមិភាគពាយ័ព្យ ដោយសារតែទីនោះសម្បូរស្រែជាច្រើន ដែលត្រូវប្រមូលផល ដូចនេះ សហគមន៍ឆ្លូងនឹងយល់ព្រមរើចេញដោយគ្មានការតវ៉ា ។

ទូរលេខនេះបានបង្ហាញដែរថា តំបន់ទន្លេមេគង្គ ជាពិសេសនៅត្រើយខាងកើតគឺជាទឹកដីចាម ហើយដើម្បីគ្រប់គ្រងចាមទូទាំងប្រទេស តំបន់ទាំងនេះត្រូវតែបំបែក ដូចដែលខ្មែរក្រហមបានអនុវត្តនៅក្នុងស្រុកឆ្លូង ក្រូចឆ្មារ និងឆាប់ៗខាងមុខនេះគឺស្រុកត្បូងឃ្មុំ ។ ខ្មែរក្រហមបានទទួលស្គាល់ពីភាពផុយស្រួយនៃការគ្រប់គ្រងរបស់ខ្លួននៅតំបន់នេះ ដូចដែល ឈោន បានសរសេរថា ស្ថានភាពចាំបាច់ត្រូវធ្វើឲ្យធូរស្រាល» ទូរលេខនេះក៏បង្ហាញដែរថា មេរៀនពីឧបត្ថិហេតុនៅកោះផល និងស្វាយឃ្លាំងខ្មែរក្រហមព្រួយបារម្ភខ្លាចជនជាតិចាមប្រតិកម្មតបនឹងការគ្រប់គ្រងយ៉ាងព្រៃផ្សៃរបស់ខ្លួន និងការអនុវត្តគោលនយោបាយ និងការសម្លាប់ទុកជាការដាក់ទោសចំពោះការប្រឆាំងនឹងបញ្ជារបស់អង្គការ ។ ដូចនេះ ភូមិភាគបូព៌ា គឺជាទីតាំងដំបូងនិងធំរឹងមាំរបស់ខ្មែរក្រហម និងជាតំបន់ដែលចាមធ្លាប់លាក់ខ្លួនដើម្បីក្រោកឡើងប្រឆាំងនឹងព្រះមហាក្សត្រខ្មែរនានា ។ សម្រាប់ខ្មែរក្រហមការគ្រប់គ្រងទឹកដីរបស់ចាមបាន មានន័យថាខ្លួនអាចគ្រប់គ្រងជនជាតិចាម និងប្រជាជនមូស្លីមផ្សេងទៀតនៅកម្ពុជា ។ ប្រសិនបើការសម្លាប់ដោយការប្រកាន់ពូជសាសន៍ត្រូវការជាចាំបាច់ វានឹងមានលទ្ធភាពអាចអនុវត្តទៅបាន ។

ការឆ្លើយតបមួយទៅនឹងទូរលេខនេះ មិនត្រូវបានរកឃើញនោះទេ ។ ទោះជាយ៉ាងណាក្ដី យោងតាមអ្នករស់រានមានជីវិត ចាមត្រូវបានជម្លៀសទៅទូទាំងភូមិភាគបូព៌ា ។ តាមធម្មតា ខ្មែរក្រហមបានទុកគ្រួសារចាមប្រហែលពី២០ ទៅ៣០ គ្រួសារនៅក្នុងភូមិ ជាពិសេសអ្នកទាំងឡាយណាដែលមានជំនាញខាងនេសាទ និងជាងដែកក្រុមគ្រួសាររបស់មេភូមិ សមាជិកខ្មែរក្រហម និងជនជាតិចាមល្អៗដែលជាប្រជាជនចាស់ ។ ទោះជាភូមិភាគពាយ័ព្យ គឺជាទីតាំងគោលដៅមួយនៃការជម្លៀស អ្នករស់រានមានជីវិតជាច្រើនបានប្រាប់ថាខ្លួនត្រូវបានបំបែកទៅស្ទឹងត្រង់ និងនៅស្រុកជាច្រើនទៀតនៅក្បែរៗនោះដែលស្ថិតក្នុងភូមិភាគឧត្ដរ ។

នៅថ្ងៃទី២ ខែមេសា ឆ្នាំ១៩៧៦ លេខាភូមិភាគឧត្ដរបានផ្ញើទូរលេខ៩៨ ទៅកាន់ ប៉ុល ពត ដែលបានចម្លងជូន នួន ជា និង ខៀវ សំផន ។ ទូរលេខនោះបានរាយការណ៍ថា “ស្ថានភាពសត្រូវ ប្រជាជន និងការប្រមូលផលនៅភូមិភាគឧត្ដរ” ។

ចំណុចគួរឲ្យចាប់អារម្មណ៍នោះគឺវិធីដែល កែ ពក កំណត់មុខសញ្ញាថា ជាសត្រូវរបស់ខ្លួន និងការពិពណ៌នាពីសកម្មភាពនានារបស់សត្រូវទាំងនោះ ។ នៅពេលដែលសត្រូវ ត្រូវបានកំណត់ថាជាសត្រូវរបស់អង្គការជាទូទៅត្រូវបានចាប់ខ្លួន ធ្វើទារុណកម្ម សួរចម្លើយ និងសម្លាប់ចោល ។ កែ ពក បានសរសេរថា “សត្រូវបាន

ប្រព្រឹត្តសកម្មភាពអាក្រក់មួយចំនួន រួមមានឃោសនាថា បដិវត្តន៍គីងវីងពេក និយាយប្រឆាំងការរៀបបចំនានារបស់សហករណ៍ និយាយប្រឆាំងនឹងការធ្វើស្រែ និងផ្សព្វផ្សាយតគ្នាពីការអត់ឃ្លាន» ។ កែ ពក បានបង្ហាញថា ស្រុកចម្ការលើ ចាម និងអតីតទ័ពសម័យលន់ នល់ នៅតែគោរពខ្មែរសាធារណរដ្ឋ ដោយបានបិតរូបជាច្រើនរបស់លន់ នល់ នៅលើដើមឈើ ក៏ដូចជាបំផ្លាញដំណាំ ។ ខ្មែរក្រហមតែងតែស្វែងរកអតីតទាហានលន់ នល់ ដើម្បីសម្លាប់ចោលឲ្យអស់ ។ សត្រូវទាំងនោះត្រូវបានដោរកចាប់ខ្លួនពីថ្ងៃដែលខ្មែរក្រហមជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ និងក្រុងផ្សេងៗទៀត និងស្វែងរករហូតក្នុងឆ្នាំដែលខ្មែរក្រហមកាន់កាប់ ។ នៅពេលដែលចាមត្រូវចាត់បញ្ចូលក្នុងក្រុមជាមួយទាហានលន់ នល់ ធ្វើឲ្យជនជាតិចាមទាំងនោះស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ជាពិសេស បន្ទាប់ពីជនជាតិចាមទាំងនោះត្រូវបានសង្ស័យ បន្ទាប់ពីការបះបោរនៅកោះផល និងស្វាយឃ្លាំង ។ ទាំងនេះអាចក្លាយជាកត្តាមួយឈានទៅដល់ការសម្លាប់ ដោយការប្រកាន់ពូជសាសន៍ ដែលកើតឡើងនៅឆ្នាំ១៩៧៨ ។

នៅកន្លែងផ្សេងទៀតនៅកម្ពុជា សេចក្តីស្អប់ប្រឆាំងនឹងចាមបានបន្តរីកដុះដាល ។ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ មន្ត្រីយោធាខ្មែរក្រហមជាច្រើនបានរៀបចំការប្រជុំជាមួយលេខា និងអនុលេខានៃកងពលធំ និងកងវរសេនាធំនានា ។ ទីតាំងនៃការប្រជុំមិនត្រូវបានលើកឡើងនោះទេ ប៉ុន្តែ បើ វិនិច្ឆ័យលើប្រវត្តិអ្នកចូលរួមជាច្រើន និងរបៀបវារៈ ដែលបានរួមបញ្ចូលទាំងការរៀបចំកម្មវិធីរំលឹកការស្លាប់របស់ ម៉ៅ សេទុង នៅពហុកីឡដ្ឋានអូឡាំពិកនៅទីក្រុងភ្នំពេញ ដូចនេះការប្រជុំនេះ ប្រហែលជាធ្វើឡើងនៅទីក្រុងភ្នំពេញ ។ ក្នុងចំណោមអ្នកដែលចូលរួមនោះ មានសមមិត្ត ពិន (ជាលេខាកងពលធំ៧០៣) និងបង៨៩ ។ បង៨៩ បានធ្វើបទបង្ហាញគួរឲ្យកត់សម្គាល់ពី ម៉ៅ សេទុង និងការយល់ដឹងពីទំនាក់ទំនងកម្ពុជា-ចិន ។ សមមិត្ត ពិន បានរាយការណ៍ពីសភាពការណ៍នៅ តំបន់ឆ្នេរ នានានៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៧៦ នៅភូមិស្រែចាម ស្រុកព្រៃនប់ «ចាមកំពុងតែសម្ងៀងការំបិត ឈប់ធ្វើការ និងរៀបចំដើម្បីបះបោរប្រឆាំងនឹងខ្មែរ» ។ នេះបង្ហាញយ៉ាងច្បាស់ពីការកំណត់បែងចែកពូជសាសន៍ដោយមេបញ្ជាការកងទ័ពខ្មែរក្រហមនៅក្នុងតំបន់នោះ ។ វាមិនមែនចាមប្រឆាំងនឹងអង្គការទេ ប៉ុន្តែប្រឆាំងនឹងជាតិសាសន៍ខ្មែរ ។ ដោយសាក្រោយមកសមាជិកដឹកនាំរបស់អង្គការជាសាសន៍ខ្មែរ វាជាការប្រឆាំងនឹងអង្គការ និងជាតិសាសន៍ខ្មែរ ។ ភូមិស្រែចាម គឺជាភូមិមួយ នៅក្នុងស្រុកព្រៃនប់ ដែលជា សហគមន៍ចាមដ៏ធំមួយ ។

នៅដើមឆ្នាំ១៩៧៦ ចាមជាង៣០នាក់នៅស្រុកព្រៃនប់បានរត់ចូលព្រៃដើម្បីបះបោរប្រឆាំងនឹងអំណាចគ្រប់គ្រងរបស់ខ្មែរក្រហមដោយហេតុថា ខ្មែរក្រហមបានហាមប្រាមមិនឲ្យគោរពសាសនាអ៊ីស្លាម និងការរឹតបន្តឹងផ្សេងៗទៅលើសហគមន៍របស់ចាម ។ ក្រុមនេះមានបំណងចង់សុំជំនួយពីប្រទេសម៉ាឡេស៊ី ដោយបញ្ជូនបុរសបួននាក់ជិះទូកឆ្លងឈូងសមុទ្រថៃចេញពីកន្លែងមួយនៃកំពង់សោម ។ ទោះជាយ៉ាងនេះក្តី ជំនួយពីប្រទេសម៉ាឡេស៊ីមិនដែលឃើញមកដល់នោះទេ មិនតែប៉ុណ្ណោះទូកនោះបានលិចនៅសមុទ្រភាគខាងជើងនៃប្រទេសម៉ាឡេស៊ី មានតែអ្នកដំណើរម្នាក់គត់ក្នុងចំណោមអ្នកដំណើរទាំងអស់នៅលើទូក ឈ្មោះ ទូន មិត ដែលនៅរស់រានមានជីវិត ។ ដោយសារគ្មានសមាជិកផ្សេងទៀត និងវត្ថុមានតម្លៃ ទូន មិត មិនអាចបញ្ចុះបញ្ចូលប្រជាជនមូស្លីមនៅប្រទេសម៉ាឡេស៊ីឲ្យជួយបាន ក៏ត្រឡប់មកស្រុកព្រៃនប់វិញឲ្យទាន់ពេលវេលាណាត់ជួបជាមួយមិត្តអ្នកប្រយុទ្ធជាច្រើន ដែលរង់ចាំនៅក្នុងព្រៃនោះទេ ។ អ្នកប្រយុទ្ធជាច្រើនត្រូវសម្លាប់ក្នុងពេលដែលខ្មែរក្រហមវាយប្រហារ ។ អ្នកខ្លះបានរត់រួចទៅប្រទេសវៀតណាម និងបានចូលរួមជាមួយកងទ័ពវៀតណាម ។

ក្នុងចំណោមអ្នករត់ចូលព្រៃទាំងនោះ ទេព យុនុស ដែលត្រូវបានចាប់ខ្លួននៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៧៦ ត្រូវបានបញ្ជូនទៅមន្ទីរស-២១ ។ គាត់ត្រូវបានសម្លាប់មួយខែក្រោយ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ ។ យុនុស បានបន្សល់ចម្លើយសារភាពចំនួន ១៣ទំព័រ បានរៀបរាប់ប្រាប់ពីដំណើរជីវិតផ្ទាល់ខ្លួនចូលរួមជាមួយក្រុមរបស់ ទូន មិត្ត និងរបៀប ដែលខ្លួនអាចរស់រានមានជីវិត ។ ទោះបីជាគាត់ត្រូវបង្ខំឲ្យសារភាពក៏ដោយរឿងរ៉ាវរបស់គាត់មានជាប់ទាក់ទងគ្នានឹងសក្ខីកម្មរបស់ប្រជាជនដែលរស់រានមានជីវិតនៅស្រុកព្រៃនប់ ។ ។

ព្រឹត្តិការណ៍ចាមបះបោរនៅស្រុកព្រៃនប់រឹតតែធ្វើឲ្យខ្មែរក្រហមព្យាយាមធ្វើឲ្យចាមឯកកោ បំបែកឲ្យបែកខ្ញែកពីគ្នា និងសម្លាប់សមាជិកនានាក្នុងសហគមន៍ ជាពិសេសបន្ទាប់ពីមានការបះបោរ

ស្រដៀងគ្នា នៅក្នុងខេត្តកំពង់ចាម ។ ឆ្នាំ១៩៧៧ ចាមនៅក្នុងស្រុកព្រៃឈរត្រូវបានបំបែកឲ្យទៅខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង ។ ការបះបោរនៅព្រៃឈរក៏បានបង្ហាញពីទំនាក់ទំនងប្រពៃណីអន្តរជាតិរវាងជាមួយនឹងប្រជាជនមូស្លីមនៅប្រទេសម៉ាឡេស៊ី និងក្នុងតំបន់ ។

ឯកសារខ្មែរក្រហមមួយទៀតចុះ ថ្ងៃទី២១ ខែឧសភា បានបង្ហាញពីភ័ស្តុតាងគួរឲ្យរន្ធត់មួយចំនួន ស្តីអំពីប្រតិកម្មរបស់ខ្មែរក្រហមនឹងប្រជាជនចាម ដែលមិនព្រមបរិភោគសាច់ជ្រូក និងការត្អូញត្អែរអំពីទង្វើនេះ ។ យើងអាចបកស្រាយតាមរយៈរបាយការណ៍នេះ បានថា វិធីសាស្ត្ររបស់ខ្មែរក្រហមគឺប្រឆាំងនឹងការបញ្ចេញមតិក្នុងន័យការពារសេរីភាពក្នុងការប្រណិបតន៍សាសនាអ៊ីស្លាម ។ ឯកសារនេះគឺជារបាយការណ៍មួយរបស់លេខាធិការដ្ឋានតំបន់៥ នៃភូមិភាគពាយ័ព្យផ្ញើទៅកាន់លេខាធិការភូមិភាគ ។

ឯកសារនេះបានបង្ហាញថា តំបន់៥ មានសមត្ថកិច្ចចាត់វិធានការក្តៅមួយចំនួនប្រឆាំងនឹងជនទាំងឡាយណាដែលត្រូវខ្មែរក្រហមចាត់ទុកជាអ្នកបះបោរ ជនក្បត់ និងជនណាជាសត្រូវរបស់អង្គការ ។ របាយការណ៍នេះបានបញ្ជាក់ថា ក្មេងប្រុសអាយុ១៣ឆ្នាំម្នាក់ដែលជាកូនប្រុសរបស់គ្រួសារ ប្រជាជន១៧មេសា (ប្រជាជនថ្មី) បានចោលដុំថ្មទៅលើដំបូលសហករណ៍ ដើម្បីបន្លាចអ្នកដែលនៅគេងខាងក្នុងនោះ ថាមានខ្មោចលង ។ លេខាតំបន់៥ បានសរសេរថា យើងបានដោះស្រាយរួចរាល់ហើយ ដោយបានចាប់ក្មេងប្រុសនោះ ជាពិសេស ស្វែងរកជនក្បត់ផ្សេងទៀត ដែលបញ្ជាឲ្យក្មេងប្រុសនោះប្រព្រឹត្តដូចនេះ ។ ការសង្ស័យរបស់ខ្ញុំ គឺថា ជនទាំងនោះបានមានបំណងធ្វើឲ្យប្រជាជនសម្រាន្តមិនលក់ ។ ដូចនេះ យើងអាចនឹងផ្លាស់កន្លែងស្នាក់នៅរួមដែលនឹងត្រូវចំណាយពេលយូរដើម្បីសាងសង់ ។ «ពួកក្បត់ទាំងនេះ អាចនឹងបន្តសកម្មភាពក្បត់នៅពេលខាងមុខទៀត» ។

បន្ទាប់មក «របាយការណ៍បាននិយាយពីចាម ប្រជាជនចាម១៧មេសាមកពីភ្នំពេញតវ៉ានៅរោងបាយសហករណ៍អំពីការហូបចុកដោយសារសាសនារបស់ពួកគេ» ។ របាយកាណ៍នេះបានបន្តទៀតថា «ស្ថានភាពនេះយើងបានដោះស្រាយរួចហើយ ជាពិសេសកំពុងតែស្វែងរកខ្សែក្បត់ និងមេដឹកនាំដើម្បីយកមកកម្ទេច» ។

តាមរយៈរបាយការណ៍នេះ ខ្មែរក្រហមគិតថា ការបដិសេធមិនព្រមទទួលទានសាច់ជ្រូក គឺជាទង្វើមួយដែលប្រឆាំងនឹងបដិវត្តន៍ ។ របាយការណ៍នេះ គឺជាភ័ស្តុតាងមួយដែលបានបង្ហាញយ៉ាងច្បាស់ថា នៅត្រឹមឆ្នាំ១៩៧៧ ការបរិភោគរួម គឺត្រូវបានធ្វើឡើងពេញទំហឹង ចំណែកឯសាសនាអ៊ីស្លាមត្រូវបានហាមឃាត់ទាំងស្រុងផងដែរ ។ ជនដែលងើបឈរឡើងនិយាយការពារសាសនាអ៊ីស្លាមត្រូវបានចាត់ទុកថាជាជនក្បត់ ។ នេះសបញ្ជាក់យ៉ាងច្បាស់ថា ចាមដែលបដិសេធមិនព្រមបរិភោគសាច់ជ្រូកអាចនឹងត្រូវបានចាប់ខ្លួននិងសម្លាប់ចោល ដោយសារតែខ្មែរក្រហមយល់ថា ការប្រព្រឹត្តល្មើសនឹងបទបញ្ជា គឺជាសកម្មភាពសម្ងាត់ប្រឆាំងបដិវត្តន៍ ។ ចាមជាប្រជាជនថ្មីដែលជាប្រជាជនអ៊ីស្លាម និងជនជាតិភាគតិចក្នុងតំបន់ អាចនឹងត្រូវបានគិតថាជាជនបរទេសសម្រាប់ខ្មែរក្រហម ។ ដូចនេះ ជនជាតិចាមស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ ដែលឈានទៅដល់ការចាប់ខ្លួន និងសម្លាប់នៅគ្រប់ទីកន្លែង ។ ឧទាហរណ៍ ចាមម្នាក់មានឈ្មោះថា ស្មះ ការីម ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១ ដោយសារបដិសេធមិនព្រមទទួលទានសាច់ជ្រូក ។ ចម្លើយសារភាពរបស់គាត់បានបញ្ជាក់ថា «ខ្ញុំមិនសប្បាយចិត្តនឹងអង្គការដែលតម្រូវឲ្យហូបអាហារប្រឆាំងនឹងប្រពៃណីរបស់ខ្ញុំ ។ ខ្ញុំបានតវ៉ាឲ្យមានការហូបផ្សេងគ្នាជាមួយក្រុមជនជាតិខ្ញុំ» ។ ស្មះ ការីម ក្រោយមកត្រូវបានសម្លាប់ ។

សុះ ការី ដែលបច្ចុប្បន្ននេះជាមុហ្វទីនៃសហគមន៍អ៊ីស្លាមកម្ពុជា បានបង្ហាញថាពីភ័ស្តុតាងមួយចំនួនស្តីអំពីគោលបំណងរបស់ខ្មែរក្រហមក្នុងការលុបបំបាត់ប្រជាជនចាម ។ នៅក្នុងសម័យខ្មែរក្រហម គាត់បានលាក់អត្តសញ្ញាណជាតិសាសន៍របស់គាត់នឹងទទួលបានការទុកចិត្តពីខ្មែរក្រហមឲ្យមើលថែក្មេងៗ ។ គាត់ត្រូវអញ្ជើញទៅចូលរួមការប្រជុំមួយនៅឆ្នាំ១៩៧៧ នៅស្រុកចម្ការលើ ខេត្តកំពង់ចាម ។ សុះ ការី បាននិយាយថាការប្រជុំនោះ និយាយអំពី «ផែនការកម្ទេចខ្មាំង» ហើយអ្នកដឹកនាំអង្គប្រជុំនោះបានលើកឡើងថា «មានសត្រូវប្រឆាំងបដិវត្តន៍ជាច្រើន ប៉ុន្តែសត្រូវធំបំផុតគឺចាម ។ ដូច្នេះផែនការនោះ គឺផែនការកម្ទេចចាមឲ្យអស់មុនឆ្នាំ១៩៨០» ។ ថ្ងៃបន្ទាប់ សុះ ការី បានឃើញកំណត់ហេតុនៃការប្រជុំ ដែលបានបញ្ជាក់ថា «ចាមត្រូវតែកម្ទេចមុនឆ្នាំ១៩៨០» ។

នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានយកប្រជាជនចាមក្មេងៗ

ជាមុខសញ្ញា ។ ជនជាតិចាមម្នាក់ ដែលនៅរស់រានមានជីវិតឈ្មោះ ស្លេះ អាម៉ាត់បានឲ្យដឹងថា នៅក្នុងការប្រជុំមួយ នៅឆ្នាំ១៩៧៨ គាត់បានអមដំណើរជាមួយគណៈស្រុកក្រូចឆ្មារ ដើម្បីចូលរួមការប្រជុំមួយ នៅខេត្តកំពង់ធំ ។ ស្លេះ អាម៉ាត់ បានបន្ថែមថា ការប្រជុំនោះគឺជាការប្រជុំសំខាន់ដែលមានការចូលរួមគណៈស្រុកជាច្រើន មកពីភូមិភាគមជ្ឈិម និងបូព៌ា ។ គាត់បាននិយាយថា ការប្រជុំនេះដឹកនាំដោយ កែ ពក ដែលបាននិយាយនៅក្នុងពេលប្រជុំថា អ្នកទាំងអស់គ្នាត្រូវតែកម្ទេចជនជាតិចាមដែលនៅក្នុងកងចលតជាមុនសិន ពួកគេទាំងអស់នោះជាជនក្បត់ ។

## ការសម្លាប់ដោយប្រកាន់ពូជសាសន៍ប្រឆាំងនឹងចាម

មិនត្រឹមតែមានភ័ស្តុតាងជាឯកសារដែលអាចបញ្ជាក់ថា ខ្មែរក្រហមមានបំណងចង់ប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងចាមប៉ុណ្ណោះទេ អ្នករស់រានមានជីវិតពីការសម្លាប់ដោយប្រកាន់ពូជសាសន៍ក៏បានបង្ហាញឲ្យដឹងផងដែរថា នយោបាយប្រល័យពូជសាសន៍ដែលខ្មែរក្រហម បានអនុវត្តគឺប្រឆាំងនឹងប្រជាជនចាម ។

ឈុំ គា ត្រូវបានជម្លៀសទៅកាន់ភូមិខ្សាច់ប្រចេះកណ្ដាល ឃុំ និងស្រុកក្រូចឆ្មារនៅឆ្នាំ១៩៧៣ ។ គាត់បាននិយាយថា នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានជ្រើសរើសគ្រួសារចាមទាំងអស់ទៅសម្លាប់ ។ ដំបូងឡើយ ខ្មែរក្រហមបានប្រមូលបុរស ដោយប្រាប់ថា ឲ្យទៅសង់ផ្ទះនៅភូមិថ្មីមួយទៀត ។ មួយសប្តាហ៍ក្រោយមក ខ្មែរក្រហមបបានអញ្ជើញស្ត្រី និងកុមារទៅភូមិថ្មី និងបន្ទាប់មក ខ្មែរក្រហមបានសម្លាប់អ្នកទាំងអស់នោះ ។ បន្ទាប់ពីពេលនោះមក ស្ទើតែគ្មានជនជាតិចាមនៅសេសសល់ទៀតទេ ។

សាឡេះ អាម៉ាត់ បាននិយាយថា គាត់រួចរស់ជីវិតពីការសម្លាប់រង្គាលរបស់ខ្មែរក្រហមនៅឆ្នាំ១៩៧៨ ដោយសារគាត់លាក់អត្តសញ្ញាណជាតិសាសន៍របស់ខ្លួន ។ គាត់បានអះអាងថានៅក្នុងការសម្លាប់នៅឆ្នាំ១៩៧៨ អ្នកភូមិរបស់គាត់ភាគច្រើន (ភូមិឈូក ឃុំជីនីក ស្រុកក្រូចឆ្មារ) ត្រូវបានសម្លាប់ដោយខ្មែរក្រហម បានកុហកអ្នកភូមិដោយនិយាយថា នឹងបញ្ជូនទៅកន្លែងផ្សេងទៀត ។ តាមពិតពេលនោះអ្នកភូមិទាំងនោះ ត្រូវបានយកទៅសម្លាប់ ។ ស្លេះ អាម៉ាត់ បានឃើញទូកជាច្រើនត្រឡប់មកភូមិវិញជាមួយនឹងសម្លៀកបំពាក់ និងរបស់របរដែលនៅជាប់នឹងខ្លួនរបស់អ្នកភូមិទាំងនោះ ប៉ុន្តែគាត់មិនដែលឃើញអ្នកភូមិទាំងអស់នោះ ត្រឡប់មកភូមិវិញទេបន្ទាប់ពីឆ្នាំ១៩៧៩ ។

សាន គេមណាស់ គឺជាស្ត្រីចំណាស់ម្នាក់រស់នៅភូមិស្វាយឃ្លាំង ។ គាត់បាននិយាយថា ដើម្បីរួចផុតពីសេចក្តីស្លាប់ក្នុងរបបខ្មែរក្រហម គាត់ត្រូវតែកុហក ដោយបាននិយាយថា គ្រួសាររបស់គាត់គឺជាអ្នកក្រីក្រ មិនមានទំនាក់ទំនងអ្វីជាមួយរបប លន់ នល់ នោះទេ ។ គាត់ឆ្លាតជាងចាមផ្សេងទៀត ដែលបានប្រាប់ខ្មែរក្រហមពីអត្តសញ្ញាណសង្គម និងសេដ្ឋកិច្ចមុនឆ្នាំ១៩៧៥ ។ សាន គេមណាស់ បាននិយាយថា "ចាមមួយចំនួនមកពីភូមិត្រា បានឆ្លើយការពិតថា ពីមុនខ្លួនជាអ្នកមានទ្រព្យធន មានដីរជាច្រើន ឬក៏គោក្របី ។ ចាមមួយចំនួនទៀតបាននិយាយថា ខ្លួនជាទួន ឬ ហាគីម ។ ខ្មែរក្រហមបានសម្លាប់ក្រុមគ្រួសាររបស់ចាមទាំងអស់នោះ" ។

ក្រៅពីការសម្លាប់ សាន គេមណាស់ បាននិយាយថា "ខ្មែរក្រហមជាញឹកញាប់បានប្រកាសប្រាប់ចាមថា អ្នកទាំងអស់គ្នាមានឈាមតែមួយ គឺឈាមខ្មែរ ដូចនេះពុំចាំបាច់បែងចែកឲ្យមានការហូបចុក ការស្លៀកពាក់ ឬក៏ភាសាផ្សេងគ្នានោះទេ" ។ សម្ដីនេះត្រូវបានខ្មែរក្រហមពង្រឹងដោយការហាមប្រាមមិនឲ្យប្រណិប័តន៍សាសនាអ៊ីស្លាម និងផ្លាស់ប្តូរជនជាតិចាមទាំងអស់ឲ្យក្លាយជាអ្នកដែលគ្មានជំនឿលើព្រះ ។ អាក្រក់ជាងនេះទៅទៀត សាន គេមណាស់ ជាមួយនឹងចាម៨នាក់ផ្សេងទៀតត្រូវបានចាត់តាំងឲ្យចិញ្ចឹមជ្រូក ។

សាន់ ម៉ៃសាម បុរសចំណាស់ម្នាក់នៅភូមិស្វាយឃ្លាំង បានពិពណ៌នាពីការសម្លាប់រង្គាលមួយទៅលើចាមនៅឆ្នាំ១៩៧៨ ។ គាត់បាននិយាយថា ចាមចំនួន៨០ គ្រួសារត្រូវបានជ្រើសរើសក្នុងចំណោមភូមិខ្មែរ-ចាមនានា និងប្រមូលផ្តុំនៅវត្តមួយនៅភូមិខ្សាច់ក្រចេះលើ ។ គ្រួសាររបស់ សាន់ ម៉ៃសាម គឺជាគ្រួសារមួយក្នុងចំណោមនៃគ្រួសារទាំង៨០ នោះ ។ ប៉ុន្តែក្រោយមកកម្មាភិបាលខ្មែរក្រហម បានដកគ្រួសារគាត់ចេញពីក្រុមនោះដោយយល់ច្រឡំថា គ្រួសាររបស់ សាន់ ម៉ៃសាម ជាខ្មែរ ។ សាន់ ម៉ៃសាម បានបិទបាំងពីអត្តសញ្ញាណជនជាតិរបស់គាត់តាំងពីប៉ុន្មានឆ្នាំមុន ។ ខ្មែរក្រហមបានស្គាល់ថា គាត់ជាខ្មែរ ។ ខ្មែរក្រហមបាននិយាយថា "អង្គការមិនឲ្យទៅជាមួយអ្នកដទៃផ្សេងទៀតទេ ។ អ្នកជាខ្មែរ" ។ ប្រជាជនចាមចំនួន៨០ គ្រួសារត្រូវបានបញ្ជូនឡើងទូកនៅព្រឹកស្អែករួមជា

*មួយកូនៗ ។ គាត់សន្និដ្ឋានថា ប្រជាជនទាំងអស់នោះត្រូវបានសម្លាប់នៅភូមិមួយ នៅឆ្ងាយពីដងទន្លេ ដោយសារតែគាត់មិនដែលឃើញប្រជាជនទាំងអស់នោះវិលត្រឡប់មកវិញនោះទេ ហើយមានរណ្តៅសាកសពជាច្រើននៅរាយប៉ាយនៅទីនោះ ។*

*ម៉ាត់ សារ៉េន បានឲ្យដឹងថា នៅភូមិពង្រូរបស់គាត់ (ស្គាល់ក្នុងចំណោមអ្នកភូមិ ជាច្រើនថាភូមិស្វាយតាហេន) ស្រុកកងមាស មានតែ២០គ្រួសារក្នុងចំណោម២០០គ្រួសារប៉ុណ្ណោះ ដែលរស់រានមានជីវិតពីរបបខ្មែរក្រហម ។ ការបរិភោគរួមបានចាប់ផ្តើមឡើងនៅឆ្នាំ១៩៧៦ នៅក្នុងភូមិរបស់គាត់ ។ ក្នុងគោលបំណងធ្វើឲ្យអត្តសញ្ញាណរបស់ជនជាតិចាមចុះខ្សោយ ខ្មែរក្រហមបានហៅគាត់ និងអ្នកភូមិជាច្រើនថា ខ្មែរថ្មី (ឬក៏អ្នកថ្មី) ដែលមានន័យថា ចាមគឺជាសមាជិកថ្មីក្នុងក្រុមខ្មែរ ។ សម្រាប់ខ្មែរក្រហម នៅក្នុងករណីនេះ រនាំងបាំងរវាងភាពជាខ្មែរ និងភាពជាចាម គឺនៅស្ថិតត្រង់អត្តសញ្ញាណវប្បធម៌ និងអត្តសញ្ញាណសាសនា ។ នៅពេលអ៊ីស្លាមត្រូវបានលុបបំបាត់ជនជាតិចាមត្រូវបានបង្ខំឲ្យទៅរស់នៅតាមសហករណ៍នានាក្នុងនាមជាប្រជាជនថ្មី ។ ទោះជាយ៉ាងនេះក្តី ម៉ាត់ សារ៉េន បាននិយាយថា នៅត្រឹមឆ្នាំ១៩៧៨ ខ្មែរក្រហមបានប្រើការសម្លាប់ដើម្បីធ្វើឯកត្តភាពអត្តសញ្ញាណខ្មែរ និងដើម្បីពន្លឿនដំណើរការនេះ ។ ចំពោះខ្មែរក្រហមការប្តូរអត្តសញ្ញាណរបស់ចាម គឺពិបាកជាងអ្វីដែលខ្មែរក្រហមធ្លាប់បានគិត ។ យោងទៅតាម ម៉ាត់ សារ៉េន ចាមនៅស្រុកកងមាស និងស្រុកកំពង់សៀមត្រូវបានរកមុខសញ្ញា និងសម្លាប់រង្គាល នៅខណៈដែលខ្មែរមិនត្រូវបានប៉ះពាល់ ។ ប្រជាជនខ្មែរជួនកាលត្រូវបានសម្លាប់ដោយមូលហេតុផ្សេង ប៉ុន្តែចាមត្រូវបានសម្លាប់ដោយសារតែជាតិសាសន៍ ។ ជនជាតិចាមមួយចំនួនដែលរួចរស់ជីវិតពីការសម្លាប់ក្នុងឆ្នាំ១៩៧៨ ដោយសារតែមានការបង្អាក់ក្នុងការសម្លាប់នៅក្នុងឆ្នាំដែលខ្មែរក្រហមចាប់ផ្តើមផ្តោតទៅលើការវាយប្រយុទ្ធជាមួយវៀតណាម ដែលជាចំណុចគំរាមកំហែងមួយនៅភាគខាងកើត ។*

*ភូមិព្រែកក្របៅ ស្រុកក្រូចឆ្មារ ជី សាលេស* (Chi Sleh) *មានសំណាងបានរួចផុតពីការសម្លាប់នៅឆ្នាំ១៩៧៨ ។ គាត់គឺជាអ្នកនេសាទជំនាញម្នាក់ ដែលខ្មែរក្រហមត្រូវការឲ្យនេសាទ ត្រីនៅទន្លេមេគង្គ ដើម្បីយកទៅផ្គត់ផ្គង់នៅក្នុងសហករណ៍ ។ ជី សាលេសបានឃើញខ្មែរក្រហមប្រើល្បិចជាច្រើន ដើម្បីសម្លាប់ជនជាតិចាមរាប់រយគ្រួសារ ។ គាត់និយាយថា ខ្មែរក្រហមជាដំបូង បានបញ្ជូនបុរសជនជាតិចាមចំនួន២៨០នាក់ដែលជាបុរសឲ្យទៅសាងសង់ផ្ទះថ្មីនៅកន្លែងឆ្ងាយ មុនពេលដែលពួកគេត្រូវបានជម្លៀសទៅនៅកន្លែងថ្មីនោះ ។ ប៉ុន្មានថ្ងៃក្រោយមក ប្រពន្ធកូន និងសមាជិកគ្រួសាររបស់បុរសចាមទាំងនោះក៏ត្រូវបានបញ្ជូនទៅទីនោះដងដែរ ។ ប្រជាជនទាំងនេះមិនដែលឃើញត្រឡប់មក ភូមិព្រែកក្របៅវិញទេ ។*

*យ៉ាស់យ៉ា អាលី ធ្លាប់រស់នៅស្រុកស៊ឹងត្រង់ក្នុងសម័យខ្មែរក្រហម ។ នៅឆ្នាំ១៩៧៨ គាត់បានឃើញខ្មែរក្រហមនាំចាមពីភូមិរកាខ្នុរ និងភូមិជំនីក ទៅកាន់ភូមិមួយហៅថាភូមិបឹងប្រជួត ខណៈពេលដែលគាត់កំពុងតែរកត្រីនៅក្បែរនោះ ។ យ៉ាស់យា អាលី បាននិយាយថា ចាមរាប់រយនាក់ផ្សេងទៀត ត្រូវបានបញ្ជូនតាមទូកទៅកាន់កន្លែងមួយនៃស្រុកស៊ឹងត្រង់ ។ ខណៈនោះគាត់បានសួរទៅកាន់ចាមម្នាក់ ដែលគាត់ធ្លាប់ស្គាល់តាំងពីមុនសម័យខ្មែរក្រហមថា ហេតុអ្វីបានជាខ្មែរក្រហមនាំប្រជាជនទាំងនោះមកកាន់ទីនេះ ។ គាត់បានប្រាប់ថា ចាមត្រូវបានជម្លៀសទៅបាត់ដំបងជាកន្លែងដែលសម្បូរម្ហូបអាហារ និងការងារស្រែចម្ការធ្វើច្រើន ។ នៅប៉ុន្មានថ្ងៃនោះ យ៉ាស់យ៉ា អាលី បានឲ្យដឹងថា ខ្មែរក្រហមបានចាក់មេក្រូយ៉ាងឮនៅក្នុងភូមិជារៀងរាល់ថ្ងៃ ។ បន្ទាប់ពីឆ្នាំ១៩៧៩ គាត់បានឃើញរណ្តៅសាកសព និងគំនរខោអាវជាច្រើន របស់ជនរងគ្រោះនៅទីកន្លែងនោះ ។*

*គាត់បានដឹងថា ចាមត្រូវបានបោកប្រាស់ឲ្យយល់ថា ខ្លួនត្រូវបាននាំយកទៅខេត្តបាត់ដំបង ។ ប៉ុន្តែផ្ទុយទៅវិញ ប្រជាជនចាមត្រូវបានយកទៅសម្លាប់នៅស្រុកស៊ឹងត្រង់ ។ យ៉ា មិន ដែលបានរស់នៅស្រុកក្រូចឆ្មារនៅសម័យនោះទេ ប៉ុន្តែ យ៉ា ក៏បានជួបប្រទះរឿងកាប់សម្លាប់ចាមនៅក្នុងភូមិបឹងប្រជួត ស្រុកស៊ឹងត្រង់ដែរ ។*

*គាត់ក៏បានឃើញការសម្លាប់នៅភូមិទ្រា ស្រុកក្រូចឆ្មារផងដែរ ។ ការរៀបរាប់របស់ យ៉ាស់យ៉ា អាលី* (Yahya Ali) *ត្រូវបានបញ្ជាក់ដោយ យ៉ា មីន ដែលបានរៀបរាប់ថា គាត់បានឃើញការសម្លាប់ចាមអស់ជាច្រើនទូកនៅឆ្នាំ១៩៧៨ នៅក្នុងទីតាំងតែមួយនៅក្នុងស្រុកស៊ឹងត្រង់ ។*

*វាជាលំនាំដែលមានលក្ខណៈចម្លែកក្នុងការសម្លាប់ក្មេងស្រីជនជាតិចាម និងក្មេងស្រីខ្មែរកាត់ចាម ។ បន្ទាប់ពីខ្មែរក្រហម បាន*

សម្លាប់ឪពុកម្តាយរបស់ក្មេងស្រីទាំងនោះហើយ ខ្មែរក្រហមគិតថា ចាំបាច់តត្រូវសម្លាប់ក្មេងស្រីទាំងនោះទៀត ។ យោងតាមអ្នករស់រានមានជីវិតជាច្រើនបានឲ្យដឹងថា ខ្មែរក្រហមមិនមែនដៅរកតែស្ត្រីចាមសុទ្ធនោះទេ ប៉ុន្តែអ្នកដែលជាកូនកាត់ផងដែរ ។ យើងមិនច្បាស់ទេថា ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ស្ត្រីទាំងនោះ ។ វាប្រហែលជាអាចនិយាយបានថា ខ្មែរក្រហមមិនបានឲ្យតម្លៃទៅលើកូនកាត់សាសន៍ ដោយខ្លួនអាចគិតបានថា កូនកាត់ទាំងនោះមិនត្រូវបានឲ្យតម្លៃសម្រាប់ការបង្កើតក្មេងជំនាន់ក្រោយ របស់បដិវត្តន៍នោះទេ ។

អាម៉ាត់ សូហ៊ីយ៉ាស (Almad Sofiyah) បានរួចផុតពីការសម្លាប់ក្រុមក្មេងស្រីចាមមួយក្រុមដែលមានចំនួន៣៦ នាក់នៅភូមិទ្រា ស្រុកក្រូចឆ្មារនៅឆ្នាំ១៩៧៨ ។ គាត់បាននិយាយថា គាត់បានរស់ជីវិតដោយសារ គាត់ប្រាប់ខ្មែរក្រហមថា គាត់ជាខ្មែរ ។ ក្មេងស្រីដទៃទៀតដែលប្រាប់ការពិតត្រូវបានគេដាក់ដោយឡែក និងសម្លាប់ចោល ។ នៅក្នុងចំណោមក្មេងស្រី៣៦នាក់ មាន១៥នាក់កុហកថាពួកគេជាខ្មែរ (ពួកគេទាំងអស់សុទ្ធជាចាមមកពីភូមិជិតៗនេះ) ។ រឿងរ៉ាវរបស់ អាម៉ាត់ សូហ៊ីយ៉ាស់ ត្រូវបានបញ្ជាក់ដោយ នូ សាតាស (No Satas) និង សាន់ សារស (San Saros) ដែលអ្នកទាំងពីរប្រហែលជាអ្នកដែលនៅមានជីវិតរួចផុតពីការសម្លាប់ក្នុងហេតុការណ៍ដែលបានកើតឡើងដូចគ្នានៅភូមិទ្រា ។ សមាជិកគ្រួសារប្រាំបីនាក់របស់ នូ សាតាស ត្រូវបានសម្លាប់នៅឆ្នាំ១៩៧៨ ។

ម៉ៅ ម៉ែសាម (Mao Maisam) បានរួចជីវិតពីការសម្លាប់ក្រុមក្មេងស្រីចំនួន២៨០នាក់ នៅទីតាំងសម្លាប់តែមួយ ស្ថិតនៅភូមិទ្រានៅឆ្នាំ១៩៧៨ ។ គាត់រួចរស់ជីវិតដោយសារតែគាត់បានប្រាប់ទាហានខ្មែរក្រហមថា គាត់ជាខ្មែរប្អូនស្រីរបស់គាត់ទាំងអស់ត្រូវបានសម្លាប់ដោយសារតែមិនបាននិយាយកុហកពីអត្តសញ្ញាណជាតិសាសន៍របស់ខ្លួន ។ សាឡេះ សារស (Saleh Saros) ក៏បានរួចរស់ជីវិតពីការសម្លាប់ក្មេងស្រីចាមមួយក្រុម ដែលមានចំនួន២០០នាក់ នៅក្នុងឆ្នាំដូចគ្នានេះដែរ ។ យើងមិនដឹងច្បាស់ទេថា ម៉ៅ ម៉ែសាម និង សាឡេះ សារស ស្ថិតនៅក្នុងហេតុការណ៍តែមួយ ។ សាឡេះ សារស បានរស់រានមានជីវិតជាមួយនឹងប្អូនស្រីរបស់គាត់ ដោយសារតែពេលដែលខ្មែរក្រហមបានសួរគាត់ថា "អ្នកជាខ្មែរឬចាម?" គាត់បាននិយាយថា គាត់ជាខ្មែរ ។ ប៉ុន្តែ ខ្មែរក្រហមបានសួរសំណួរជ្រៅជាងនេះបន្តទៀតថា "ប្រសិនបើអ្នកជាខ្មែរ ហេតុអ្វីបានជាអ្នកមកទីនេះជាមួយក្មេងស្រីចាមទាំងនេះ?" សារស បាននិយាយថា គាត់រស់នៅក្បែរភូមិចាមជាច្រើន ។ បន្ទាប់មក គាត់ត្រូវបានដាក់ឲ្យនៅម្នាង ។

នៅតំបន់ដទៃទៀតក្នុងខេត្តកំពង់ចាម ជនជាតិចាមនៅភូមិមួយចំនួនដូចជា ភូមិរកាពោធិ៍ប្រាំ នៃស្រុកត្បូងឃ្មុំ ភូមិគោកូនៃស្រុកកំពង់សៀម និងភូមិអូរត្រកួននៃស្រុកកោះសូទិន ត្រូវបានខ្មែរក្រហមជ្រើសរើស ដោយផ្អែកលើអត្តសញ្ញាណជាតិសាសន៍ ដូចជាឈ្មោះការបញ្ចេញសំឡេងជាភាសាខ្មែរ និងការឆ្លើយសារភាពរៀងៗខ្លួន ។

**(តទៅលេខក្រោយ)**

**អេង កុកថាយ**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

Email: truthbunthorn.s@dccam.org

Home page: www.dccam.org

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល *truthphalla.c@dccam.org* ។





















# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគត ដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែលៈ truthpechet@dccam.org ។

**◆ ទីកន្លែង ៖ អគារ “ក” ជាន់លើ ◆ ពេលវេលា ៖ ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

# www.cambodiatribunal.org

គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org គឺជាប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងមូល ។ រយៈពេលកន្លងមកនេះព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយ នៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សំណុំរឿងព្រហ្មទណ្ឌលេខ០០២ដែលទាក់ទិននឹងជនជាប់ចោទពីរនាក់ទៀតគឺ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អនុលេខាបក្សនិងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២០១១ និងបានប្រកាសសាលក្រមលើកទីមួយកាលពីខែសីហា ឆ្នាំ២០១៤។

ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបានតាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org ត្រូវបានបង្កើតដោយមានផ្នែកជាច្រើនទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ វីដេអូសវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងនឹងសវនាការ សារព័ត៌មានផ្សេងៗជុំវិញតុលាការ របាយការណ៍របស់តុលាការ និងអង្គការក្រៅរដ្ឋាភិបាល ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ ប្រវត្តិសាស្ត្រ ប្រវត្តិរបស់តុលាការនេះ និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ ។

គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិ និងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញ និងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី “សហកម្មខក្រិដ្ឋកម្មរួម” ដែលភាសាអង់គ្លេសហៅថា “*Join Criminal Enterprise*” ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម “ផែនការឧក្រិដ្ឋកម្មរួម” ដែលភាសាអង់គ្លេសហៅថា “*Common Criminal Plan*” ។ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះឬបទអត្ថាធិប្បាយរបស់អ្នកជំនាញដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តើមានភាគីផ្សេងទៀតដែរឬទេដែលមានយោបល់ទៅលើបញ្ហានេះ?

ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ ។ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។

**ភ៊ាន់ថាន់ ពៅដាភ៊ា**

# គេហទំព័រទស្សនាវដ្ដីស្វែងរកការពិតជាភាសាខ្មែរ

## www.truthcambodia.com

ទស្សនាវដ្ដីស្វែងរកការពិត បង្កើតគេហទំព័រ www.truthcambodia.com ក្នុងគោលបំណងផ្សព្វផ្សាយ និងអប់រំឲ្យបានកាន់តែទូលំទូលាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) ដើម្បីសម្រេចឲ្យបាននូវការចងចាំ យុត្តិធម៌ និងការផ្សះផ្សាជាតិក្នុងសង្គមដែលទទួលរងនូវការបែកបាក់ និង សង្គ្រាមជាច្រើនទសវត្សរ៍ ។

គេហទំព័រ www.truthcambodia.com ក៏នឹងដើរតួនាទីដ៏សំខាន់ផងដែរក្នុងការចែករំលែកព័ត៌មានអំពីដំណើរការសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាមួយសាធារណជន និងជួយសាលាក្ដីក្នុងការរំលែកព័ត៌មានទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម នៅខណៈពេលអត្ថបទមួយចំនួននៅក្នុងគេហទំព័រនេះត្រូវបានយកទៅប្រើប្រាស់ជាភ័ស្តុតាងដើម្បីដាក់បន្ទុកមេដឹកនាំខ្មែរក្រហម ។

គេហទំព័រ www.truthcambodia.com បែងចែកជា៥ផ្នែកសំខាន់ គឺ១) ផ្នែកឯកសារ ២) ផ្នែកប្រវត្តិសាស្ត្រ ៣) ផ្នែកច្បាប់ ៤) ផ្នែកវេទិកាពិភាក្សាជាសាធារណៈ និង ៥) ផ្នែកស្រាវជ្រាវស្វែងរកក្រុម គ្រួសារដែលបានស្លាប់ ឬបាត់ខ្លួនក្នុងរបបខ្មែរក្រហម ។ នៅក្នុងគេទំព័រ www.truthcambodia.com ក៏មានផ្ទុកនូវឯកសារជាវីដេអូ, សំឡេង, រូបថត និងឯកសារដើមរបស់ខ្មែរក្រហមដែរ ។

អត្ថបទសម្រាប់ផ្នែកទី១) នឹងរៀបរៀងឡើង ដោយស្មេរមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយផ្អែកលើឯកសារដើមទាំងស្រុង ។ សរសេរឲ្យស្រួលអាន គឺការសង្ខេបចេញពីឯកសារដើមមកជាអត្ថបទ ។ គោលបំណងនៃផ្នែកនេះ គឺចង់ជម្រាបជូនសាធារណជនថាតើមានឯកសារអ្វីខ្លះដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ផ្នែកទី២) គឺជាអត្ថបទវិភាគលើប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ។ អត្ថបទផ្នែកនេះគឺជាអត្ថបទចូលរួមមកពីអ្នកជំនាញជាន់ខ្ពស់លើប្រវត្តិសាស្ត្រខ្មែរក្រហម ហើយមានទិសដៅសម្រិតសម្រាំងប្រវត្តិសាស្ត្រនេះឲ្យមានភាពកាន់តែសុក្រឹតទៅឡើងទៀត ។ ផ្នែកទី៣) គឺជាផ្នែកច្បាប់ដែលធ្វើការវិភាគដោយមេធាវី ឬចៅក្រម ឬអ្នកជំនាញការច្បាប់អន្តរជាតិ ។ ការវិភាគនេះនឹងជួយជាគំនិតលើផ្នែកច្បាប់ថា តើឧក្រិដ្ឋកម្មអ្វីខ្លះដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ហើយថា តើឧក្រិដ្ឋកម្មនីមួយៗត្រូវតែដោះស្រាយតាមនីតិវិធីបែបណា ដើម្បីរកឲ្យបាននូវយុត្តិធម៌ពិតប្រាកដមួយដល់ជនរងគ្រោះ ។ ផ្នែកទី៤) គឺជាវេទិកាពិភាក្សា និង ផ្ដល់គំនិតនានាលើបញ្ហាខ្មែរក្រហម ។ អត្ថបទទីនេះ គឺជាវិភាគទានចូលរួមពីសំណាក់អង្គការក្រៅរដ្ឋាភិបាលនានា សមាជិករាជរដ្ឋាភិបាល គ្រូ សិស្ស និស្សិត ជាដើម ។ល ។ ផ្នែកទី៥) គឺជាទំព័រស្រាវជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬ បាត់ខ្លួនក្នុងរបបខ្មែរក្រហម ឬការសាកសួររកព័ត៌មានអំពីមិត្តភក្តិ សាច់សារលោហិតដែលបានស្លាប់ដោយសាររបបខ្មែរក្រហម ។ ជាទំព័រឈឺចាប់ អាណោចអាធ័ម ប៉ុន្តែក៏ជាទំព័ររម្ងាប់ការមន្ទិលសង្ស័យដើម្បីសេចក្ដីសុខក្នុងខ្លួនជាអមតៈ ។

សរុបសេចក្ដីទៅផ្នែកទាំង៥ ខាងលើនៃគេហទំព័រ www.truthcambodia.com នឹងបើកចំហជូនដល់ការចូលរួមស្វែងរកការពិតពីសាធារណជនគ្រប់ស្រទាប់ ជាន់ថ្នាក់ ដោយមិនប្រកាន់ពណ៌សម្បុរ ភេទ អាយុ ឬនិន្នាការនយោបាយណាមួយឡើយ ។ គេហទំព័រ www.truthcambodia.com នឹងបម្រើដល់សាធារណជន និងដើម្បីជួយជ្រោមជ្រែងស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាគ្រប់រូប ។ គ្រប់លិខិត ឬអត្ថបទ ដែលផ្ញើមកកាន់គេហទំព័រ www.truthcambodia.com សូមដាក់ឈ្មោះ មុខងារ អាសយដ្ឋាន និងលេខទូរសព្ទសម្រាប់ធ្វើសេចក្ដីបញ្ជាក់លើខ្លឹមសារនៃលិខិត ឬអត្ថបទមុនការចេញផ្សាយ ។

គេហទំព័រ www.truthcambodia.com សូមរក្សាសិទ្ធិក្នុងការកែលម្អពាក្យពេចន៍នៃលិខិតទាំងឡាយ ក្នុងន័យថែរក្សានូវអត្ថន័យដើមទាំងស្រុង ។ ប៉ុន្តែ គេទំព័រ www.truthcambodia.com នឹងចុះផ្សាយទាំងស្រុងចំពោះអត្ថបទចូលរួមទាំងឡាយ ។

# ការស្លាប់របស់ជនជាប់ចោទ អៀង ធីរិទ្ធ : ស្ត្រីទីមួយដែលទទួលបានការយកចិត្តទុកដាក់ផ្នែកសម្បទាក្នុងការចូលរួមសវនាការ

នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៥ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រកាសជាសាធារណៈអំពីដំណឹងមរណៈភាពរបស់ អៀង ធីរិទ្ធ ដែលជាអតីតជនជាប់ចោទនៅក្នុងសំណុំរឿង០០២ ។ អៀង ធីរិទ្ធ គឺជាសមាជិកជាន់ខ្ពស់ម្នាក់នៅក្នុងជួររដ្ឋាភិបាល និងបានកាន់មុខតំណែងជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ កាលពីនៅឆ្នាំ ២០១០ លោកស្រី អៀង ធីរិទ្ធ ត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២ ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ។ អៀង ធីរិទ្ធ កើតនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៣២ នៅសង្កាត់លេខ៥ ក្រុងភ្នំពេញ ។ អៀង ធីរិទ្ធ បានចូលរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក្នុងទីក្រុងភ្នំពេញ ហើយបន្ទាប់មកទទួលបានសញ្ញាបត្រអក្សរសាស្ត្រអង់គ្លេសនៅប្រទេសបារាំង ។ អៀង ធីរិទ្ធ បានរៀបការជាមួយ អៀង សារី នៅឆ្នាំ ១៩៥១ ។ នៅឆ្នាំ១៩៥៧ អៀង ធីរិទ្ធ បានវិលត្រឡប់មកប្រទេសកម្ពុជាវិញ និងធ្វើជាគ្រូបង្រៀនភាសាអង់គ្លេស ។ ចំណែកបងស្រីរបស់ អៀង ធីរិទ្ធ ឈ្មោះ ខៀវ ប៉ុណ្ណារី បានរៀបការជាមួយ ប៉ុល ពត ។ អៀង ធីរិទ្ធ ត្រូវបានចោទពីបទជាប់ពាក់ព័ន្ធនឹង



រូបអង្គុយនៅលើរទេះអីរុញ អៀង ធីរិទ្ធ នៅក្នុងពិធីបុណ្យសពប្តី អៀង សារី នៅឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ កាលពីឆ្នាំ២០១៣

ការចាប់ខ្លួន និងសម្លាប់ សមាជិកមកពីក្រសួងសង្គមកិច្ច ។ នៅឆ្នាំ ១៩៩៦ អៀង ធីរិទ្ធ និង អៀង សារី បានចាកចេញពីខ្មែរក្រហម ។ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ បានបន្តតាំងពីពេលចាប់ខ្លួននៅឆ្នាំ២០០៧ រហូតដល់ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ ២០១២ ទើបអង្គជំនុំជម្រះតុលាការកំពូលចេញសេចក្តីសម្រេចដោះលែង អៀង ធីរិទ្ធ ដោយមូលហេតុនៃការវិវឌ្ឍនៃជំងឺវង្វេងវង្វាន់របស់ខ្លួនកាន់តែធ្ងន់ធ្ងរទៅៗ និងបានតែងតាំងអាណាព្យាបាលតាមផ្លូវច្បាប់ម្នាក់ ដែលត្រូវជាកូនស្រីបង្កើត ។

គួររំឭកថា អង្គជំនុំជម្រះសាលាដំបូង បានសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌលើកទីមួយនៅខែវិច្ឆិកា ឆ្នាំ២០១១ បន្ទាប់ពីបានរកឃើញថា ជនជាប់ចោទពុំមានសម្បទាខាងបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមការជំនុំជម្រះ ដោយបំបែកបទចោទប្រកាន់ចេញពីសំណុំរឿង០០២ និងផ្អាកនីតិវិធីប្រឆាំងនឹងជនជាប់ចោទរូបនេះ ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវបានបដិសេធដោយអង្គជំនុំជម្រះតុលាការកំពូល ដែលបង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទក្នុងរយៈពេល៦ខែទៀត ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងប្រឹងប្រែងក្នុងការប្រើប្រាស់ឲ្យអស់ពីលទ្ធភាពនូវវិធានការទាំងឡាយ ដែលមានក្នុងការជួយជនជាប់ចោទឲ្យមានភាពប្រសើរឡើងដើម្បីអាចចូលរួមការជំនុំជម្រះបាន ។ បន្ទាប់ពីការបើកសវនាការបន្តបន្ទាប់ ដើម្បីពិភាក្សាលើសម្បទារបស់ជនជាប់ចោទ ដោយអង្គជំនុំជម្រះ និងភាគីបានសួរដេញដោលអ្នកជំនាញផ្នែកវេជ្ជសាស្ត្រអស់ជាច្រើនលើកច្រើនសា និងមានការប្តឹងឧទ្ធរណ៍ជំទាស់លើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពីភាគីសហព្រះរាជអាជ្ញា រួចមកអង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចដោះលែងជនជាប់ចោទ ដោយដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។ ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនេះ ភ្ជាប់នឹងលក្ខខណ្ឌមួយចំនួនរួមមាន ៖ ១) ជនជាប់ចោទត្រូវជូនដំណឹងដល់អង្គជំនុំជម្រះអំពីអាសយដ្ឋានដែលខ្លួនត្រូវស្នាក់នៅ ហើយមិនត្រូវផ្លាស់ប្តូរទីលំនៅដោយពុំមានការអនុញ្ញាតពីអង្គជំនុំជម្រះឡើយ ២) ជនជាប់ចោទត្រូវប្រគល់លិខិតឆ្លងដែន និងឯកសារធ្វើដំណើរពាក់ព័ន្ធដទៃទៀត ហើយមិនត្រូវចេញក្រៅព្រំប្រទល់ដែនដីនៃព្រះរាជណាចក្រកម្ពុជាឡើយ និង ៣) ជនជាប់ចោទត្រូវគោរពតាមដីកាកោះ ដែលចេញដោយតុលាការ ។

ក្នុងចំណោមជនជាប់ចោទទាំងបួនរូបក្នុងសំណុំរឿង០០២ អៀង ធីរិទ្ធ គឺជាបុគ្គលតែម្នាក់ ដែលទទួលបានការដោះលែងឲ្យនៅក្រៅឃុំ បន្ទាប់ពីមានការចោទប្រកាន់នៅចំពោះមុខសាលាក្តីខ្មែរក្រហម ។ ដំណឹងពីសម្បទាមិនគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ដែលបណ្តាលឲ្យមានការដោះលែង អៀង ធីរិទ្ធ គឺជាស្ថានភាពមួយដែលពិបាកទទួលយកសម្រាប់ប្រជាជនខ្មែរដែលជាជនរងគ្រោះនៃរបបខ្មែរក្រហមម្តងរួចទៅហើយ ។ មកដល់ពេលនេះ មានអតីតជនជាប់ចោទពីររូបនៅក្នុងសំណុំរឿង០០២ បានទទួលមរណភាព គឺ អៀង សារី (ស្លាប់នៅឆ្នាំ២០១៣) និង អៀង ធីរិទ្ធ ដែលត្រូវជាប្រពន្ធរបស់ អៀង សារី ហើយក៏ជាបុគ្គលដ៏មានឥទ្ធិពល និងមានអំណាចនៅទូទាំងប្រទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការស្លាប់របស់ អៀង ធីរិទ្ធ នៅពេលនេះបានធ្វើឲ្យការចោទប្រកាន់របស់តុលាការប្រឆាំងនឹង អៀង ធីរិទ្ធ ត្រូវបិទបញ្ចប់ទាំងស្រុង ។ ការបិទបញ្ចប់នេះក៏ពុំមានផលប៉ះពាល់ចំពោះជនជាប់ចោទទាំងពីររូបដែលនៅមានជីវិតនោះឡើយ ដោយមូលហេតុថា សំណុំរឿងរបស់ អៀង ធីរិទ្ធ ត្រូវបានបំបែកចេញតាំងពីឆ្នាំ២០១១មកម្ល៉េះ ។

អៀង ធីរិទ្ធ បានស្លាប់ស្របពេលដែលអង្គជំនុំជម្រះសាលាដំបូងកំពុងតែពិភាក្សាសួរដេញដោលលើសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការសាងសង់ទំនប់ត្រពាំងថ្ម ដែលស្ថិតក្នុងភូមិភាគពាយ័ព្យ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អៀង ធីរិទ្ធ ត្រូវបានបញ្ជូនឲ្យទៅស៊ើបអង្កេត និងរាយការណ៍ពីបញ្ហាសុខាភិបាលមួយចំនួនក្នុងភូមិភាគនេះ ហើយទំនងជាបានដឹងថា ប្រជាជនកម្ពុជាជាច្រើននាក់កំពុងតែអត់ឃ្លានក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ ការពិត យុត្តិធម៌ ការផ្សះផ្សា ការទទួលខុសត្រូវ និង ប្រវត្តិសាស្ត្រត្រូវបាត់បង់បន្ទាប់ពីមរណភាពនេះ បើទោះបីជាមានការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរហូតដល់ពេលស្លាប់ក៏ដោយ ។ **ឌី សុជាតា**

# សវនាការស្ដីពីការស្ដាប់សេចក្ដីថ្លែងរៀបរាប់ទុក្ខសោក ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវិដា

កាលខែមិថុនា ឆ្នាំ២០១៥ អង្គជំនុំជម្រះសាលាដំបូង បានបើកសវនាការ ដើម្បីស្ដាប់ការថ្លែងរៀបរាប់ទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវិដា ដែលបានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវិដា កើតនៅឆ្នាំ១៩៦៤ មានទីកន្លែងកំណើតនៅសង្កាត់លេខ៥ ក្រុងភ្នំពេញ និងទីលំនៅបច្ចុប្បន្ននៅសង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ ឪពុកឈ្មោះ លី ជីវសៀង ម្ដាយឈ្មោះ ម៉ៅ គីមយ៉ាន ស្វាមីឈ្មោះ ម៉ុក ប្រឌិតវ៉ាសនា មានកូនចំនួនពីរនាក់ ។

នៅមុនចាប់ផ្ដើមការសាកសួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី ប្រធានអង្គជំនុំជម្រះសាលាដំបូង បានប្រាប់ពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការថ្លែងរៀបរាប់ពីទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្ម ដែលខ្លួនធ្លាប់បានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។


សៀង សុវិដា (រូបថត ៖ អ.វ.ត.ក)

ដើមបណ្ដឹងរដ្ឋប្បវេណីបានរៀបរាប់ អំពីដំណើរនៃការជម្លៀសរបស់ក្រុមគ្រួសារខ្លួន និងស្ថានភាពរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជូនសហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ។ បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដើមបណ្ដឹងរដ្ឋប្បវេណី និងឪពុកម្ដាយ បងប្អូន បានជម្លៀសពីចេញពីក្រុងភ្នំពេញមកកាន់ខេត្តកណ្ដាល និងបន្តដំណើរមកខេត្តកំពង់ចាម ។ នៅខេត្តកំពង់ចាម ដើមបណ្ដឹងរដ្ឋប្បវេណី និងគ្រួសារ ត្រូវបានខ្មែរក្រហមបង្ខំឲ្យធ្វើការនៅភ្លឺស្រែ និងទទួលបានអាហារមិនគ្រប់គ្រាន់ ។ រំលងបាន ៦ខែ ដើមបណ្ដឹងរដ្ឋប្បវេណី ឪពុកម្ដាយ និងបងប្អូន ត្រូវខ្មែរក្រហមបន្តជម្លៀសមកកាន់ភូមិឬស្សីកែវលើ សង្កាត់ឬស្សីកែវ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។

នៅខេត្តក្រចេះ ខ្មែរក្រហមចាត់ឲ្យដើមបណ្ដឹងរដ្ឋប្បវេណីនៅកងកុមារ បន្ទាប់មកចាត់ឲ្យចូលកងចល័តជាមួយបងស្រីដើមបណ្ដឹងរដ្ឋប្បវេណី ។ បងស្រីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី មានអាយុត្រឹមតែ១៥ ឬ១៦ឆ្នាំ ត្រូវខ្មែរក្រហមបង្ខំឲ្យរៀបការ ។ បន្ទាប់ពីបងស្រីរៀបការ ដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានអាយុ១១ឆ្នាំ បានស្ម័គ្រចិត្តធ្វើដំណើរជាមួយប្រជាជនផ្សេងទៀតនៅក្នុងភូមិ មកធ្វើការនៅទំនប់១មករា រយៈពេលបីខែ ព្រោះដើមបណ្ដឹងរដ្ឋប្បវេណីចង់ការពារក្រុមគ្រួសាររបស់ខ្លួនពីការធ្វើបាបពីសំណាក់ពួកខ្មែរក្រហម ។ ផ្ទុយទៅវិញ បន្ទាប់ពីដើមបណ្ដឹងរដ្ឋប្បវេណីត្រឡប់មកវិញ បានដឹងថាឪពុកម្ដាយ និងបងស្រី ត្រូវខ្មែរក្រហមធ្វើបាប និងបង្អត់អាហារ ។

ដើមបណ្ដឹងរដ្ឋប្បវេណី បានរៀបរាប់ពីស្ថានភាពការងារនៅទំនប់១មករាថា ពេលដើមបណ្ដឹងរដ្ឋប្បវេណីធ្វើដំណើរទៅដល់ការដ្ឋាន ខ្មែរក្រហមចាត់ចែងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកភូមិដទៃទៀតសម្រាកនៅភូមិប្រជាជន នៅជិតវត្តបារាយណ៍ជាន់ដែក ចម្ងាយ

ពីទំនប់១មករា ប្រហែល១គីឡូម៉ែត្រ និងក្រោយមកប្តូរទៅទីតាំងថ្មី ដែលមានចម្ងាយពីទំនប់ប្រហែល៥គីឡូម៉ែត្រ ។ ការងារដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវធ្វើនៅទំនប់១មករា គឺរែកដីពីប្រឡាយយកទៅចាក់នៅទំនប់ ឯបុរសៗដែលមានកម្លាំងជាអ្នកកាប់ដី ។ ដើមបណ្តឹងរដ្ឋប្បវេណីតែងតែត្រូវអ្នកធ្វើការនៅការដ្ឋានទំនប់ ចាត់ឲ្យទៅដងទឹកសម្រាប់បរិភោគនៅរោងបាយ ព្រោះដើមបណ្តឹងរដ្ឋប្បវេណីមានវ័យក្មេងជាងគេ ។

ប្រជាជននៅស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ដែលបានបញ្ជូនមកធ្វើការនៅទំនប់១មករា ត្រូវបានខ្មែរក្រហមបែងចែកជាកង ហើយកងចែកជាក្រុម ដោយមានប្រជាជនមូលដ្ឋានជាអ្នកគ្រប់គ្រង ។ នៅក្នុងកងចល័តរបស់ដើមបណ្តឹងរដ្ឋប្បវេណី មានប្រជាជនអាយុចន្លោះពី១០ឆ្នាំ ដល់៣០ឆ្នាំ ហើយដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកដែលមានអាយុតិចជាងគេ ដូច្នេះខ្មែរក្រហមមិនសូវបង្ខំឲ្យដើមបណ្តឹងរដ្ឋប្បវេណីរែកដីច្រើនទេ ។

ចំពោះពេលវេលានៃការធ្វើការងារនៅទំនប់១មករា ដើមបណ្តឹងរដ្ឋប្បវេណី និងប្រជាជននៅកងជាមួយគ្នា ត្រូវក្រោកពីព្រលឹម ប្រហែលម៉ោង៤កន្លះ ឬម៉ោង៥ព្រឹក ដើម្បីធ្វើដំណើរទៅការដ្ឋាន ។ នៅពេលព្រឹក ដើមបណ្តឹងរដ្ឋប្បវេណីមិនទទួលបានអាហារបរិភោគ ដល់ពេលថ្ងៃត្រង់ទើប ខ្មែរក្រហមឲ្យសម្រាកបរិភោគអាហារ ហើយបន្តការងាររហូតដល់ល្ងាច ទើបសម្រាកបរិភោគអាហារ នៅរោងបាយជិតកន្លែងការដ្ឋានទំនប់ និងបន្តការងារនៅពេលយប់រហូតដល់ម៉ោង៩ ឬម៉ោង១០យប់ ទើបសម្រាក ។

ទាក់ទងនឹងស្ថានភាពសុខភាព ក្រៅពីដើមបណ្តឹងរដ្ឋប្បវេណីដែលធ្លាប់ឈឺគ្រុនក្តៅ ហើយដួលសន្លប់ម្តងនៅការដ្ឋាន មានប្រជាជនផ្សេងទៀត ធ្លាក់ខ្លួនឈឺជាបន្តបន្ទាប់ ព្រោះតែការបរិភោគអាហារមិនគ្រប់គ្រាន់ និងធ្វើការងារធ្ងន់ ។ បើមានអ្នកជំងឺឈឺធ្ងន់ មេកងនឹងបញ្ជូនឲ្យសម្រាកនៅរោងជិតការដ្ឋានទំនប់ ដែលមានពេទ្យប្រចាំការ ហើយបើធ្ងន់ជាងនេះ អ្នកជំងឺនឹងត្រូវបញ្ជូនទៅពេទ្យស្រុក ស្ថិតនៅក្នុងវត្តចំប៉ក់ ។

ដើមបណ្តឹងរដ្ឋប្បវេណីធ្លាប់បានចូលរួមការប្រជុំតាមក្រុម តាមកង តាមស្រុក និងមីទ្ទីង ។ ការប្រជុំតាមក្រុមត្រូវបានធ្វើឡើងជាញឹកញាប់ ដើម្បីជំរុញឲ្យប្រជាជនខិតខំធ្វើការងារឲ្យបានឆាប់រហ័ស កុំឲ្យទម្រន់ ឬខ្ជិលច្រអូស និងណែនាំឲ្យធ្វើស្រែឲ្យបាន៣តោនក្នុង១ហិកតា ។ ការធ្វើមីទ្ទីង ដែលជាការប្រជុំធំ ដើមបណ្តឹងរដ្ឋប្បវេណីធ្លាប់បានចូលរួមម្តង ដោយគោលបំណងនៃការប្រជុំ គឺណែនាំឲ្យខិតខំបំពេញការងារដូចការប្រជុំតាមកង តាមក្រុម ។

ដើមបណ្តឹងរដ្ឋប្បវេណីបានឲ្យដឹងថា នៅការដ្ឋានទំនប់ និងតាមភូមិ មានកងឈ្លបស្ពាយកាំភ្លើងវែង ចាំតាមដាន និងសង្កេតមើលការងាររបស់ប្រជាជន ជាពិសេសប្រជាជន ១៧មេសា ។

បញ្ហាកង្វះអនាម័យប្រចាំថ្ងៃ តែងកើតមានឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចជាបញ្ហាទឹកសម្រាប់បរិភោគ និងសម្អាតខ្លួនប្រាណ ការបន្ទោរបង់ និងសម្លៀកបំពាក់តែមួយកំប្លេរសម្រាប់ស្លៀកពាក់ ។

ដើមបណ្តឹងរដ្ឋប្បវេណីបានជម្រាបជូនសហព្រះរាជអាជ្ញាជាតិថា ឪពុករបស់ដើមបណ្តឹងរដ្ឋប្បវេណីជាអតីតទាហាននៅសម័យខ្មែរឥស្សរៈ ហើយគាត់បានព្យាយាមលាក់ប្រវត្តិរបស់ខ្លួនពេលដែលជម្លៀសចេញពីក្រុងភ្នំពេញ ព្រោះគាត់បារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន និងគ្រួសារ ។

នៅភូមិដែលដើមបណ្តឹងរដ្ឋប្បវេណីរស់នៅ មានជនជាតិចាម ដែលបានជម្លៀសពីទីតាំងផ្សេងមករស់នៅ ហើយលក្ខខណ្ឌការងារ និងរបបអាហារដែលពួកគេទទួលបាន គឺដូចគ្នានឹងប្រជាជនខ្មែរទូទៅ ។

ដើមបណ្តឹងរដ្ឋប្បវេណី មានការសោកសង្រេង និងឈឺចាប់ ព្រោះម្តាយឪពុក រួមនឹងបងស្រី ដែលមានផ្ទៃពោះ៤ខែ និងប្អូនស្រី ត្រូវខ្មែរក្រហមនាំយកទៅសម្លាប់នៅជើងភ្នំសុពណ៌កាឡី នៅឆ្នាំ១៩៧៧ ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានឃើញមានវត្តអារាម និងការគោរពប្រតិបត្តិសាសនា ទាំងនៅការដ្ឋានទំនប់១មករា និងភូមិដែលដើមបណ្តឹងរដ្ឋប្បវេណីស្នាក់នៅ ។

ចៅក្រមអន្តរជាតិបានសាកសួរចំពោះដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីការបាត់ខ្លួនប្រជាជននៅការដ្ឋានទំនប់១មករា ។ ដើមបណ្តឹងរដ្ឋប្បវេណីបានប្រាប់ថា មានការបាត់ខ្លួនអ្នកដែលធ្វើការនៅទំនប់១ មករា ភាគច្រើនជាប្រជាជន១៧មេសា និងជាបុរសៗ ។ ពួកគាត់ទាំងនោះ ត្រូវខ្មែរក្រហមចាត់ឲ្យទៅធ្វើការនៅកន្លែងផ្សេង

ហើយមិនដែលឃើញត្រឡប់មកវិញ ។

ដើមបណ្ដឹងរដ្ឋប្បវេណីបានឆ្លើយប្រាប់សហមេធាវីការពារក្ដីជនជាប់ចោទថា នៅការដ្ឋានទំនប់១មករា ប្រជាជនទាំងអស់ មិនដែលមានឱកាសបានសម្រាកយូរទេ ត្រូវសម្រុកធ្វើការងារទាំងពេលថ្ងៃ និងពេលយប់ ។ នៅរៀងរាល់១សប្ដាហ៍ម្ដង មានខាងក្រុមសេដ្ឋកិច្ច ដឹកស្បៀងពីភូមិមករោងបាយនៅការដ្ឋានទំនប់ ។ ចំពោះការព្យាបាលជំងឺ ថ្វីបើមានពេទ្យនៅប្រចាំការទាំងនៅការដ្ឋាន និងនៅស្រុក តែជាពេទ្យដែលគ្មានជំនាញ និងមិនបានរៀនសូត្រវិជ្ជាពេទ្យចេះដឹងច្បាស់លាស់ ។

នៅមុនបញ្ចប់ការផ្ដល់សក្ខីកម្ម ដើមបណ្ដឹងរដ្ឋប្បវេណីបានសាកសួរសំណួរ ទៅកាន់ជនជាប់ចោទអំពីមូលហេតុដែលពួកគាត់ធ្វើបាបប្រជាជនខ្មែរ ជាពិសេសគឺប្រជាជន១៧មេសា និងការទទួលខុសត្រូវរបស់ជនជាប់ចោទទាំងពីរ ក្នុងឋានៈពួកគាត់ជាអ្នកដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ ។ ដើមបណ្ដឹងរដ្ឋប្បវេណីក៏បានថ្លែងរៀបរាប់ពីទុក្ខសោកវេទនា ដែលបានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យថា "ខ្ញុំមិនចង់ឲ្យខាតពេលទេ ពីព្រោះអីការទុក្ខសោករូបខ្ញុំ ក៏ដូចប្រជាជនគ្រប់គ្នា ក្នុងរបបពាន់ឆ្នាំហ្នឹងទាំងអស់គ្នាដែរ ។ បើនិយាយទឹកភ្នែករហូត ចង់ស្ទះហើយខ្ញុំនេះ ញ័រសាច់ទ្រើកហើយ ។ ខ្ញុំអត់ចង់និយាយអីច្រើនទេ ចង់ថាទុក្ខសោកដូចគ្នាទាំងអស់ គឺខ្លាំងណាស់ មកលើគ្រួសារខ្ញុំៗ ដូចបានរៀបរាប់អីចឹង គឺខ្លាំង ។ ហើយខ្ញុំៗចង់និយាយ--នៅពេលត្រឡប់--ខ្ញុំសូមនិយាយកាត់មកដល់នេះហ្មង ពេលត្រឡប់ពីភ្នំពេញមកវិញ ទុក្ខសោកទាំងឡាយមកលើរូបខ្ញុំគឺធំធេងណាស់ ។ ធំធេងរកអ្វីមិនបាន ហើយកូនតែងតែសួរថា ហេតុអីក៏ម្ដាយមិនដែលឃើញសប្បាយចិត្តសោះ? ខ្ញុំប្រាប់គាត់កូនថាម្ដាយមិនដឹងសប្បាយយ៉ាងម៉េចទេ បើម្ដាយបាត់បង់អ្នកជាទីស្រឡាញ់ អ្នកមានគុណអស់ហើយ ម្ដាយ--ខ្ញុំនិយាយ--ខ្ញុំចង់--អត់ចង់បន្តទៀតទេ ខ្ញុំចេះរំឭកឡើង ខ្ញុំចេះតែវិល ចង់តែដួល ។ ខ្ញុំៗគិតថា ប្រវត្តិវាជូរចត់ណាស់ គ្រាន់តែថារឿងកំសត់ រឿងអត់ហូប រឿងគេធ្វើបាប ទារុណកម្មមកលើវាយដំក៏អត់ដែលធ្វើបាបក្នុងតាមផ្លូវចិត្ត និងផ្លូវកាយបង្អត់អាហារ ជាពិសេសឈឺចាប់នឹងបងនិងម្ដាយហ្នឹង ។ អីចឹងខ្ញុំសូមនេះប៉ុណ្ណឹងចុះ ខ្ញុំដូចជាបន្តទៅទៀត ខ្ញុំអត់សូវស្រួលក្នុងខ្លួនម៉េចទេ ។

សវនាការក្នុងការស្ដាប់សេចក្ដីថ្លែងរៀបរាប់ទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់ ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវិដា ដែលធ្លាប់បានទទួលរងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានបញ្ចប់នៅរសៀលថ្ងៃដដែល ។ **ឌិន ដួងច័ន្ទរ៉ា កែវលក្ខិនារីរតន៍**



សៀង សុវិដា និង មេធាវី ផ្ដល់សក្ខីកម្មនៅមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (រូបថត ៖ អ.វ.ត.ក)

# ការជំរុញទឹកចិត្តពីអ្នកទោសខ្មែរក្រហម


ដុំ ម៉ី នៅពេលបច្ចុប្បន្ន

អ្នកដែលបានរស់រានមានជីវិតពីរបបខ្មែរក្រហម បានទទួលរងនូវជីវភាពឈឺចាប់ ក៏ដូចជាការលងបន្លាចពីអតីតកាលដ៏សែនជូរចត់នៃរបបព្រៃផ្សៃនេះ ដែលមានរយៈពេលប្រមាណជាង៣០ឆ្នាំមកហើយ ។ មនុស្សមួយចំនួនពុំចង់លើកឡើងពីបទពិសោធឈឺចាប់នេះទេ អ្នកទាំងនោះក៏ពុំមានភាពក្លាហានទៅកាន់ទីតាំងនៃភាពសោកសង្រេងរបស់ខ្លួនដែរ ។ ប៉ុន្តែ ចំពោះ ដុំ ម៉ី គឺមិនដូច្នោះទេ ។ ក្នុងនាមជាអ្នកស្រាវជ្រាវមួយរូបរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា នាងខ្ញុំមានឱកាសក្នុងការសម្ភាសជាមួយអ្នករស់រាននៃមន្ទីរស-២១ ម្នាក់ក្នុងចំណោមអ្នករស់រានពីររូប ។ លោកតែងតែមកកាន់ទីតាំងដែលជាមន្ទីរឃុំឃាំង និងជាទីកន្លែងដែលលោកទទួលរងទារុណកម្មក្នុងអំឡុងពេលជាប់ឃុំឃាំង ។ នៅក្នុងបទសម្ភាសនេះ ដុំ ម៉ី បានលើកឡើងនូវប្រយោគមួយដែលស្រដៀងទៅនឹងអ្វីដែលបានលើកឡើងក្នុងសៀវភៅរបស់គាត់ថា «ខ្ញុំមកកាន់ទីនេះរៀងរាល់ថ្ងៃ ដើម្បីប្រាប់ពីការពិតរបស់គុកទួលស្លែង ទៅកាន់ពិភពលោក ដូចនេះឧក្រិដ្ឋកម្មនឹងមិនកើតឡើងជាថ្មីនៅផ្នែកណាមួយនៃពិភពលោកនេះទៀតឡើយ» ។ ជួបដោយផ្ទាល់ និងសង្កេតឃើញពីទឹកមុខរបស់លោក បានធ្វើឲ្យនាងខ្ញុំកាន់តែចង់ដឹងពីប្រវត្តិរឿងរ៉ាវរបស់គាត់ ។ ឥទ្ធិពលនៃការស្តាប់នូវសម្តីរបស់គាត់ដោយផ្ទាល់ មានភាពជ្រាលជ្រៅជាងអំនាននូវពាក្យដែលគាត់បានសសេរនៅក្នុងសៀវភៅរបស់គាត់ទៅទៀត ។

បើទោះជាស្ថិតក្នុងវ័យ៨០ឆ្នាំ ក៏ពិតមែន ដុំ ម៉ី នៅតែបន្តទៅកាន់សារមន្ទីរប្រល័យពូជសាសន៍ ទួលស្លែងជារៀងរាល់ថ្ងៃ ដើម្បីចែករំលែកនូវបទពិសោធអតីតកាលសោកសៅរបស់គាត់ដល់អ្នកទស្សនា ។ គាត់បានលើកឡើងថា «ខ្ញុំយំរាល់យប់ និងរាល់ដង នៅពេលលើកឡើងពីរបបខ្មែរក្រហម វាបានរំឭកខ្ញុំពីប្រពន្ធ និងកូនរបស់ខ្ញុំ» ។ ចំពោះដុំ ម៉ី ការរំឭកពីរបបខ្មែរក្រហម គឺប្រៀបបានទៅនឹងការកាត់សាច់របស់គាត់យ៉ាងដូច្នោះដែរ ។ ទោះបីជាយ៉ាងនេះក្តី ដើម្បីអប់រំដល់មនុស្សទូទៅ គាត់បានសម្រេចចិត្ត ប្រឈមទៅនឹងការឈឺចាប់នេះរៀងរាល់ថ្ងៃ ។ សេចក្តីមោះមុតរបស់គាត់ បានបង្រៀនយើងឲ្យជម្នះនូវរាល់ឧបសគ្គដែលយើងជួបប្រទះក្នុងជីវិត បើទោះជាវាមានការឈឺចាប់ក៏ដោយ យើងមិនគួរមានការភ័យខ្លាច និងរួញរាឡើយ ។ យើងគប្បីធ្វើជាម្ចាស់លើបទពិសោធទាំងអស់នេះ និងយកឈ្នះលើវា ។ យើងនឹងទទួលបាននូវជ័យជម្នះប្រសិនបើយើងមានការប្តេជ្ញា ។ អាកប្បកិរិយារបស់ ដុំ ម៉ី សបញ្ជាក់ថា យើងពុំអាចធ្វើការផ្លាស់ប្តូរនូវអតីតកាលរបស់យើងបានទេ ក៏ប៉ុន្តែ គាត់បានបង្ហាញខ្ញុំពីវិធីសាស្ត្រ ក្នុងការក្លាយខ្លួនជាបុគ្គលមួយរូបដែលមានភាពរឹងប៉ឹងទាំងផ្នែកស្មារតី និងកម្លាំងកាយ ។ គាត់ជាបុគ្គល មួយរូបដែលរឹងប៉ឹង ដែលមិនអនុញ្ញាតឲ្យអតីតកាលគ្រប់គ្រងលើខ្លួន ។ ខ្ញុំយល់ថា អតីតកាលរបស់គាត់ពុំបានលងបន្លាចគាត់នោះទេ ផ្ទុយទៅវិញ គឺធ្វើឲ្យគាត់កាន់តែរឹងមាំថែមទៀត ។ លើសពីនេះទៅទៀត គាត់បានធ្វើការតទល់ជាមួយ ឌុច និងការស្វែងរកនូវយុត្តិធម៌ ជាជាងការភ័យខ្លាចនូវប្រធានគុកស-២១ រូបនេះ ។

ដុំ ម៉ី បានប្រើអតីតកាលរបស់ខ្លួន ក្នុងការជួយសង្គ្រោះនូវជនរងគ្រោះដទៃទៀត ក៏ដូចជាជួយដល់ជនងាយរងគ្រោះដទៃទៀត ។ តាមរយៈការលក់សៀវភៅរបស់ខ្លួន គាត់អាចទទួលបានប្រាក់កម្រៃសម្រាប់ទ្រទ្រង់ជីវភាពរបស់ខ្លួនសមរម្យ ។ យ៉ាងណាមិញ គាត់ពុំប្រើប្រាស់ចំណូលនោះដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួននោះទេ ។ គាត់បានបង្កើតនូវអង្គការមួយដែលមានឈ្មោះថា «សមាគមជនរងគ្រោះនៃរបបខ្មែរក្រហម» ។ លើសពីនេះ គាត់បានផ្តល់ជាថវិកាដើម្បីជួយដល់អ្នកដែលរស់រាន និងកុមារកំព្រា ។ គាត់បានមានប្រសាសន៍ថា «យើងជាខ្មែរ យើងត្រូវតែជួយគ្នាទៅ

វិញទៅមក» ។ ភាពអង់អាច និងភាពសប្បុរសរបស់គាត់ បានបង្ហាញប្រាប់ខ្ញុំថា យើងគួរធ្វើអ្វីដែលយើងអាចធ្វើបានជួយដល់អ្នកដទៃ ។

ចំពោះទស្សនៈរបស់ខ្លួន ជុំ ម៉ី បានផ្តល់តម្លៃលើជីវិតជាខ្លាំង ។ ក្នុងអំឡុងរបបខ្មែរក្រហម គាត់បានទទួលរងនូវការធ្វើទុក្ខបុកម្នេញជាច្រើន ដូចជា ការឆក់ខ្សែភ្លើង ការដកក្រចក និងការវាយដំយ៉ាងព្រៃផ្សៃ ។ មនុស្សគ្រប់គ្នា មិនសុទ្ធតែអាចទ្រាំទ្រនូវទារុណកម្មនេះបាននោះទេ ។ មនុស្សមួយចំនួននឹងធ្វើអត្តឃាតដើម្បីបញ្ចប់នូវភាពសោកសង្រេងនេះ ។ ចំណែក ជុំ ម៉ី គឺមិនដូច្នោះទេ ។ គាត់បានខិតខំប្រឹងប្រែងអស់ពីលទ្ធភាពដើម្បីឲ្យបានរស់រានមានជីវិត និងប្រាប់នូវរឿងរ៉ាវដែលគាត់បានឆ្លងកាត់ដល់អ្នកដទៃ ។ ទង្វើទាំងនេះ បានផ្តល់សារសំខាន់ដល់រូបខ្ញុំ គឺយើងមិនគួរបញ្ចប់ជីវិតរបស់ខ្លួនដោយងាយទេ ហើយបញ្ហាលំបាកដែលយើងជួបប្រទះគង់តែនឹងកន្លងផុត ។

បើទោះជាមានការឈឺចាប់ក្នុងការចងចាំនូវអតីតកាលដ៏ជូរចត់ ជុំ ម៉ី នៅតែបន្តឆ្ពោះទៅមុខយ៉ាងអង់អាច ។ ទោះបីជា គាត់មានភាពពិបាកក្នុងការបញ្ឈរលើមួយចំហៀងខ្លួនរបស់គាត់ក្តី គាត់នៅតែបន្ត និយាយរឿងរ៉ាវប្រាប់ដល់ក្រុមទេសចរនៅទួលស្លែងពីព្រលឹមទល់ព្រលប់រៀងរាល់ថ្ងៃដោយពុំខ្លាចហត់នឿយ ។ បន្ទាប់ពីកិច្ចសម្ភាស និងគំរូល្អពីគាត់ ខ្ញុំត្រូវបានលើកទឹកចិត្តបន្ថែមក្នុងការខិតខំប្រឹងប្រែងដើម្បីរៀនសូត្របន្ថែមពីរបបខ្មែរក្រហម ។ ខ្ញុំដឹងថា វាជាដំណើរដ៏វែងឆ្ងាយមួយ ប៉ុន្តែ ជុំ ម៉ី ផ្ទាល់ក៏បានធ្វើដំណើរដ៏វែងឆ្ងាយផងដែរក្នុងការជួយដល់ប្រជាជនកម្ពុជា ។ ដោយមានគាត់ជាគំរូ ខ្ញុំមានក្តីសង្ឃឹមពោរពេញដោយការប្តេជ្ញាចិត្ត និងជំហរដ៏រឹងមាំ ។

**សុភ័ក្រ្ត ភាណា**



រូបទីមួយ រាប់ពីឆ្វេង ជុំ ម៉ី រួមជាមួយអ្នកទោស៦នាក់ទៀត ដែលរួចរស់ជីវិតពីគុកទួលស្លែង ក្រោយពេលរបបខ្មែរក្រហមដួលរលំ ឆ្នាំ១៩៧៩

# រសាត់តាមខ្យល់

**(តពីលេខមុន)**



ប៉ុក ប៉ុនសូម៉ាដ

នេះជាលើកដំបូងបង្អស់ហើយ ដែលខ្ញុំបានឃើញកងទ័ពប្រជាជនបដិវត្តន៍ដ៏អង់អាចក្លាហាន តែសម្រាប់រូបខ្ញុំមើលទៅដូចជារខេករខាក មិនខុសពីអ្នកសុំទានឡើយ ។

ពូជនបានកេះខ្ញុំឲ្យមើលពួកមិត្តនារីកងទ័ពបដិវត្តន៍ដែលកំពុងដើរជាជួរ ខ្លះរែកគ្រាប់ ខ្លះទៀតនៅ នឹងស្មាមានលីកាំភ្លើង B៤០ម្នាក់មួយដើមយ៉ាងស្វាហាប់ ពួកមិត្តនារីកងទ័ពកាត់សក់យ៉ាងខ្លីត្រឹមកញ្ចឹងកដូចៗគ្នា មើលទៅសឹងតែមិនស្គាល់ថា ជាបុរស ឬស្ត្រីឡើយ ។

ប្រមាណជិតពីរម៉ោងក្រោយមក មុនពេលថ្ងៃត្រង់បន្តិច កងទ័ពមិត្តរំដោះបានចូលកាន់កាប់ទីក្រុង ភ្នំពេញជាស្ថាពរ ... ម្នាក់ៗសែនត្រេកអរ...តែប៉ុណ្ណេះសង្គ្រាមចប់ហើយ....ចាប់ពីថ្ងៃនេះតទៅស្រុក យើងបានសុខសាន្តត្រាណវិញហើយ... ។

នៅចំពីមុខខ្ញុំ ស្រាប់តែមានយុវជនម្នាក់ក្នុងសម្លៀកបំពាក់ជាកូនសិស្ស ជិះម៉ូតូហុងដាមួយគ្រឿង ដោយមានផ្ទុកសៀវភៅសិក្សាមួយចំនួននៅពីក្រោយផង បានបើកចេញពីផ្លូវលំតូចមួយរួចបត់ឡើងថ្នល់ជាតិ បើកតម្រង់ឆ្ពោះទៅក្បាលថ្នល់ ឃើញដូច្នេះមិត្តកងទ័ពរំដោះម្នាក់ដែលកំពុងតែឈរនៅទីងកណ្ដាលថ្នល់បានបាញ់កាំភ្លើងដៃជាច្រើនគ្រាប់ឡើងលើបណ្ដើរ ហើយស្រែកបញ្ជាឲ្យម៉ូតូឈប់បណ្ដើរស្ថិតក្នុងសភាពយ៉ាងស្ងន់ស្ងោ យុវជនអ្នកបើកម៉ូតូបានជ្រុលល្បឿនបន្តិចទៅមុខទៀត រំពេចនោះមិត្តរំដោះ យើងបានលើកកាំភ្លើងឡើងបាញ់តម្រង់ស្រោចពីលើអ្នកបើកម៉ូតូយ៉ាងកំរោលយុវជនម្ចាស់ម៉ូតូត្រូវ គ្រាប់ប្រកាច់ស្លាប់ភ្លាមក្នុងថ្លុកឈាម ម៉ូតូខ្ទាតទៅលើចិញ្ចើមថ្នល់ម្ខាងទៀត ហើយឆេះក្នុងអណ្ដាតភ្លើងយ៉ាងសន្ធោរសន្ធៅ សៀវភៅសិក្សាជ្រុះរាយប៉ាយប៉ើងពាសពេញថ្នល់ ។

ដោយបានឃើញភាពសាហាវ និងយ៉ាងអមនុស្សធម៌ផ្ទាល់នឹងភ្នែកបែបនេះ ប្រជាជនទាំងអស់ ដែលមុននេះបន្តិចទើបតែបានសប្បាយរីករាយ អបអរសាទរនឹងជ័យជម្នះរបស់ពួកកងទ័ពខ្មែរក្រហមនោះម្នាក់ៗប្រែជាភ័យខ្លាចតក់ស្លុតយ៉ាងខ្លាំង ហើយបំបែកគ្នាដោយស្ងប់ស្ងៀមត្រឡប់ទៅកាន់លំនៅដ្ឋានវិញរៀងៗខ្លួន ។

នៅជាប់នឹងរបងខាងកើតវត្ត មានចេតិយធំប្រណិតមួយដែលមានរចនាក្បូរក្បាច់ ដូចប្រាសាទអង្គរល្អលើសចេតិយនានាគឺជាចេតិយរបស់មាតារបស់លោក អ៊ីង ក្រពុំផ្កា បានអញ្ជើញមកពីស្រុកបារាំង រៀបចំកម្មវិធីបុណ្យបូជាសពមាតាលោកយ៉ាងរួសរាន់នៅទីងបរិវេណវត្ត ដោយមានបញ្ចេះម៉ាស៊ីនភ្លើងភ្លឺព្រោងព្រាត ហើយយប់នោះមានទាំងបាញ់កាំជ្រួចជាច្រើនគ្រាប់លាន់ទ្រហឹងពេញវត្ត ពុបន្ទុរគ្នានឹងសូរកាំភ្លើងធំតូចដែលពេលនោះកងទ័ពរដ្ឋាភិបាលកំពុងតែជាប់ដៃប្រយុទ្ធគ្នាជាមួយពួកខ្មែរក្រហមនៅឯត្រើយម្ខាងទន្លេបាសាក់ ។

ដើរមកដល់ចេតិយមាតាលោក អ៊ីង ក្រពុំផ្កា ខ្ញុំ និងពូជនទុចដំណើរង៉ក់ភ្ញាក់ក្រញាងដោយបានប្រទះភ្នែកឃើញសាកសពទាហានរដ្ឋាភិបាលម្នាក់ដេកស្លាប់ក្នុងថ្លុកឈាមនៅទីងគៀនចេតិយដែលជាប់ចំណាងស្លៀកខោខ្លី លែងខ្លួនទទេ ដែលពួកមិត្តរំដោះទើបតែបានសម្លាប់ចោលថ្មីៗ.... ។

ពួកមិត្តរំដោះមួយក្រុមប្រដាប់ដោយអាវុធគ្រប់ដៃ មិត្តម្នាក់មានកាន់ប្រដាប់បំពងសំឡេង កំពុងតែស្រែកប្រកាសបញ្ជាឲ្យប្រជាជនធ្វើដំណើរចាកចេញពីផ្ទះសំបែងរៀងៗខ្លួន ។ ពួកមិត្តបានស្រែកក្តែងៗថា ៖ «យើងខ្ញុំជាកងទ័ពប្រជាជនបដិវត្តន៍ ជាកូនចៅរបស់ប្រជាជន បានមករំដោះបងប្អូនពុកម៉ែ និងជនរួមជាតិឲ្យរួចផុតពីនឹមចក្រពត្តិអាមេរិក និងបរិវារ សូមបងប្អូនពុកម៉ែ កុំភ័យ កុំខ្លាចឲ្យសោះ ពួកយើងមិនធ្វើទុកបុកម្នេញបងប្អូនប្រជាជនទេ ។ ខ្ញុំបានសង្កេតឃើញពួកមិត្តរំដោះមួយក្រុមនេះមានចងក្រណាត់ខ្មៅនៅនឹងកដៃខាងឆ្វេងជាសញ្ញា ខ្លះកំពុងរុញចុងកាណុងកាំភ្លើងតម្រង់ប្រជាជនខ្លះទៀតកំពុងតែបាញ់កាំភ្លើងឡើងលើលាន់យ៉ាងទ្រហឹង ។ ពួកមិត្តដែលមានកាន់ប្រដាប់បំពងសំឡេងបានស្រែកប្រកាសបន្តទៀតថា ៖ «ថ្វីត្បិតតែពួកចក្រពត្តិអាមេរិក និងបរិវារ វាត្រូវបរាជ័យទៅហើយមែន តែពួកវាមិនលះបង់គំនិតប្រតិកិរិយារបស់វាឡើយ ដើម្បីរក្សាសន្តិសុខជូនបងប្អូនប្រជាជនយើងឲ្យបានមួយរយភាគរយ ពេលនេះអង្គការអំពាវនាវហើយ អំពាវនាវទៀត សូមឲ្យបងប្អូនប្រញាប់ប្រញាល់ចាកចេញពីផ្ទះសម្បែងរៀងៗខ្លួន និងចាកចេញពីទីក្រុងភ្លាមៗក្នុងពេលឥឡូវនេះ ព្រោះទីក្រុងភ្នំពេញទាំងមូលអាចនឹងទទួលរងនូវការវាយប្រហារដោយទម្លាក់គ្រាប់បែកពីពួកចក្រពត្តិអាមេរិក....» ។

មានប្រជាជនច្រើនណាស់ហាក់ដូចជាមិនទាន់ចាប់អារម្មណ៍នៅឡើយចំពោះការអំពាវនាវរបស់ពួកមិត្តរំដោះទាំងនោះ អ្នកខ្លះគ្រាន់តែចេញមកស្តាប់រួចហើយនាំគ្នាដើរចូលទៅក្នុងផ្ទះវិញ ។ ឃើញដូច្នេះ ពួកមិត្តបានស្រែកបញ្ជាបង្ខំឲ្យចេញពីផ្ទះកាន់តែខ្លាំង «បងប្អូនត្រូវតែចេញភ្លាមៗ ក្នុងពេលឥឡូវនេះ ប្អូនមិនត្រូវរឹងទទឹងចំពោះបញ្ជារបស់អង្គការឡើយ អង្គការសូមឲ្យបងប្អូនចេញពីទីក្រុងតែបីថ្ងៃទេ បងប្អូនមិនចាំបាច់យកស្អីទៅក៏បានដែរ បងប្អូនចេញតែខ្លួនទទេ អង្គការរង់ចាំទទួលផ្គត់ផ្គង់យ៉ាងកក់ក្តៅបំផុត» ។

នៅនឹងផ្ទះលោក អ៊ឹង រិទ្ធិរុង ប្អូនបង្កើតរបស់លោក អ៊ឹង ក្រពុំផ្កា ខ្ញុំឃើញពួករំដោះមួយក្រុមកំពុងតែនាំគ្នាធាក់ទ្វាររបងចូល ខ្លះកំពុងឈរការពារនៅនឹងផ្លូវខាងមុខផ្ទះក្រោមដើមទឹកដោះគោដ៏ត្រឈុំត្រឈៃ ខ្លះនាំគ្នាឡើងទៅលើផ្ទះ ពួកមិត្តពីរបីនាក់ទៀតកំពុងតែនាំគ្នាធាក់ និងបាញ់ទម្លាយសោទ្វារតាមបន្ទប់ជាន់ផ្ទាល់ដី ។

«ក្នុងផ្ទះមានអ្នកណានៅទេ? ....» ពួកមិត្តស្រែកសួរបណ្តើរយកជើងធាក់ទ្វាគ្រាំងៗបណ្តើរ អ្នកណាហ៊ានរឹងទទឹងនឹងបញ្ជារបស់អង្គការនឹងត្រូវសម្លាប់ចោល» ។

កាលពីប្រមាណមួយខែមុននេះ ដោយសារខ្លាចគ្រាប់ផ្លោងដែលពួកខ្មែរក្រហមផ្លោងចូលក្រុងភ្នំពេញញឹកញាប់ពេក លោករិទ្ធិរុង និងគ្រួសារបានចាកចេញពីផ្ទះនេះទៅនៅភូមិគ្រឹះរបស់លោកមួយទៀតឯទួលគោកដោយចាក់សោផ្ទះទុកចោលយូរៗក្មួយរបស់គាត់មកអើតមើលម្តងៗ ។

ដោយឃើញច្បាស់ថា ពេលនេះអាសន្នមកដល់ហើយ ម្នាក់ៗភ័យស្លន់ភ្នែកនៅនឹងកញ្ចឹងក ទាំងគេ ទាំងអ្នកម៉ែនាំគ្នាប្រញាប់ប្រញាល់រៀបចំវេចខ្ចប់អីវ៉ាន់ អង្ករ ចាន ឆ្នាំង ខោអាវ បន្តិចបន្តួចរួចនាំគ្នាចាកចេញតាមមុខសញ្ញាដែលពួកមិត្តរំដោះបានចង្អុលបង្ហាញដោយចុងកាំភ្លើង អ្នកណាហ៊ានដើរខុស ពីមុខសញ្ញាតែបន្តិច ត្រូវបានពួកមិត្តបាញ់សន្ធាប់គំរាមជិតៗខ្លួន.... ។

អ្នកម៉ែទូលផង យួរផង ខ្ញុំបណ្តើរកង់កញ្ចាស់មួយដឹកអង្ករបានមួយកំណាត់បាវតូច មានទាំងចានឆ្នាំងព្យួររណោងរណោងនៅនឹងដៃកង់ផង រួមដំណើរជាមួយគ្រួសារពូជន ដែលមានម្តាយក្មេកគាត់ មីងណារុងប្រពន្ធគាត់ និងធានីកូនស្រីតែមួយរបស់គាត់ដែលមានអាយុជិតពីរឆ្នាំ ហើយដែលខ្ញុំ និងអ្នកម៉ែបាននិយាយជាមួយគ្នាថាទោះជាទៅដល់ទីណាក៏ដោយគឺយើងនឹងទៅជុំជាមួយគ្នារហូត ។

រសៀលថ្ងៃនោះគឺជាថ្ងៃទី១៧ ខែមេសា ដែលប្រជាជនក្រុងភ្នំពេញប្រមាណជិតពីរលាននាក់ត្រូវបានកងទ័ពខ្មែរក្រហមបណ្តេញចេញពីទីក្រុង ទាំងព្រះសង្ឃក៏ត្រូវចេញពីវត្តអារាម ទាំងអ្នកជំងឺក៏ត្រូវបណ្តេញចេញពីមន្ទីរពេទ្យយ៉ាងទីណាត់ទីណែង ។

តាមបណ្តោយផ្លូវឆ្ពោះទៅកាន់ក្បាលថ្នល់ តាំងពីមុខវិមានរដ្ឋចំការមន ពួកមិត្តកងទ័ពរំដោះឈរបណ្តាក់គ្នាជាជួរ មិនអនុញ្ញាតឲ្យនរណាម្នាក់ដើរចេញពីថ្នល់ជាតិឡើយ ដល់ច្រកតាមផ្លូវលំតូចៗពួកខ្មែរក្រហមឈរយាមដោយដាក់ដៃក្នុងកៃកាំភ្លើងជាស្រេចចាំបាញ់បង្ក្រាបប្រជាជនដែលរឹងទទឹងដើរខុសមុខព្រួញដែលអង្គការបានកំណត់ឲ្យ ។

ខ្ញុំនៅបានប្រទះភ្នែកឃើញសាកសពទាហានរដ្ឋាភិបាលនិងជនស៊ីវិលជាច្រើនបានដេកស្លាប់នៅកណ្តាលវាល និងក្បែរៗ

ចិញ្ចើមថ្នល់ដែលក្នុងចំណោមនោះ មានសាកសពខ្លះដាច់ដៃដាច់ជើង ខ្លះធ្លាយដើមទ្រូង ខ្លះទៀតដាច់ក្បាលបាត់ពីដងខ្លួនតែម្តង និងនៅមានបំណែកសាច់ទាំងដុំៗជាច្រើនដែលខ្ទាតជាប់នឹងជញ្ជាំងផ្ទះខ្លះខ្ទាតព្យួរជាប់នឹងបង្គោលរបង ហើយអគារខ្លះតាមបណ្តោយផ្លូវនៅមានប្រឡាក់ឈាមដោយឈាមក្រហមឆ្អៅ ចោលក្លិនស្អុយឆ្អាប ។

ពេលធ្វើដំណើរបានមកជិតដល់វង្វង់មូលក្បាលថ្នល់ នៅនឹងជ្រុងម្ខាងនៃអគារថ្មមួយល្វែងក្បែរនោះ ខ្ញុំបានឃើញមិត្តកុមារកងទ័ពរំដោះពីរនាក់ស្ពាយកាំភ្លើងស្ទើរតែមិនផុតពីដីកំពុងតែកួចកាំភ្លើង ស្រែកគំរាមបណ្តើរ ដោះយកនាឡិកាពីដៃបុរសម្នាក់បណ្តើរដោយបានស្រែកគំរាមយ៉ាងខ្លាំងៗថា ៖ «មិត្តឯងមិនដឹងទេរបស់ទាំងនេះសុទ្ធតែជារបស់ចក្រពត្តិ បើមិត្តឯងចង់រស់ប្រញាប់ប្រគល់មកឲ្យអង្គការភ្លាម» ។

ខ្ញុំចោលភ្នែកពីចម្ងាយសម្លឹងមើលទៅលើស្ពានច្បារអំពៅឃើញសភាពការណ៍យ៉ាងកកកុញ ដោយប្រជាជនរាប់ម៉ឺនរាប់សែននាក់ដែលកំពុងតែប្រជ្រៀតគ្នាធ្វើដំណើរយ៉ាងយឺតៗបំផុត ។

នៅនឹងក្បាលស្ពានច្បារអំពៅ ដែលជាស្ពានតែមួយគត់បានរួចផុតពីការបំផ្លិចបំផ្លាញខូចខាត ដោយសារសង្គ្រាមប្រាំឆ្នាំនេះមិត្តរំដោះបានដាក់តុធំមួយជាមួយនឹងប្រដាប់បំពងសំឡេងដែលមិត្តបានស្រែកប្រកាសខ្លាំងៗពីគោលនយោបាយសណ្តោសប្រណីនយោបាយលើកលែងទោសរបស់អង្គការចំពោះនាយទាហាននាយទាហានរង និងពលទាហានរដ្ឋាភិបាលទាំងអស់ ទោះជាមានឋានៈបុណ្យស័ក្តិថ្នាក់ណាក៏ដោយឲ្យតែចូលមកសារភាពចំពោះមុខអង្គការនៅពេលនេះ នឹងត្រូវបានអង្គការលើកលែងទោសមានសិទ្ធិដូចប្រជាជនធម្មតា និងត្រូវបានការអនុញ្ញាតឲ្យវិលត្រឡប់ទៅកាន់ភូមិកំណើតរួមរស់ជួបជុំគ្រួសាររៀងៗខ្លួន ។

ក្រោមកំដៅថ្ងៃខែចែត្រស្ទើរបែកលលាដ៍ក្បាលក្នុងចំណោមមនុស្សដ៏ច្រើនកកកុញដូចហ្វូងស្រមោចដែលទម្រាំតែនឹងបានឈានជើងមួយជំហានៗទៅមុខនោះ នៅនឹងការិយាល័យឃោសនារបស់ពួកមិត្តរំដោះ ដោយទឹកមុខញញឹមរីករាយរាក់ទាក់ ពួកមិត្តបានទទួលស្វាគមន៍ពួកទាហានរដ្ឋាភិបាល ដែលបានចូលមកសារភាពបង្ហាញខ្លួនជាបន្តបន្ទាប់ ។

លុះដល់ពេលព្រលប់ឡើង ពួកទាហានរដ្ឋាភិបាលដែលបានចូលមកសារភាពទាំងអស់នោះត្រូវ បានអង្គការយករថយន្តជាច្រើនគ្រឿងមកដឹកចេញពីកន្លែងប្រមូលផ្តុំមួយយកទៅរៀនសូត្រនៅឯក្នុងទីក្រុងភ្នំពេញបាត់អស់ទៅ ។

ល្ងាចនោះពូផន អល់អែក គាត់មិនទាន់ចង់ឆ្លងស្ពានទៅត្រើយម្ខាងច្បារអំពៅទេ ចង់នាំគ្នារកកន្លែងសម្រាកនៅនឹងក្បាលថ្នល់មួយយប់សិន ព្រោះខ្លាចមានធ្លាក់ភ្លៀងនៅពេលយប់ច្បាស់ជាត្រូវហាលភ្លៀងគ្មានកន្លែងជ្រក ម្យ៉ាងមនុស្សច្រើនណាស់កំពុងនាំគ្នាសម្រុកឆ្លងស្ពាន ចាំមើលដល់ពេលស្កាល់មនុស្សបន្តិចចាំឆ្លង ហើយម្យ៉ាងទៀតយើងកុំអាលធ្វើដំណើរទៅណាឆ្ងាយពេក នាំតែពិបាកត្រឡប់ចូលមកភ្នំពេញវិញ ព្រោះពួកមិត្តបានប្រកាសថា ៖ «ចេញតែបីថ្ងៃទេ» ។ មុនពេលដែលគាត់ដើរចេញទៅរកផ្ទះសម្រាប់សម្រាក គាត់បានប្រាប់ឲ្យពួកខ្ញុំចាំគាត់មួយកន្លែងសិន ខ្ញុំឃើញពូផនដើរគេចពីពួកមិត្តដែលកំពុងតែស្រែកបញ្ជាបង្ខំជំរុញឲ្យប្រជាជនធ្វើដំណើរតទៅមុខ ទៀតជាមួយនឹងចុងកាណុងកាំភ្លើងយ៉ាងច្រវាត់ច្រវែង ទោះជាទៅកកស្ទះលើស្ពានហើយ ដែលឈានជើងមួយជំហានៗទៅមុខបានដោយលំបាកយ៉ាងណាក៏ដោយ ។

គេចផុតពីពួកមិត្ត ពូផនដើរតម្រង់ទៅផ្ទះមួយល្វែងយ៉ាងស្ងាត់ស្ងៀមនៅឆ្ងាយបន្តិចពីថ្នល់ជាតិ ។ មួយស្របក់ក្រោយមកខ្ញុំក៏បានដើរទៅតាមពីក្រោយគាត់ ហើយនៅពេលដែលខ្ញុំបានទៅដល់ទីនោះ ស្រាប់តែខ្ញុំឃើញពូផនរត់ត្រឡប់ចេញមកក្រៅវិញយ៉ាងប្រញាប់ប្រញាល់ ។

ខ្ញុំឈរទ្រឹង ដោយអារម្មណ៍យ៉ាងស្លុតរន្ធត់ភ័យខ្លាចនៅក្នុងបន្ទប់ នៅក្នុងបន្ទប់មួយជាប់នឹងជណ្តើរឡើងទៅជាន់ខាងលើខ្ញុំបានឃើញសាកសពមនុស្សបួនប្រាំនាក់ដេកស្លាប់យ៉ាងរណ្តូករណែលឈាមហូរ ស្រោចខ្ទាតប្រឡាក់មួយចំហៀងជញ្ជាំង ដែលត្រូវបានពួកមិត្តរំដោះបាញ់សម្លាប់ចោលទាំងគ្រួសារ ។

ពូផនប្រញាប់ប្រសាន់នាំពួកខ្ញុំបន្តដំណើរទៅមុខទៀត យើងនាំគ្នាតម្រង់ឆ្លងស្ពានទៅត្រើយម្ខាងតែម្តង ។ ទើបតែចេញដំណើរបានបន្តិច ខ្ញុំបានជួបមិត្តរួមថ្នាក់ខ្ញុំម្នាក់ឈ្មោះ គង់ ពន្ទុកពេជ្រ ដែលមានប្អូនស្រីម្នាក់រៀននៅវិទ្យាល័យខ្ញុំដែរ ។ អាពេជ្រ ដើរតែម្នាក់ឯងមានរែកអីវ៉ាន់មួយអម្រែកផង ។

គ្រាន់តែចេញពីផ្ទះបានបន្តិច វាវង្វេងបែកពីឪពុកម្តាយ

និងប្អូនស្រីវា មិនដឹងជាធ្វើដំណើរទៅមុខបាត់ហើយ ឬក៏នៅខាងក្រោយនៅឡើយ ។ ខ្ញុំបានឃាត់ អាពេជ្រ ឲ្យរួមដំណើរជាមួយពួកខ្ញុំ តែវាមិនព្រម ដោយវាសម្រេចចិត្តបន្តដំណើរទៅមុខទៀតក្រែងបានជួបឪពុកម្តាយ និងប្អូនស្រីវា ។

អាពេជ្របានឲ្យស្បែកជើងជិបតុងខ្ញុំពីរគូ កៅស៊ូកង់មួយគូ និងមីដាណាហូតមួយកំណាត់បារ៉ៅ អង្ករអាបី ដែលវាបានចូលទៅដណ្តើមយកជាមួយនឹងគេឯងក្នុងរោងចក្រផលិតមីក្រៀមក្បែរចំការមន មុនពេលដែលវាបានចាកចេញពីខ្ញុំទៅ ។

មុនពេលថ្ងៃលិចបន្តិច ស្រាប់តែមានធ្លាក់ខ្យល់ និងធ្លាក់ភ្លៀងរលឹមប្រុយៗ មិនទាន់ទាំងបានសើមដីផង ភ្លៀងក៏រាំងទៅវិញ ធ្វើឲ្យធាតុអាកាសរិតតែថប់ក្តៅស្អុះស្អាប់លើសដើម ។ ក្នុងចំណោមហ្វូងមនុស្សដែលកំពុងតែប្រជ្រៀតគ្នាធ្វើដំណើរយ៉ាងពពាក់ពពូន ខ្ញុំបានជួបមិត្តរួមថ្នាក់ខ្ញុំម្នាក់ទៀតឈ្មោះ បូនី ដែលក្នុងថ្នាក់ពួកខ្ញុំហៅវាថា ៖ "អាឃ្មី...អាឃ្មី..." ។ វាកំពុងតែដើរម្នាក់ ឯងមានតែខ្លួនមួយ គ្មានអីវ៉ាន់បន្តិចសោះជាប់នឹងខ្លួន ហើយដើរដោយជើងទទេថែមទៀត ។

អាឃ្មីវារស់នៅជាមួយឪពុកមារបស់វា ដែលមានផ្ទះជាប់នឹងរបងវិទ្យាល័យ ។ វាមានបងប្អូនសុទ្ធតែប្រុសបីនាក់ បងប្រុសវាជានិសិត្សរៀននៅមហាវិទ្យាល័យច្បាប់ ប្អូនប្រុសវាជាសិស្សរៀននៅសាលាវិចិត្រសិល្បៈ ។

នៅក្នុងវិទ្យាល័យទាំងមូល មានយុវសិស្សប្រុសដប់នាក់ ដែលនិយមទុកសក់វែង អាឃ្មី ក៏ស្ថិតក្នុងចំណោមទុកសក់វែងទាំងនោះដែរ ។ សក់អាឃ្មីវែងប្រះស្មាមើលពីក្រោយច្រឡំស្មានថា ជាស្រី អាឃ្មី ស្រលាញ់សក់វាណាស់ ។

អាឃ្មី វាបែកពីពូមីងបងប្អូនវា មិនដឹងជាចេញទៅតាមច្រកណាទេ ហើយនៅពេលដែលខ្ញុំបានសួរវាថា ចុះឯណាស្បែកជើងអ្ហែង? អាឃ្មី បានឆ្លើយប្រាប់ខ្ញុំថា ពេលចេញពីផ្ទះវាពាក់ស្បែកជើងបាតាមួយគូ តែត្រូវបានពួកមិត្តកងទ័ពរំដោះ ភ្ជុងកាំភ្លើងដោះយកពីជើងថា ជារបស់ជ័យភណ្ឌ យកទៅប្រគល់ឲ្យអង្គការ ។

អាឃ្មី លើកជើងទាំងសងខាងបង្ហាញខ្ញុំ គួរឲ្យអាណិតវាណាស់ ឡើងពងរលាកក្រហមពេញបាតជើង ខ្ញុំបានប្រគល់ស្បែកជើងផ្ទាត់មួយគូឲ្យវា ។

ដោយមិនដឹងទិសដៅថា ត្រូវទៅកាន់ទីណា អាឃ្មីក៏បានយល់ព្រមរួមដំណើរជុំជាមួយខ្ញុំ និងគ្រួសារពូផន ។ អស់ពេលពេញមួយល្ងាចនោះ ទើបយើងបានឆ្លងផុតស្ពានមកដល់ត្រើយម្ខាងច្បារអំពៅ ហើយយើងបានស្រូតដំណើរទៅមុខទៀត មុនពេលយប់ងងឹតមកដល់ ។

ផុតពីច្បារអំពៅបានបន្តិច មីងណារុង ប្រពន្ធពូផន បានប្រញេបប្រញាប់ស្រាយបង្វិចយកក្រមាមួយប្រគល់ឲ្យទៅអាឃ្មីឃុំក្បាលបន្ទាប់ពីយើងបានប្រទះភ្នែកឃើញក្បាលខ្មោចយុវជនសក់វែងប្រះស្មាម្នាក់ ដែលពួកមិត្តបានកាត់យកមកដោតនឹងបង្គោលរបងមួយ ប្របនឹងចិញ្ចើមថ្នល់ក្បែរនោះ ។

យប់ជ្រៅណាស់ទៅហើយ ទើបពួកយើងបានមកដល់បឹងស្នោរ ជាមួយនឹងប្រជាជនយ៉ាងច្រើនកកកុញពាសពេញថ្នល់ ដែលធ្វើដំណើរទៅមកពុំបានស្រាកស្រាន្តមួយវិនាទីណាឡើយ សូម្បីតែតាមចិញ្ចើមទាំងសងខាងថ្នល់ក៏ប្រជ្រៀតដើងដើរសឹងតែពុំរួច ហើយការធ្វើដំណើររឹងរិតតែលំបាកថែមទៀត ដោយមានឡាន និងម៉ូតូពួកមិត្តកងទ័ពបើកបរទៅមកពុំឈប់ឈរ ។ ដើម្បីបើកផ្លូវពួកមិត្តបាញ់កាំភ្លើងឡើងលើលាន់យ៉ាងទ្រហឹង ដែលពួកអ្នកដំណើរជាញឹកញយត្រូវដឹកកង់រុញរទេះចុះពីថ្នល់ ។

យើងបានចូលទៅសម្រាកនៅនឹងផ្ទះឈើមួយខ្នងសង់ផុតពីដីលយចូលទៅក្នុងបឹងបន្តិច ដោយមានស្ពានឈើតូចមួយភ្ជាប់ពីចិញ្ចើមថ្នល់ជាច្រកចូល ។ អ្នកម៉ែ និងមីង ណារុង ប្រញាប់ប្រញាល់នាំគ្នាដណ្តាំស្ល លោកយាយកំពង់សៀម រៀបចំឲ្យធានី គេង ។

គ្រាន់តែហូបបាយរួចភ្លាម មីងណារុងក៏បានយកកន្ត្រៃមកកាត់សក់ឲ្យអាឃ្មីកាត់បណ្តើរគាត់ និយាយទៅកាន់វាបណ្តើរថា ៖ "អត់បានទេក្មួយ....ឃើញនឹងភ្នែកស្រាប់ហើយ....ស្រលាញ់សក់ក៏ស្រលាញ់ជីវិត...." ។

អាឃ្មី បាត់មាត់សូន្យឈឹង វាសម្ងំបណ្តោយឲ្យ មីងណារុងច្រូតសក់វាឲ្យខ្លីយ៉ាងណា ដែលអាចខ្លីទៅបាន ។ យប់នោះដោយអស់កម្លាំងខ្លាំងពេកគ្រាន់តែប្រះខ្នងដល់កំរាល ខ្ញុំក៏ដេកលក់មិនដឹងថាមីង ណារុង ច្រូតសក់អាឃ្មីហើយពីថ្មើរណាផង ។

លុះដល់ព្រឹកឡើង ខ្ញុំឃើញ អាឃ្មី នៅតែឃុំក្បាលនឹងក្រមាដដែល ហើយពេលដែលវាបើកក្រមា ចេញបង្ហាញខ្ញុំ ខ្ញុំមើល អាឃ្មី

សឹងតែពុំស្គាល់សក់ក្បាលវាពីក្រោយដូចដេកក្បែរដំបូកឲ្យកណ្ដៀរស៊ី ។

ខ្ញុំចោលភ្នែកមើលទៅវាលមាត់បឹងខាងក្រោយផ្ទះ នៅនឹងប្រឡាយទឹកដែលមានស្មៅ និងត្រកួនឈ្ងុកទឹកដុះលាយឡំយ៉ាងទ្រុបទ្រុល ខ្ញុំឃើញសាកសពជនស៊ីវិលម្នាក់ដេកស្លាប់ផ្កាប់មុខ ធ្លាក់ខ្លួនមួយចំហៀងចូលទៅក្នុងប្រឡាយ ហើយដែលកំពុងតែហើមយ៉ាងពេញទំហឹង ។

ព្រឹកនោះគឺជាព្រឹកថ្ងៃទីពីរ បន្ទាប់ពីប្រជាជនទូទាំងក្រុងភ្នំពេញ ត្រូវបានពួកមិត្តរំដោះបណ្ដេញចេញពីផ្ទះសម្បែង ។ នៅនឹងបឹងស្នោរ ពួកខ្ញុំមិនបានត្រៀមលក្ខណៈរៀបចំបន្តដំណើរទៅទៀតទេ ពូជន បានប្រាប់ខ្ញុំ និងអ្នកម៉ែថា យើងនៅសំណាក់ត្រឹមនេះហើយ ដើម្បីរង់ចាំមើលសភាពការណ៍សិន ព្រោះនៅតែស្អែកមួយថ្ងៃទៀតទេ គ្រប់បីថ្ងៃហើយ ។

តាំងពីព្រឹករហូតដល់ពេលថ្ងៃត្រង់ ខ្ញុំ និងអាឃ្មី នាំគ្នាឈរមើលប្រជាជន ដែលកំពុងតែប្រជ្រៀតគ្នាធ្វើដំណើរទៅមកយ៉ាងកកកុញ ក្រែងលោបានជួបមិត្តភក្ដិ ជាពិសេស អាឃ្មី ចាំមើលក្រែងបានជួប ពូ មីង និងបងប្អូនរបស់វា ។

ក្នុងចំណោមនោះ ខ្ញុំបានឃើញ អាណារ៉ា (សន ណារ៉ា) កូនលោកស័ក្តិ៩ ប៉េអ៊ឹម សន សាន្ត ប្រចាំការនៅទីក្រុងតាខ្មៅ ខេត្តកណ្ដាល ដែលមានប្អូនស្រីវាម្នាក់ឈ្មោះ សន ណារ៉ាន់ រៀននៅវិទ្យាល័យជាមួយខ្ញុំ និងអាឃ្មី ដែរ ។

អាណារ៉ា គ្រាន់តែបានលើកដៃដាក់ខ្ញុំពីចម្ងាយតែប៉ុណ្ណោះ ព្រោះវាកំពុងតែបើកឡាន *Chevrolet* ពណ៌បៃតងរបស់ឪពុកវា ដឹកពួកមិត្តកងទ័ពរំដោះចេញចូលទីក្រុងភ្នំពេញយ៉ាងមមាញឹក ។

ពួកមិត្តកងទ័ពបួនប្រាំនាក់ជួតក្បាលក្រមាពណ៌ក្រហមជិះក្នុងឡានជាមួយ អាណារ៉ា មិត្តម្នាក់ដែលជិះនៅខាងមុខ អើតក្បាលចេញមកក្រៅតាមបង្អួចស្រែកឲ្យប្រជាជនបើកផ្លូវ ជួនកាលនៅពេលដែលមានភាពកកកុញខ្លាំងពេក ពួកមិត្តបានលើកកាំភ្លើងបាញ់ឡើងលើ ខ្ទាតសំបកគ្រាប់រាយពាសពេញថ្នល់ ។

ថ្ងៃទីដប់ប្រាំបីខែមេសានោះដដែល ពេលហួបបាយថ្ងៃត្រង់រួច ពូជន បានមកបបួលខ្ញុំ និងអាឃ្មី ត្រលប់ទៅទីក្រុងភ្នំពេញវិញ ដើម្បីចូលទៅយកអង្ករនៅនឹងឃ្លាំងអង្ករក្បាលថ្នល់ ព្រោះសភាពការណ៍ដូចជាមិនសូវស្រួលសោះ ។

ពូជន គាត់ហាក់ដូចជាគ្មានរំពឹងថា នឹងបានវិលចូលទីក្រុងភ្នំពេញវិញឡើយ ព្រោះគ្រប់ពេលទាំងអស់ពួកមិត្តរំដោះនៅបានដេញប្រជាជនយ៉ាងរន្ថើនឲ្យបន្តដំណើរទៅមុខ ហើយទៅមុខទៀត ។

ប្រមាណជិតមួយម៉ោងក្រោយមក ពូជន អាឃ្មី និងខ្ញុំក៏បានចេញដំណើរពីបឹងស្នោរត្រឡប់ទៅរកអង្ករនៅឯភ្នំពេញវិញ ។ ពូជន ដឹកកង់គាត់មួយ ខ្ញុំដឹកកង់មួយដោយមានអាឃ្មីដើរតាមពីក្រោយ ដង ទុកឲ្យអ្នកម៉ែ និងគ្រួសារគាត់រង់ចាំនៅទីនោះ ។

ការធ្វើដំណើរបកក្រោយមានការលំបាកខ្លាំងណាស់ ខ្ញុំដឹកកង់តាមក្រោយ ពូជន ដែលជាញឹកញយ ត្រូវដឹកចុះចិញ្ចើមថ្នល់ ជួនកាលត្រូវស្ទះគ្មានបានឈានជើងទៅមុខមួយជំហានផង ។ រហូតដល់ពេលថ្ងៃរសៀល ទើបពួកខ្ញុំបានមកដល់ច្បារអំពៅ ពូជន ក៏ប្រញាប់ប្រញាល់នាំពួកខ្ញុំដើរតម្រង់ទៅកាន់មាត់ទន្លេភ្នាម ។

ក្រោយពីបានផ្ដេកកង់ទាំងពីរចោលនៅនឹងមាត់ច្រាំង ពូជន ដើរទៅរកបានធុងសាំងមួយរួចគាត់ បានប្រើខ្ញុំ និងអាឃ្មី ឲ្យទៅដកដើមចេកឆេះភ្លើងរោលឡើងខ្មៅនៅនឹងផ្ទះប្រជាជនតាមបណ្ដោយមាត់ទន្លេ ដែលត្រូវរងការវាយប្រហារឆេះខ្ទេចខ្ទីសល់តែគំនរផេះ និងដែលនៅមានផ្សែងហុយៗនៅឡើយ ។

ពូជន ប្រមៀលធុងសាំងចុះទឹកទន្លេ គាត់យកដើមចេកចងភ្ជាប់គ្នាដាក់ពីក្រោមធ្វើដូចជាក្បូន រួច ពួកខ្ញុំទាំងបីនាក់ក៏នាំគ្នាហែលរុញក្បូនធុងសាំងនោះកាត់ទទឹងទឹកទន្លេបាសាក់តែម្ដង ហែលតម្រង់ទៅឲ្យចំឃ្លាំងអង្ករនៅឯត្រើយម្ខាងក្បាលថ្នល់ ។

ហែលមកដល់ពាក់កណ្ដាលទន្លេ ខ្ញុំចោលភ្នែកសំលឹងមើលទៅស្ពាននៅឯនាយ ឃើញប្រជាជនធ្វើដំណើរនៅកកលើស្ពានដូចហ្វូងស្រមោច ហើយនៅពេលដែលពួកខ្ញុំបានហែលទឹកមកដល់ត្រើយម្ខាង ខ្ញុំឃើញពួកមិត្តកងទ័ពរំដោះជាច្រើននាក់កំពុងតែបាញ់កាំភ្លើងផូង1ផាំង1ឡើងលើ ដើម្បីទប់ស្កាត់ប្រជាជនរាប់រយនាក់ដែលកំពុងតែសម្រុកចូលយកអង្ករពីក្នុងឃ្លាំង ។

គ្រាន់តែសប់ស្ងួរកាំភ្លើងពួកមិត្តតែបន្តិច ខ្ញុំទាំងបីនាក់រួមជាមួយប្រជាជនជាច្រើននាក់ផ្សេងទៀត ប្រញាប់រត់ព្រួចចូលទៅក្នុងឃ្លាំងអង្ករយ៉ាងធំមួយ ក្នុងចំណោមឃ្លាំងអង្ករមួយជួរនៅតាមបណ្ដោយមាត់ទន្លេនោះ ។

ក្នុងឃ្លាំងខ្ញុំឃើញមានអង្ករយ៉ាងច្រើន រហូតដល់រាប់ពាន់រាប់ម៉ឺនបាវ ដែលដាក់តម្រៀបគ្នាតាំងពីបាតឃ្លាំងទល់ដល់ដំបូល ។ នៅនឹងគៀនជញ្ជាំងក្បែរខ្លួនខ្ញុំបង្អើយ ខ្ញុំប្រទះភ្នែកឃើញសាកសពប្រជាជនពីនាក់ដេកស្លាប់ដោយត្រូវគំនរបាវអង្ករធ្លាក់សង្កត់លើ ។

មុនពេលដែលពួកមិត្តរំដោះបកត្រឡប់មកដេញសាជាថ្មីទៀត ពួកខ្ញុំយកអង្ករបានម្នាក់មួយបាវ ហើយក៏ប្រញេបប្រញាប់លីរត់តម្រង់ទៅរកក្បូននៅឯមាត់ទន្លេវិញ ។

ទៅដល់ ពូផន លោតចុះទៅក្នុងទឹកប្រូង ចាំទទួលអង្ករពីខ្ញុំនិងអាឃ្មីដាក់ទៅលើក្បូន ។ ដាក់អង្ករបានតែមួយបាវ ក្បូនត្រូវធ្ងន់ពៀបនឹងទឹក ។ ដោយគ្មានមធ្យោបាយអ្វីផ្សេង ពូផនក៏បានប្រាប់ឲ្យអាឃ្មី រង់ចាំអង្ករនៅទីនោះ ខ្ញុំនិងគាត់ហែលរុញក្បូនឆ្លងទៅត្រើយម្ខាងមួយសារសិន ។ ប្រមាណជិតមួយម៉ោងក្រោយមក ទើបខ្ញុំ និងពូផនបានហែលរុញក្បូនមកដល់ត្រើយម្ខាងច្បារអំពៅ ។ សំណាងល្អណាស់ដោយកង់ទាំងពីររបស់យើងគ្មានអ្នកណាលួច ក្រោយពីដាក់អង្ករពីក្បូនភ្លាម ពូផន ប្រញាប់ហែលបកទៅវិញតែម្នាក់ឯង ដោយឲ្យខ្ញុំនៅរង់ចាំកង់ និងអង្ករមួយបាវនៅត្រើយខាងច្បារអំពៅនេះ ។

ខ្ញុំនៅរង់ចាំ ពូផន និងអាឃ្មី ដោយអន្ទះសារបំផុត រហូតដល់ថ្ងៃលិចជិតផុត ទើបបានឃើញគាត់ និងអាឃ្មី ហែលរុញក្បូនមកដល់ច្រាំង ។ លើកនេះពូផនផ្ទុកអង្ករបានដល់ទៅពីរបាវ នៅពេលដែលខ្ញុំសួរទៅគាត់ថា ម៉េចក៏យូរម្ល៉េះ? គាត់បានឆ្លើយប្រាប់ខ្ញុំថាដោយសារ គាត់ត្រូវស្រាយក្បូនរៀបចំចងសាជាថ្មី ។

យប់បានមកដល់ល្មម ពេលដែលខ្ញុំ និងពូផន បានផ្ទុកអង្ករលើកង់ រួចផ្ដើមចេញដំណើរពីមាត់ទន្លេតម្រង់ទៅថ្នល់ជាតិ ។ កង់ពូផនដឹកអង្ករមួយបាវ កង់ខ្ញុំដឹកបានពីរបាវដោយមាន អាឃ្មី ចាំជួយទប់ ជួយរុញពីក្រោយផង ។

ឡើងមកដល់ថ្នល់ជាតិ ពូផន ដឹកកង់នាំផ្លូវពីមុខខ្ញុំព្រោះតែមនុស្សច្រើនពេក ខ្ញុំដឹកកង់តាមពីក្រោយពូផនដោយប្រុងប្រយ័ត្នបំផុតខ្លាចវង្វេងគ្នា ។ ដោយហេវហត់ ហើយពេលឡើងពីទឹកមក ខោអាវនៅសើមជោគថែមទាំងគ្មានបាយមួយគ្រាប់ក្នុងពោះផង អាឃ្មីបានស៊ុះទៅជួយពូផនជាញឹកញយ នៅពេលដែលវាបានឃើញពូផនទន់ជើងអស់កម្លាំងទ្រេតទ្រោតចង់ដួល ។

យប់នោះរហូតដល់ជិតពាក់កណ្ដាលអាធ្រាត្រ ទើបពួកខ្ញុំបានដឹកកង់មកដល់បឹងស្នោរវិញ ដោយមានអ្នកម៉ែ និងមីងណារុងរង់ចាំមើលផ្លូវពួកខ្ញុំនៅនឹងចិញ្ចើមថ្នល់តាំងពីក្បាលព្រលប់មក ។

គ្រាន់តែដាក់បាវអង្ករចុះផុតពីកង់ ដោយអស់ល្ហិងល្ហើយក្នុងខ្លួនខ្លាំងពេក ខ្ញុំ និងអាឃ្មីព្រមទាំង ពូផន បានប្រះខ្លួនទៅលើកំរាលរង់ចាំទម្រាំ មីងណារុង និងអ្នកម៉ែរៀបចំបាយទឹករួច ក្នុងវិនាទីជាមួយគ្នានោះ ស្រាប់តែខ្ញុំបានឮសម្រែកស្រែក អូយ .....អូយ ...ដែលនៅមិនឆ្ងាយប្រមាណពីទីនោះ ឮសូរគួរឲ្យសង្វេគ ។

ខ្ញុំក៏ប្រញាប់ស៊ុះក្រោកចេញទៅមើល នៅនឹងចិញ្ចើមថ្នល់ក្រោមស្ពានប្រកបូល ខ្ញុំបានឃើញបុរសចំណាស់ម្នាក់អាយុប្រមាណជាងហាសិបឆ្នាំ សក់ល្បាយអាចម៍ខ្លា កំពុងតែដេកក្នុងថ្លុកឈាម ដៃគាត់ទាំងពីរខ្ទប់ចំមុខរបួសត្រង់ចង្កេះ ដែលមានឈាមហូរសើមជោគមួយកំណាត់ខ្លួន ។ មីងណារុង បានប្រាប់ខ្ញុំថា គាត់ត្រូវរបួសកាលពីថ្ងៃរសៀលនេះដោយសារពួកមិត្តកងទ័ពរៀលកៃកាំភ្លើងពេលដែលពួកមិត្តពីរនាក់ជិះម៉ូតូហុងដាមួយគ្រឿងលើកកាំភ្លើងឡើងបាញ់បើកផ្លូវ ។

ក្រោមពន្លឺដួងខែ យប់ថ្ងៃដប់បីកើតខែចេត្រ បុរសរងគ្រោះដ៏កំសត់បានខំប្រឹងបើកភ្នែកភ្លឹះៗ សម្លឹងមើលគេឯងដែលដើរទៅហួសមកហួសជាមួយនឹងសម្រែកដែលកាន់តែខ្សោយទៅៗ ..ជួយខ្ញុំផង...ជួយខ្ញុំផង...! ឮគួរឲ្យអាណិតអាសូរពេកក្រៃ.. ។

ប្រជាជនដែលធ្វើដំណើរទៅមក បានត្រឹមតែក្រឡេកមើលរួចបន្តដំណើរទៅមុខទៀត ក្នុងគ្រាដ៏អាសន្នបែបនេះគ្មានអ្នកណាជួយយកអាសារអ្នកណាឡើយ សូម្បីតែពួកមិត្តកងទ័ពក៏ទៅហួសមកហួសដែរ គ្មានមិត្តរំដោះណាម្នាក់រវល់អើពើនឹងសម្រែកដ៏ខ្លោចផ្សារបស់គាត់ឡើយ ។

លុះដល់ព្រឹកស្អែកឡើង ខ្ញុំបានឃើញបុរសរងគ្រោះដេកស្លាប់ទាំងបិទភ្នែកមិនជិត នៅក្បែរកូនហិបខោអាវតូចមួយដែលជាកម្មសិទ្ធិរបស់គាត់ និងកង់កញ្ចាស់មួយដែលផ្ដេកចោលក្បែរនោះ ។

ព្រឹកថ្ងៃដដែល ពួកខ្ញុំក៏បានចាកចេញពីផ្ទះសំណាក់នៅបឹងស្នោរនោះភ្លាមដែរ ព្រោះពួកមិត្តបានដើរដេញប្រជាជនដែលស្នាក់នៅតាមផ្ទះទាំងសងខាងផ្លូវឲ្យបន្តដំណើរទៅមុខទៀត ដោយមិនអនុញ្ញាតឲ្យប្រជាជនណាម្នាក់ស្នាក់នៅទីនោះឡើយ ។

**(តទៅលេខក្រោយ)** **ប៉ុក ប៉ុនសូម៉ាថ**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៧៩៧ ៣៩៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។










ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 188, 2015 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.